ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Oct-2013, 10:07
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# លើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០២នាទី**

**សវនាការលើកទី២១៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ស៊ីម៉ុន មេស៊ិនប៊ឺជ

*(Mr. Simon MEISENBERG)*

កញ្ញា មីរាម ម៉ាហ្វេសសាន់ទិ

*(Ms. Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក នីកូឡាស គូមជែន

*(Mr.Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

លោក វ៉េង ហ៊ាត់

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ឃីត រេយ៍ន័រ *(Mr. Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន
*(Mr. Arthur VERCKEN)*

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក សំ សុគង់

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រីនណា

លោក អូលីវីយ៉េ បាហ៊ូញ
*(Mr. Olivior BAHOUGNE)*

កញ្ញា លីម៉ា ង្វៀន *(Ms.Lyma NGUYEN)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ជា លាង | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីបន្តធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួនជាបន្ត។ ហើយមុននឹងផ្តល់វេទិកាជូនលោកសហព្រះរាជអាជ្ញា លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍ស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីក្រោមបន្ទប់សវនាការនេះ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុសុខភាព។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាបន្តទៅនេះអង្គជំនុំជម្រះវេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីបន្តធ្វើការថ្លែងនូវសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ សូមអញ្ជើញ!

**លោកស្រី ជា លាង៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូលសាជាថ្មីម្តងទៀត។ យើងខ្ញុំសូមបង្ហាញនូវភស្តុតាងជាបន្តបន្ទាប់ទៀត ដែលពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំក្នុងដំណាក់-កាលទី២។

ដោយយោងទៅលើសារទូរលេខមួយ ដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការជម្លៀសដំណាក់កាលទី២។ សារទូរលេខនេះចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ត្រូវបានផ្ញើដោយ សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា ដែលបានប្រើឈ្មោះថា ផុន។ សារទូរលេខនេះត្រូវផ្ញើទៅ ប៉ុល ពត និងបានចម្លងជូនលោក នួន ជា

និង ឌឿន ដែលជាសហសេវិករបស់ ខៀវ សំផន ធ្វើការនៅមន្ទីរនយោបាយ គឺមន្ទីរ៨៧០។

[០៩:០៥:៣៩]

ប្រធានបទនៅក្នុងសារទូរលេខនេះ គឺទាក់ទងទៅនឹងអំពើអំពីបញ្ហាដកមនុស្សពីភូមិភាគបូព៌ាទៅឧត្តរ។ ឯកសារនេះបានបញ្ជាក់យ៉ាងច្បាស់ថា ការជម្លៀសនេះដែលបានដំណើរការស្របទៅតាមសេចក្ដីសម្រេចរបស់មជ្ឈិមបក្ស។ ឯកសារនេះបានសរសេរថា៖ "យើងរាយការណ៍អំពីការជម្លៀសប្រជាជនពីភូមិភាគបូព៌ា ទៅភូមិភាគឧត្តរ ដែលមានការជំទាស់ខ្លះ និងបានអនុវត្តតាមការណែនាំរបស់អង្គការ និងមិនបានណែនាំនូវគោលដៅ"។ បន្ទាប់មកទៀត ឯកសារបង្ហាញថា "ការជម្លៀសប្រជាជនជាគោល-ការណ៍គឺបំបែកស្របតាមការណែនាំរបស់បង ដូចដែលបានពិភាក្សាលើមុនជាមួយយើងខ្ញុំ"។ សោម ភឹម បានបញ្ជាក់ផងដែរថា ជាគោលភូមិភាគនេះត្រូវដកមនុស្ស៥០.០០០នាក់ចេញ និងផ្ទេរពួកគេទាំងអស់ទៅឲ្យភូមិភាគឧត្តរវិញ។ មូលហេតុដែល សោម ភឹម បញ្ជូនសារទូរលេខនេះ គឺគាត់ប្រឈមមុខនឹងបញ្ហានៅក្នុងការអនុវត្តសេចក្ដីណែនាំរបស់មជ្ឈិមបក្ស។ ភូមិភាគឧត្តរមិនទទួលចាមទេ។ ដូចនេះ សោម ភឹម រាយការណ៍បញ្ហានេះ ទៅមជ្ឈិមបក្ស ហើយបញ្ជាក់ថា៖ "បងត្រូវសម្រេចបញ្ហានេះ"។ សារទូរលេខមួយនេះនិយាយពីការជម្លៀសប្រជាជន៥០.០០០នាក់។ ទន្ទឹមនឹងនេះដែរ មានភស្តុតាងជាក់ស្តែង និងអាចជឿជាក់ពីប្រភពដទៃផ្សេងៗទៀត ចំពោះមនុស្សដែលបានត្រូវជម្លៀស។

[០៩:០៦:៣៦]

សុខ ឈិន ជាកម្មករអយស្ម័យយានម្នាក់ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះកន្លងមក ត្រូវបានសួរពីប្រជាជនជម្លៀសរាប់ពាន់នាក់ ដែលគាត់បានឃើញផ្ទាល់នៅត្រពាំងឈ្វូង ក្នុងខេត្តពោធិ៍សាត់។ គាត់បានបញ្ជាក់ថា វាជាការពិត ដូចអ្វីដែលគាត់បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេត។ "ខ្ញុំបានឃើញរថភ្លើងពីរដងក្នុងមួយសប្តាហ៍។ រថភ្លើងនោះ មានទូប្រមាណ២០ ទៅ២៥ទូ។ ធម្មតាដឹកទំនិញ និងរបស់របរ។ ទូនីមួយៗដឹកមនុស្សពី៤០ ទៅ៥០នាក់។ គាត់ក៏បានបញ្ជាក់ផងដែរថា ចំនួននៃការដឹកជញ្ជូន និងជម្លៀសនេះ មានបន្តបន្ទាប់មានរយៈពេលបីខែ គឺខែតុលា វិច្ឆិកា និងធ្នូ ឆ្នាំ១៩៧៥។ សាក្សីជាច្រើនបានបញ្ជាក់ថា ជនរងគ្រោះដោយសារការជម្លៀសដោយបង្ខំដំណាក់កាលទី២ ភាគច្រើន គឺប្រជាជនថ្មី។ អោ រី បានជម្រាប លោក លោកស្រីចៅក្រមថា៖ "គេបញ្ជូនតែប្រជាជនថ្មីទៅទេ។ គេទុកប្រជាជនមូលដ្ឋាន"។ សុខ ឈិន បញ្ជាក់ថា៖ "ច្បាស់ណាស់ អ្នកទាំងនោះជាប្រជាជនថ្មី អ្នកដែលទើបតែមកថ្មី។ អ្នកទាំងអស់នោះត្រូវបានគេជម្លៀសពីភ្នំពេញទាំងអស់ គ្មានអ្នកមូលដ្ឋានទេ"។

ពេជ ស្រីផល បាននិយាយថា៖ "គ្មានប្រជាជនមូលដ្ឋានណាម្នាក់ឡើងជិះលើរថភ្លើងទេ។ អ្នកទាំងនោះ គឺសុទ្ធតែប្រជាជន១៧មេសា។ អ្នកខ្លះមកពីភ្នំពេញ និងអ្នកខ្លះទៀតមកពីតាមខេត្តផ្សេងៗ"។

[០៩:០៨:៣១]

ការអះអាងរបស់មេធាវីការពារក្តីមិនត្រឹមត្រូវទេ។ តាមការពិត ការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី២ បានបណ្តាលឲ្យមនុស្សស្លាប់ជាច្រើននាក់។ ប្រជាជនថ្មីមួយចំនួនត្រូវបានគេបាញ់ក្នុងពេលកំពុងធ្វើដំណើរ។ មានប្រជាជនស្លាប់តាមផ្លូវ ដោយសារដាច់បាយ បាក់កម្លាំង និងមានជំងឺ។ នៅពេលដល់កន្លែងថ្មីមិនបានបញ្ចប់ការសម្លាប់មនុស្សនោះឡើយ។ ប្រជាជនទាំងនោះ ត្រូវបានគេយកទៅចោលនៅក្នុងព្រៃ គ្មានអ្វីហូប គ្មានជម្រក និងថ្នាំសង្កូវ។ តើក្រុមមេធាវីការពារក្តីឆ្លើយតបយ៉ាងដូចម្តេចដែរ អំពីការស្លាប់មនុស្សដ៏សន្ធឹកសន្ធាប់នេះ? តើនោះគ្រាន់តែជាឧប្បត្តិហេតុឬ?

ផលវិបាកដែលមិនអាចគ្រោងទុក នៃការអនុវត្តផែនការនយោបាយដ៏ភ្លីស្វាង។ ភស្តុតាងនេះ ក៏ផ្ទុយនឹងការអះអាងរបស់ជនជាប់ចោទដែរ។ ច្បាស់លាស់ណាស់ចំពោះ នួន ជា និងខៀវ សំផន និងអ្នកដឹកនាំដទៃទៀតនៅក្នុងមជ្ឈិមបក្ស ដែលមានមនុស្ស ដែលបណ្តាលឲ្យមនុស្សស្លាប់យ៉ាងច្រើន។ នេះគ្រាន់តែជាការជម្លៀសចេញពីភ្នំពេញ ក្នុងខែមេសា ឆ្នាំ១៩៧៥ប៉ុណ្ណោះ ដែលពួកគេដឹងអំពីការស្លាប់ប្រជាជនដែលមានមិនអាចជៀសបាន។

[០៩:១០:០៧]

គេមិនអាចជម្លៀសមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់ តាមវិធីអមនុស្សធម៌បែបនេះ និងបែរជាមិនដឹងអំពីផលវិបាកដែលនឹងមាននោះទេ។ ការស្លាប់ដ៏ច្រើនលើសលប់ ជាលទ្ធផលផ្ទាល់ និងមិនអាចជៀសវាងបាន។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានដឹង តែពួកគេមិនបានចាត់វិធានការណាមួយ ដើម្បីកាត់បន្ថយការរងទុក្ខវេទនានោះទេ។ នៅតាមផ្លូវ គ្មានកន្លែងផ្តល់ម្ហូបអាហារ។ ទឹកក៏គ្មាននរណាចែកឲ្យ។ កូនក្មេងត្រូវផឹកទឹកមិនស្អាត។ ប្រជាជនត្រូវបានកៀងទាំងហ្វូងឡើងលើទូរថភ្លើង ដូចកៀងសត្វពាហនៈ។ នៅតាមផ្លូវរថភ្លើង មានសាកសពមនុស្សរាយប៉ាយ។ ពួកទាហានបានគ្រវែងកូនក្មេងចេញតាមបង្អួចទូរថភ្លើង។ ពួកគេបានឲ្យប្រជាជនបញ្ច្រៀតគ្នានៅក្នុងទូរថភ្លើងទទេ គ្មានកៅអីអង្គុយ។ ប្រជាជនត្រូវបន្ទោបង់នៅកណ្តាលហ្វូងមនុស្សក្នុងទូរថភ្លើង។

លោក លោកស្រីចៅក្រម ឥឡូវយើងសាកនឹកស្រមៃទៅដល់ស្ថានភាពនោះទាំងអស់គ្នា ថាតើវាអាក្រក់ប៉ុនណា? តើធុំក្លិនស្អុយ ឆ្អេះឆ្អាបប៉ុនណា បើក្នុងទូរថភ្លើង គ្មានខ្យល់អាកាសចេញចូល និងគ្មាន

ពន្លឺ យើងលាយឡំជាមួយក្តីព្រួយបារម្ភអំពីអនាគតមិនច្បាស់លាស់ ភាពភ័យខ្លាច និងការជម្លៀសម្តង ទៀត ដោយមានពួកអ្នកយាមដែលមានកាន់អាវុធគ្រប់ដៃ ការគិតដល់ សេចក្តីស្លាប់ដែលនឹងមកដល់។ តើទាំងអស់នេះឬដែលជាផ្នែកមួយនៃផែនការសេដ្ឋកិច្ចច្បាស់លាស់ ដែលដាក់ចេញដោយ នួន ជា និង ខៀវ សំផន?

[០៩:១២:១២]

ដូចខ្ញុំបានជម្រាបរួចហើយ នៅពេលយើងវាយតម្លៃលើការប្រព្រឹត្ត និងស្ថានភាពផ្លូវចិត្តរបស់ជនជាប់ចោទទាំងពីររូប។ យើងសូមស្នើឲ្យ លោក លោកស្រីចៅក្រម មេត្តាពិនិត្យមើលព្រឹត្តិការណ៍ដែលបានកើតឡើងជុំវិញការជម្លៀសនេះ។ ក្នុងនោះរួមមាន៖ ភាពឃោរឃៅនៃអំពើ ការប្រើការ បង្ខិតបង្ខំ និងការប្រើប្រាស់ហិង្សាដើម្បីអនុវត្តនូវការជម្លៀស ការអនុវត្តដែលធ្លាប់បានធ្វើកន្លងមកប្រព្រឹត្តឡើងចំពោះប្រជាជនក្រុង។ ការសម្លាប់ជាប្រព័ន្ធ និងការធ្វើអោយមានការឈឺចាប់ ធ្វើឡើងទៅលើប្រជាជនជាច្រើនជុំវិញការជម្លៀសនេះ គឺជាលទ្ធផលដោយផ្ទាល់កើតពីគម្រោងការរបស់មជ្ឈិមបក្ស។ ការប្រព្រឹត្តបទឧក្រិដ្ឋគឺមិនអាចវាងបានឡើយ។ ឧក្រិដ្ឋកម្មនានា គឺជាផែនស្នូលនៃគម្រោងការឧក្រិដ្ឋ និងការធ្វើទុក្ខបុកម្នេញជាប្រព័ន្ធ ត្រូវបានគាំទ្រនិងឲ្យមានជាបន្តទៀត ដោយ នួន ជា និង ខៀវ សំផន។

ភស្តុតាងនៃការស្លាប់មនុស្ស បានមកពីប្រភពឯករាជ្យជាច្រើន ដែលបានពិពណ៌នាការស្លាប់មនុស្សតាមរូបភាពផ្សេងៗ។ អ្នកស្រី តេង សុខា បានផ្តល់សក្ខីកម្មនៅចំពោះមុខលោក និង លោកស្រីចៅក្រមរួចហើយ អំពីការស្លាប់របស់កូនស្រីគាត់អំឡុងពេលជម្លៀសដោយបង្ខំដំណាក់កាលទី២។ ការស្លាប់នេះ គឺជាការទទួលខុសត្រូវរបស់ជនជាប់ចោទ។ លោកស្រីបានរៀបរាប់ការស្លាប់របស់កូនស្រីគាត់ថា៖ “កូនស្រីទី២របស់ខ្ញុំ បានស្លាប់នៅក្នុងពេលជម្លៀសលើកទី២ គឺនៅពេលយើងបានទៅដល់ខេត្តបាត់ដំបង។ នាងស្លាប់ដោយសារអត់បាយ។ រាងកាយរបស់នាងឡើងហើម និងមានជំងឺរាករូសខ្លាំង។ ដោយគ្មានថ្នាំសង្កូវព្យាបាល។ នាងស្លាប់នៅដើមឆ្នាំ១៩៧៦”។

[០៩:១៤:៣២]

រាល់ការស្លាប់នីមួយៗ ដែលបានកើតឡើងក្នុងអំឡុងពេល ឬកើតឡើងដោយសារផលវិបាកនៃការជម្លៀសផ្ទាល់ ឬ កើតឡើងភ្លាមនៅក្រោយការជម្លៀសដោយបង្ខំដំណាក់កាលទី២ គឺស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តីនេះ។ ដើម្បីបណ្តឹងរដ្ឋប្បវេណីដែលមានលេខឯកសារ E3/5423 គឺជាប្រជាជនដែលគេជម្លៀសពីទីក្រុងភ្នំពេញមួយរូប ក្នុងចំណោមប្រជាជន ១៧មេសា ផ្សេងទៀត។

លោកស្រីរំឮកអំពីរឿងហេតុនៃការស្លាប់របស់កូនស្រីរបស់គាត់។ កូនគាត់ស្លាប់ដោយសារដាច់បាយ។ កូនគាត់ស្លាប់ អំឡុងពេលជម្លៀសប្រជាជនចេញពីខេត្តកំពង់ស្ពឺ ទៅកាន់ខេត្តបាត់ដំបង។ លោកស្រីបានមានប្រសាន៍ថា៖ "ពួកគេបានបញ្ជាប្រមូលពួកយើង ឲ្យមកជុំគ្នានៅស្ថានីយរថភ្លើងព្រៃទទឹង ដើម្បីឡើងជិះរថភ្លើងទៅខេត្តបាត់ដំបង... ដោយសារតែយើងជាអតីតអ្នករស់នៅទីក្រុងភ្នំពេញ ពួកគេដាក់ឈ្មោះយើងថា ប្រជាជន១៧មេសា និងបានបង្ខំឲ្យពួកយើងធ្វើការដោយគ្មានឈប់សម្រាក។ ចំពោះម្ហូបអាហារ ពួកគេឲ្យអង្ករ១០កំប៉ុងក្នុងមួយថ្ងៃ សម្រាប់គ្នា៣០នាក់។ ការអត់អាហារធ្វើឲ្យប្រជាជនធ្លាក់ខ្លួនឈឺ និងស្លាប់រាល់ថ្ងៃ។ កូនស្រីរបស់ខ្ញុំឈ្មោះ ហាក់ គឹមលី ធ្លាក់ខ្លួនឈឺ និងស្លាប់ដោយអត់បាយក្នុងឆ្នាំនោះដែរ"។

លោក ពិន យ៉ាថៃ បានឃើញផ្ទាល់ភ្នែកអំពីការស្លាប់ជាច្រើន។ ពោលគឺមនុស្សចាប់ផ្ដើមស្លាប់ច្រើន នៅមួយសប្ដាហ៍បន្ទាប់ពីគេយកទៅដាក់ចោលក្នុងព្រៃវាលវង់ ក្នុងខែកញ្ញា ឆ្នាំ១៩៧៥។ គាត់បានបញ្ជាក់ថា គាត់នៅចាំច្បាស់អំពីព្រឹត្តិការណ៍ទាំងនេះ នឹងបានកត់ត្រាទុកនៅក្នុងសៀវភៅរបស់គាត់។ គាត់រៀបរាប់យ៉ាងដូច្នេះថា៖ "មិនយូរប៉ុន្មាន មនុស្សចាប់ផ្ដើមស្លាប់ជាបន្តបន្ទាប់។ គ្រាន់តែនៅក្នុងសប្ដាហ៍ទីមួយ ខ្ញុំបានឃើញមនុស្សសែងសាកសពជាច្រើន កាត់តាមផ្លូវ។ រឿងស្លាប់នេះគឺគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ដ្បិតមានមនុស្សច្រើនណាស់ នៅក្នុងព្រៃនេះ និងស្ថានភាពសុខភាពក៏មានបញ្ហា។ គេកប់សាកសពទាំងនោះនៅក្នុងព្រៃ ក្បែរវាលដែលយើងទើបកាប់ឆ្ការរួចថ្មីៗ"។

[០៩:១៧:២៦]

ជាថ្មីម្ដងទៀត ការស្លាប់បន្ថែមទៀតទាំងអស់នេះ គឺជាការទទួលខុសត្រូវរបស់ជនជាប់ចោទ។ លោក ពិន យ៉ាថៃ អត់មានបាយហូប។ គាត់ត្រូវសង់ជម្រកស្នាក់នៅដោយខ្លួនឯង។ មានប្រជាជនថ្មីជាច្រើននាក់ ត្រូវបានគេយកទៅដាក់ចោលនៅក្នុងព្រៃជ្រៅ បន្ទាប់ពីគាត់បានទៅដល់ទីនោះ។ ប្រការនេះគឺចៀសមិនផុតពីការធ្វើឲ្យមនុស្សស្លាប់កាន់តែច្រើនឡើងនោះទេ។ ការស្លាប់ទាំងនេះ នៅតែពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំដំណាក់កាលទី២ដដែល។ គាត់បានរៀបរាប់បន្ថែមថា៖ "ឥឡូវ នៅក្នុងព្រៃនៅជុំវិញយើង ការស្លាប់ចាប់ផ្ដើមកាន់តែញឹកញាប់ជាងមុន។ គេកប់សាកសពនៅកន្លែងវាលនៅក្បែរៗនោះ។ ប្រធានភូមិបានចាត់អ្នកកប់សាកសពទាំងនេះ ដើម្បីឲ្យមកកប់សព។ ការងាររបស់អ្នកកប់សាកសព កាន់តែមានតម្រូវការចាំបាច់ ដ្បិតក្រុមគ្រួសារសពចាប់ផ្ដើមថមថយកម្លាំង ដោយមិនអាចជីករណ្ដៅកប់សាកសពបានដោយខ្លួនឯង។ ការងារកប់សពនេះមិនអាក្រក់ប៉ុន្មានទេ ដ្បិតបើពួកគេរវល់កប់សព ពួកគេមិនបាច់ទៅធ្វើការមួយថ្ងៃបាន...។ ការងារពលកម្មកាន់តែលំបាក និង គ្មានពេលសម្រាក

សោះ... យើងចាប់ផ្តើមរាស់ពេលវេលា ជាមួយនឹងចំនួនមនុស្សនៅជុំវិញយើងស្លាប់ក្នុងមួយថ្ងៃៗ ថ្ងៃខ្លះស្លាប់បួននាក់ ថ្ងៃខ្លះប្រាំនាក់ មានថ្ងៃខ្លះមានមនុស្សស្លាប់រហូតដល់ ១០នាក់ក៏មាន"។

[០៩:១៩:២៣]

ខ្ញុំសូមអញ្ជើញលោក លោកស្រីចៅក្រម នឹកស្រមៃអំពីទិដ្ឋភាពនោះមើល។ ប្រជាជនថ្មីដែលកំពុងតែងាយប្រឈមមុខទៅនឹងសេចក្តីស្លាប់ ដែលត្រូវបានគេបញ្ជាឲ្យយកខ្មោចទៅកប់ បានគិតថាវាជាការធូរស្រាល ដោយសារថា គេអាចជៀសវាងការស៊ូទ្រាំធ្វើពលកម្មដោយបង្ខំសម្រាប់ថ្ងៃនោះបាន។ យោងតាមការវិភាគមួយ តើគេអាចយល់ឃើញបញ្ហានេះ ថាវាជាតម្លៃមនុស្សដែលអាចធ្វើយុត្តិកម្មបានដោយរបៀបណាចំពោះកម្មវិធីនយោបាយដ៏ភ្លីស្វាងនេះ។ លោក ពិន យ៉ាថៃ បានបញ្ជាក់អះអាងថា៖ "នៅពេលគាត់រស់នៅក្នុងព្រៃនៅវាលវង់ចន្លោះពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ចុងខែវិច្ឆិកា ឆ្នាំ១៩៧៥ មនុស្សមួយភាគបីនៃចំនួនប្រជាជនសរុបទាំងអស់ ៥.០០០នាក់បានស្លាប់"។ ស្លាប់រាប់ពាន់នាក់ គឺមិនមែនរាប់រយនាក់នោះទេ។ នៅក្នុងសក្ខីកម្មរបស់ ទឹង សុខា លោកស្រីបានរៀបរាប់អំពីការស្លាប់ដែលបានកើតឡើងនៅពេលដែលគេយកលោកស្រីទៅទុកនៅក្នុងព្រៃជិតក្នុងខេត្តបាត់ដំបង គេបានដឹកលោកស្រីតាមរថយន្តកាំម៉ុង និងតាមរថភ្លើងពីខេត្តតាកែវ ហើយក្រោយមកក៏ត្រូវបានគេបំបែកពីឪពុកម្តាយ មិត្តភក្តិ និងសាច់ញាតិរបស់គាត់។ លោកស្រីបានរៀបរាប់អំពីស្ថានភាពរបស់គាត់ថា៖ "ហើយពេលខ្ញុំទៅដល់ខេត្តបាត់ដំបងហ្នឹងស្ថានភាពធ្ងន់ធ្ងរដោយមានតែខ្ញុំម្នាក់ឯងនៅក្នុងព្រៃ ខ្ញុំគ្មានទីពឹងអ្វីទេ។ គ្មានជម្រកគ្មានចំណីអាហារ គ្មានថ្នាំពេទ្យ ហើយត្រូវប្រមូលឫស្សី និងឈើមកសង់ខ្ទម។ មនុស្សជាច្រើនធ្លាក់ខ្លួនឈឺយ៉ាងធ្ងន់ធ្ងរ និងស្លាប់ជាបន្តបន្ទាប់។ ប្រជាជនថ្មីទទួលបានបបររាវៗ។ ហេតុដូច្នេះគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេថាមនុស្សជាច្រើនបានស្លាប់"។

[០៩:២១:៥២]

ដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុងឯកសារលេខE3/5053 ជាអ្នកភូមិនៅក្នុងឃុំជ្រោយនៃខេត្តកណ្តាល បានរៀបរាប់អំពីការស្លាប់សមាជិកគ្រួសាររបស់គាត់ថា៖"ក្នុងដើមឆ្នាំ១៩៧៦ ខ្មែរក្រហមបានជម្លៀសគ្រួសាររបស់ខ្ញុំ របបអាហារមិនគ្រប់គ្រាន់ទេ។ យើងម្នាក់ៗទទួលបានតែបបររាវៗតែពីរស្លាបព្រាប៉ុណ្ណោះ។ ជាបច្ច័យអាក្រក់ពួកគេទាំងពីរនាក់ធ្លាក់ខ្លួនឈឺ ហើយបានស្លាប់ដោយសារការអត់ឃ្លាន។ ការស្លាប់ក៏បានកើតមានឡើងនៅក្នុងពេលជម្លៀសនេះផងដែរ"។ លោក សុខ ឈិន ជាកម្មកររថភ្លើងដែលខ្ញុំបានលើកឡើង និងយោងខាងលើបានរៀបរាប់ជូនលោក លោកស្រីចៅក្រម រួចហើយថា

តើគាត់បានកប់សាកសពជនរងគ្រោះដែលគេជម្លៀសដោយរបៀបណានោះ។

“គ្មានអ្នកណាម្នាក់អាចចាកចេញទៅណាបានទេ ដោយសារមានគេយាមកាម ហើយអ្នកដែលឈឺត្រូវស្លាប់នៅទីនោះ។ ខ្ញុំបានយកខ្មោចទៅកប់ដោយផ្ទាល់ដៃ ព្រោះខ្មោចស្លាប់នៅតាមផ្លូវហើ្នងវាធុំក្លិនស្អុយ។ ដូច្នេះយើងត្រូវតែកប់ខ្មោចទាំងនោះ។ ក្រោយមកគាត់បញ្ជាក់ថា មានហេតុល្អសម្រាប់គាត់ក្នុងការកប់សាកសពទាំងនោះ។ ខ្មោចដែលខ្ញុំបានកប់ គឺជាខ្មោចដែលបានស្លាប់នៅតាមផ្លូវរថភ្លើង ហើយដោយសារតែវាធុំក្លិនស្អុយពេកយើងមិនអាចធ្វើការងារបានទេ។ ដូច្នេះ ខ្ញុំត្រូវតែកប់ខ្មោចទាំងនោះ តែខ្មោចដែលនៅឆ្ងាយពីផ្លូវរថភ្លើង ខ្ញុំមិនបានកប់ខ្មោចទាំងនោះទេ។ ខ្ញុំបានឃើញខ្មោចខ្លះដែលនៅឆ្ងាយពីផ្លូវរទេះភ្លើងគេគ្របទុកចោលនៅតាមភ្លឺស្រែ ឬតាមបណ្ដោយផ្លូវ”។

[០៩:២៤:០៥]

លោកស្រី ពេជ ស្រីផល បានផ្ដល់សក្ខីកម្មនៅចំពោះមុខលោក លោកស្រីចៅក្រមថា៖ “ប្រជាជនបានស្លាប់នៅក្នុងទូរថភ្លើង ដោយរបៀបណារួចមកហើយ និងអំពីការឆ្លើយតបរបស់ឆ្មាំខ្មែរក្រហម។ គ្មានអ្នកណាម្នាក់អាចរត់ចេញបានទេ ព្រោះពួកគេយាមកាមនៅតាមមាត់ទ្វាររថភ្លើង ទូរថភ្លើង ហើយគេប្រើរនុកឈើដើម្បីបិទទ្វារទូរទេះភ្លើងផងដែរ។ ប្រជាជនខ្លះបានស្លាប់នៅក្នុងទូរទេះភ្លើងដោយសារតែអស់កម្លាំងខ្លាំងពេក ហើយនៅក្នុងទូរទេះភ្លើងមានមនុស្សណែនតាន់តាប់ណាស់។ ទោះបីជាមានមនុស្សស្លាប់ក៏ដោយ ក៏រទេះភ្លើងមិនឈប់ ដើម្បីឲ្យគេយកខ្មោចទាំងនោះចេញទៅទុកនៅខាងក្រៅដែរ។ នៅពេលមានអ្នកណាស្លាប់នៅក្នុងទូរទេះភ្លើង ពេលនោះកងទ័ពខ្មែរក្រហមបានរុញខ្មោចនោះទម្លាក់ចេញពីទូរទេះភ្លើង ដោយសារពួកគេគិតថា វាគ្រាន់តែជាកាកសំណល់តែប៉ុណ្ណោះ”។ កម្មករផ្លូវដែកម្នាក់ទៀតដែលមានរហស្សនាម TCW-285 បានបញ្ជាក់ថា ពេលប្រជាជនធ្វើដំណើរពីភ្នំពេញទៅកាន់ខេត្តបាត់ដំបងនៅក្នុងឆ្នាំ១៩៧៥ “ប្រជាជនច្រើនបានស្លាប់ ដោយសារពួកគាត់គ្មានអ្វីហូប” ។

[០៩:២៥:៤៤]

លោក ពិន យ៉ាថៃ ក៏បានឃើញមនុស្សស្លាប់នៅក្នុងទូរថភ្លើងដោយផ្ទាល់ភ្នែក។ “ចំពោះការជម្លៀសលើកទី២នេះ គេបញ្ជូនយើងមកឲ្យជិះឡាន ហើយឡាននោះគ្មានដំបូលទេ។ ហើយជាការពិតនៅលើឡានដែលខ្ញុំជិះ មនុស្សពីរនាក់បានសន្លប់ ហើយក្រោយមកក៏ស្លាប់ទៅ”។

ដូច្នេះលោក លោកស្រីចៅក្រម ជាមួយនឹងភស្តុតាងនៃការស្លាប់នេះ ថាតើលោក លោកស្រីចៅក្រមអាចវាយតម្លៃបានដោយរបៀបណាចំពោះការអះអាងរបស់ នួន ជា ថា “មិនមានសក្ខីកម្មបញ្ជាក់

ពីចំនួនមនុស្សស្លាប់ដ៏ច្រើនសន្ធឹកសន្ធាប់ នៅក្នុងអំឡុងពេល ឬនៅក្នុងការទាក់ទងដោយផ្ទាល់ទៅនឹងការជម្លៀសលើកទី២នេះទេ"។ មនុស្សស្លាប់រាប់ពាន់នាក់ គឺជាច្រើនសន្ធឹកសន្ធាប់ណាស់។ មេធាវីការពារក្តីរបស់ នួន ជា មិនបានជំទាស់ទៅនឹងលោក ពិន យ៉ាថៃ ទេ នៅពេលដែលគាត់បាននិយាយថា មនុស្សរាប់ពាន់នាក់បានស្លាប់ក្នុងអំឡុងពេលនៃការជម្លៀសដោយបង្ខំនេះ។ មេធាវីការពារក្តីមិនបាននិយាយថាសាក្សីបាននិយាយខុស ឬមិនមានមនុស្សស្លាប់នោះទេ។ ជាថ្មីម្តងទៀត សូមបញ្ជាក់ថាការព្យាយាមធ្វើការអះអាងរបស់មេធាវីការពារក្តីពុំមានន័យអ្វីទាំងអស់ នៅពេលដែលពួកគាត់មិនបានជំទាស់តវ៉ាទៅនឹងភស្តុតាងនៃការស្លាប់នៅក្នុងទ្រង់ទ្រាយធំបែបនោះ។

[០៩:២៧:៣០]

ប្រជាជនត្រូវបានគេបង្ខិតបង្ខំចាកចេញ និងសម្លាប់ចោល ប្រសិនបើពួកគេមិនអនុវត្តតាមទេ។ លោកស្រី សូផាន់ សូវណ្ណី បានផ្តល់សក្ខីកម្មថា៖ "គេបានរុញយើងចូលនៅក្នុងទូរទេះភ្លើង នៅពេលពេញគេបិទទ្វារដោយខ្ទាស់នឹងរនុកឈើ"។ សាក្សីដទៃទៀតបង្ហាញភស្តុតាងថា ពួកគាត់ត្រូវបានយោធាខ្មែរក្រហមប្រដាប់ដោយអាវុធទាញទម្លាក់ចេញពីទូរថភ្លើង ហើយបង្ខំឲ្យឡើងជិះឡាន។ លោកស្រី យឹម សុវណ្ណ បានផ្តល់សក្ខីកម្មវិញថា៖ "យើងចង់សុំពួកគេនៅទីនេះ ប៉ុន្តែពួកគេបានប្រាប់ពួកយើងវិញថាគេមិនអនុញ្ញាតឲ្យយើងនៅទីនេះទេ។ បើយើងចង់នៅ ពួកគេនឹងស្នើឲ្យយើងទៅនៅក្នុងមន្ទីរសន្តិសុខលេខ១៥។ ដូច្នេះយើងត្រូវតែផ្លាស់ទីលំនៅឲ្យស្របតាមមាគ៌ារបស់បក្ស"។ លោកស្រី ទឹង សុខា បានផ្តល់សក្ខីកម្មថា មានករណីរត់គេចខ្លួនមួយចំនួនតូចអ្នកដែលលាក់ខ្លួនគេចពីការជម្លៀសនេះត្រូវបានគេសម្លាប់ចោល ដោយសារអង្គការបានរកឃើញថា ពួកគាត់កំពុងតែលាក់ខ្លួន"។

បើប្រៀបធៀបទៅនឹងការជម្លៀសប្រជាជនដែលនៅទីក្រុងភ្នំពេញ និងទីក្រុងដទៃទៀត ដោយបង្ខំ នៅក្នុងខែមេសា ឆ្នាំ១៩៧៥ ស្ថានភាពសម្រាប់ប្រជាជនដែលត្រូវបានគេជម្លៀសនៅលើកទី២ គឺមានភាពអមនុស្សធម៌ប្រហាក់ប្រហែលគ្នា និងបានបង្កឲ្យមានការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្តយ៉ាងខ្លាំងដល់ជនរងគ្រោះ។

[០៩:២៩:៣១]

ខ្ញុំបានលើកឡើងរួចមកហើយអំពីការស្លាប់ប្រជាជនរាប់ពាន់នាក់។ ជាញឹកញាប់ ការប្រព្រឹត្តមកលើបុគ្គលទាំងឡាយគឺមានភាពឃោរឃៅ សូម្បីតែកុមារក្តី។ នៅក្នុងឆ្នាំ១៩៧៦ ដែលមានឯកសារ E3/4656 អ្នកស្រី ឌី រឿន ត្រូវបានគេជម្លៀសដោយបង្ខំជាមួយនឹងកូនៗរបស់គាត់ពីស្រុកស្អាងខេត្ត

កណ្ដាលឆ្ពោះទៅកាន់ខេត្តពោធិ៍សាត់តាមរថភ្លើង។ នេះគឺជាអ្វីដែលលោកស្រីបានឃើញ៖ "ខ្ញុំបានធ្វើដំណើរតាមរទេះភ្លើងឆ្ពោះទៅកាន់ខេត្តពិធិ៍សាត់ជាមួយនឹងកូនៗខ្ញុំ។ មានប្រជាជនជាច្រើននៅលើទូរថភ្លើង។ ខ្ញុំមិនដឹងថាពួកគាត់មកពីណានោះទេ។ កូនក្មេងខ្លះបានវង្វេងម្ដាយរបស់គេ ហើយស្រែកយំឥតឈប់។ មេក្រុមបានបោះក្មេងៗទាំងនោះចេញតាមបង្អួចរទេះភ្លើង។ ឃើញបែបនេះ ខ្ញុំឱបកូនៗរបស់ខ្ញុំជាប់នឹងទ្រូងខ្ញុំ។ ទិដ្ឋភាពគួរឲ្យភ័យខ្លាចមែនទែន"។ លោកស្រី អោ រី បានរៀបរាប់អំពីរបៀបថា៖ "សូម្បីតែមនុស្សឈឺ ក៏មិនត្រូវបានលើកលែងនៅក្នុងការជម្លៀសដោយបង្ខំនេះដែរ។ ខ្ញុំបានកត់សម្គាល់ឃើញមានអ្នកជំងឺជាច្រើនត្រូវបានគេជម្លៀសដោយបង្ខំ សូម្បីតែបងខ្ញុំគ្រាមករហូត។ ទោះបីជាយើង ឬប្រជាជនដែលឈឺធ្ងន់ ឈឺយ៉ាងម៉េចក៏ដោយ ក៏គ្មានអ្នកណាមើលដែរ មានតែគេបង្ខំឲ្យទៅឲ្យស្រូតៗ ឲ្យឆាប់ដល់គោលដៅ"។ លោក អួន ផល្លី បានផ្ដល់សក្ខីកម្មថា៖ "មុនពេលចេញដំណើរទៅកាន់ភូមិភាគពាយ័ព្យ កូនខ្ញុំយំស្រែកយ៉ាងខ្លាំងហើយ សូម្បីតែបាយនិងទឹកក៏អត់មាន ហើយប្រដាប់ប្រដា មុង កន្ទេល ឆ្នាំងចានក៏អត់ដែរ ឡើងទៅតែខ្លួន"។

[០៩:៣១:៥៣]

សាក្សីដែលត្រូវបានគេជម្លៀសពីភូមិភាគនិរតី និងភូមិភាគបូព៌ា បានធ្វើសក្ខីកម្មថា ពួកគេមិនត្រូវបានផ្ដល់អាហារ ឬទឹក នៅតាមផ្លូវទៅភូមិភាគពាយ័ព្យឡើយ។ សុវណ្ណ សុផានី បានផ្ដល់សក្ខីកម្មថា "ពេលយើងទៅដល់កន្លែងមានទឹក មិនថាទឹកស្អាតឬមិនស្អាត យើងផឹកទាំងអស់។ នៅពេលទៅដល់ប្រជាជនថ្មីដែលគេបានទុកនៅក្នុងព្រៃ និងទុកចោល -- ទុកឲ្យផ្គត់ផ្គង់ខ្លួនដោយខ្លួនឯង។ ពួកគេគ្មានបានផ្ដល់អ្វីទេ"។ អ្នកស្រី ទឹង សុខា បានផ្ដល់សក្ខីកម្មថា៖ "ដូច្នេះ ការចងចាំអំពីការលំបាកនៅក្នុងខេត្តបាត់ដំបង នៅតែដក់ជាប់ជាមួយខ្ញុំជានិច្ច ហើយខ្ញុំនៅនឹកឃើញ ខ្ញុំគ្មានអ្វីហូបសោះ ហើយខ្ញុំ ដោយសារខ្ញុំគ្មានអ្វីហូប ខ្ញុំត្រូវហូបសត្វម្រឹមព្រះ ជាសត្វមិនមែនគេញុំាទេ ហើយយើងបានផ្លាក់ខ្លួនលែងជាមនុស្សទៀតហើយ តែវាជាសត្វស្វាទៅវិញ។ យើងត្រូវញុំាស្លឹកឈើគ្រប់មុខ អ្វីដែលយើងអាចលូកដៃបេះបាន"។

លោក លោកស្រីចៅក្រម! ផែនការរបស់មជ្ឈិមបក្សដើម្បីបន្តការបង្ក្រាប ការគាបសង្កត់ និងការដាក់ទណ្ឌកម្មមកលើប្រជាជនថ្មី ពិតជាត្រូវធ្វើបានសម្រេចមែន។ ហើយជាបន្តទៀត សហការីរបស់ខ្ញុំ លោក វីវៀ្លម ស្មីត នឹងបង្ហាញជូនលោក លោកស្រីចៅក្រមអំពីការប្រព្រឹត្តដ៏ឃោរឃៅស្រដៀងគ្នានេះ មកលើប្រជាជនដែលជាប់ពាក់ព័ន្ធនឹងអតីតរបបសាធារណរដ្ឋខ្មែរ។

ចាស សូមអរគុណ ហើយនិងសូមឲ្យសហការីរបស់ខ្ញុំបន្តទៀត ចាស។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញ!

[០៩:៣៤:០៥]

**លោក វីណ្ឌៀម ស្មីត៖**

អរុណសួស្ដីលោកប្រធាន លោក លោកស្រីចៅក្រម ជាទីគោរព។ អរុណសួស្ដីដើមបណ្ដឹងរដ្ឋប្បវេណីដែលមានវត្តមាននៅទីនេះ ក្នុងថ្ងៃនេះ។

ដើមបណ្ដឹងរដ្ឋប្បវេណីមានសេចក្ដីក្លាហានណាស់ និងមានភាពរឹងប៉ឹងក្នុងការស្វែងរកយុត្តិធម៌សម្រាប់ខ្លួនឯង និងអ្នកដែលជាទីស្រឡាញ់ ដែលបាត់បង់ជីវិតក្នុងរយៈ៤០ឆ្នាំកន្លងទៅនេះ។

អរុណសួស្ដីភាគីទាំងអស់ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ក្រុមមេធាវីការពារក្ដី ក្រុមសហព្រះរាជអាជ្ញាដែលអង្គុយពីក្រោយយើងខ្ញុំ។ ភាគីគឺនៅទីនេះ ដើម្បីធ្វើយ៉ាងណាឲ្យយើងអនុវត្តទៅតាមវិធានច្បាប់ក្នុងប្រទេសកម្ពុជា។ ហើយក៏ខ្ញុំសូមសម្ដែងនូវអរុណសួស្ដី ចំពោះសាធារណជនដែលគាត់មានការចាប់អារម្មណ៍ថាធ្វើយ៉ាងណាឲ្យសង្គមនេះការពារសិទ្ធិមនុស្ស។ សិទ្ធិមនុស្សសម្រាប់ជនរងគ្រោះសិទ្ធិមនុស្សរបស់យើងគ្រប់ៗគ្នា និងសិទ្ធិរបស់ជនជាប់ចោទផងដែរ។

វត្តមានរបស់សាធារណជននៅថ្ងៃនេះមានសារៈសំខាន់ណាស់ ហើយវាមានសារៈសំខាន់ចំបាច់សម្រាប់ដំណើរការនេះ។ ហើយចំពោះអ្នកដែលកំពុងតែស្ដាប់សវនាការនេះតាមអ៊ីធឺណេតនោះ ខ្ញុំសូមសម្ដែងនូវការសួស្ដី ហើយពួកគេតាមដានដើម្បីធ្វើយ៉ាងឲ្យយុត្តិធម៌នេះត្រូវស្វែងរកឲ្យបាន។

[០៩:៣៥:៤៧]

លោកប្រធានជាទីគោរព! សហសេវិករបស់ខ្ញុំ លោកស្រី ជា លាង បានបង្ហាញជូនលោកចៅក្រមអំពីឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងដំណាក់កាលចំនួនពីរនៃការជម្លៀសដោយបង្ខំ។ ឧក្រិដ្ឋកម្មនេះកើតចេញពីផលនៃផែនការឧក្រិដ្ឋដែលមានការរៀបចំ និងគ្រោងឡើងយូរមកហើយដែលជាផែនការរបស់ នួន ជា និង ខៀវ សំផន រួមជាមួយនឹងសមាជិកផ្សេងទៀតនៃមជ្ឈិមបក្ស។

លោក លោកស្រីចៅក្រមជាទីគោរព! ហេតុការណ៍នេះ គឺដូចគ្នានឹងហេតុការណ៍នៅទួលពោធិ៍ជ្រៃដែលជាហេតុការណ៍ឧក្រិដ្ឋទី៣ និងចុងក្រោយខ្ញុំនឹងលើកឡើងជូនអង្គជំនុំជម្រះនៅក្នុងថ្ងៃនេះ។

លោក លោកស្រីចៅក្រម ប្រាកដជាយល់ច្បាស់ហើយថាការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃមិនកើតឡើងនោះទេ ប្រសិនបើមិនមានគោលនយោបាយបង្កើតឡើងយ៉ាងហ្មត់ចត់ដើម្បីធ្វើទុក្ខបុកម្នេញ

និងកាប់សម្លាប់អតីមន្ត្រីសាធារណរដ្ឋខ្មែរ រួមទាំងទាហាន និងប្រសិនបើគោលនយោបាយនេះពុំផ្សាយ ផ្សាយតាមរយៈរចនាសម្ព័ន្ធដែលមានការរៀបចំ និងប្រសិនបើពុំមានការលើកទឹកចិត្តយ៉ាងខ្លាំងខ្លាទៅដល់កងកម្លាំងមានវិន័យ និងស្មោះស្ម័គ្រដោយជនជាប់ចោទទាំងនេះនោះទេ គឺ នួន ជា និង ខៀវ សំផន និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត។

[០៩:៣៧:១៨]

នៅពេលនេះ ខ្ញុំនឹងលើកឡើងអំពីគោលនយោបាយនេះ ហើយនិងបង្ហាញអំពីភ័ស្តុតាងដែលគាំទ្រឧក្រិដ្ឋកម្មដែលកាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរទាំងនេះ រួមទាំងនៅពេលជម្លៀសទីក្រុងភ្នំពេញ និងការកាប់សម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។

លោក លោកស្រីចៅក្រមជាទីគោរព! ភស្តុតាងបានបង្ហាញយ៉ាងច្បាស់ថា ខ្មែរក្រហម និងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរធ្វើសង្គ្រាមប្រឈមមុខដាក់គ្នានៅក្នុងប្រទេសកម្ពុជានៅចន្លោះឆ្នាំ៧០ និង៧៥។ អ្នកទាំងពីរនេះ គឺជាសត្រូវ ឬនៅលើសមរភូមិ។ ឋានៈជាខ្មាំងនៃរដ្ឋាភិបាលលន់ នល់ មិនមែនកើតឡើងដោយសារអង្គហេតុនេះទេ គឺវាដោយសារតែបញ្ហាចាក់ឫសជ្រៅជាងនេះ។ វាពុំមែនឯកសណ្ឋានរបស់ទាហានដែលពួកគេស្លៀកពាក់នោះទេ ក៏ប៉ុន្តែគឺដោយសារតែទាហាននេះតំណាងឲ្យភាគីណា។ នៅក្នុងក្រសែភ្នែករបស់ នួន ជា, ខៀវ សំផន និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត ទាហានទាំងអស់នេះគឺតំណាងអោយរបបពុករលួយមួយ របបដែលមានទំនាស់ស្លាប់រស់។ ទំនាស់នេះទាមទារឲ្យមានការដោះស្រាយ តើគេដោះស្រាយទំនាស់នេះដោយរបៀបណាទៅ? ភស្តុតាងមានច្រើនណាស់ដែលបង្ហាញអំពីដំណោះស្រាយនេះ។ ដំណោះស្រាយទៅលើទំនាស់ទាំងនេះ គឺធ្វើឡើងតាមរយៈគោលនយោបាយនៃការធ្វើទុក្ខបុកម្នេញ និងការធ្វើមនុស្សឃាត។ គោលនយោបាយនេះត្រូវបានបង្កើតឡើងយ៉ាងហ្មត់ចត់នៅពេលភ្នំពេញដួលរលំ ហើយមន្ត្រីសាធារណរដ្ឋខ្មែរ និងទាហានត្រូវបានគេសម្លាប់ជាឈុតនៅទួលពោធិ៍ជ្រៃ។ គោលនយោបាយក្នុងការធ្វើទុក្ខបុកម្នេញ និងការកាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរពីមុន និងយោធា និងជនស៊ីវិល ឃើញមាននៅទូទាំងប្រទេស និងឃើញមាននៅក្នុងរយៈពេល ៣ឆ្នាំ ៨ខែ ដែលបក្សកុម្មុយនីស្តកម្ពុជាកាន់កាប់អំណាច។ គោលនយោបាយនេះតម្រូវឲ្យមានការកំណត់អត្តសញ្ញាណ ការបំបែក ការកំណត់គោលដៅ និងការកាប់សម្លាប់មន្ត្រីទាំងនេះជាលក្ខណៈប្រព័ន្ធ។

[០៩:៣៩:៣៧]

សហសេវិករបស់ខ្ញុំ លោកស្រី ជា លាង បានអះអាងរួចមកហើយថា ភស្តុតាងបង្ហាញឲ្យយើង

ឃើញថានៅក្នុងឆ្នាំ១៩៧៣ បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមកែទម្រង់គោលនយោបាយរបស់ខ្លួនឱ្យកាន់តែហួសហេតុ និងកាន់តែចាប់បង្ខំនៅក្នុងការព្រឹត្តទៅលើខ្មាំងដែលធ្លាក់ក្នុងកណ្តាប់ដៃរបស់បក្សនេះ។

នៅក្នុងពេលនោះមន្ទីរសន្តិសុខម-១៣ គឺជាភស្តុតាងបង្ហាញច្បាស់មួយអំពីគោលនយោបាយផ្តាច់ការនេះ។ ឌុច ដែលជាប្រធានមន្ទីរម-១៣ បានគោរពតាមបញ្ជាហើយបានកាប់សម្លាប់ទាហានលន់ នល់ និងព្រះសង្ឃដែលចាប់ខ្លួនបាននៅមន្ទីរសន្តិសុខនោះ។ ក្នុងនាមជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាស្មោះស្ម័គ្រមួយរូបនិងជាគ្រូបង្រៀនគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា កាំង ហ្គេកអ៊ាវ (ឌុច) បានផ្តល់សក្ខីកម្មនៅចំពោះមុខលោក លោកស្រី ចៅក្រមថា៖ “ទស្សនាវដ្តីទង់បដិវត្តន៍ឆ្នាំ(១៩)៧៣ បានផ្សព្វផ្សាយអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីការធ្វើចំណាត់ថ្នាក់ទៅលើខ្មាំង”។ យោងតាមគោលនយោបាយនេះ ទាហាន ប៉ូលិស ត្រូវបានគេចាត់ថ្នាក់ជាប្រភេទខ្មាំងពិសេស។

នៅក្នុងតុលាការ ស្ទីវហ្វិន ហេដឌ័រ *(Stephen Heder)* បានបញ្ជាក់ទៅលើអត្ថបទមួយដែលគាត់បានបោះពុម្ពផ្សាយស្តីអំពីអត្ថិភាពនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានេះក្នុងការលុបចោលវណ្ណៈខ្មាំងពិសេសនេះ។ ខ្ញុំសូមលើកការដកស្រង់៖ “សមាជិកទាំងឡាយ ដែលការវិភាគវណ្ណៈជាផ្លូវការដោយបក្សកុម្មុយនីស្តកម្ពុជាបានកំណត់ថាជាប្រភេទវណ្ណៈពិសេស ឬប្រភេទដោយឡែកនោះ ត្រូវបានលុបបំបាត់ចោលដើម្បីបញ្ចូលជាមួយវណ្ណៈកម្មករ កសិករ ដើម្បីជាផ្នែកមួយនៃការជីកឫសគល់បដិវត្តន៍សង្គមនិយម។ ប្រភេទវណ្ណៈពិសេសនេះពុំស៊ីសង្វាក់នឹងវណ្ណៈធំៗដូចជាសក្តិភូមិ គហបតី អនុធន កសិករ និងកម្មករ។ ក្រៅពីបញ្ញាជនប្រភេទវណ្ណៈផ្សេងទៀតនេះ រួមមាន ទាហាន និងប៉ូលិសនៅសម័យសាធារណរដ្ឋ ព្រះសង្ឃ និងគ្រប់ជាតិទាំងអស់”។ សូមបញ្ចប់ការដកស្រង់។

[០៩:៤១:៥៨]

មាគ៌ាបក្សដែលកំណត់ប្រភេទខ្មាំងពិសេស គឺបានកត់ត្រា ទុកនៅក្នុងសៀវភៅកំណត់ត្រារបស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាមួយរូបដែលគាត់បានចូលរួមនៅក្នុងវគ្គអប់រំបក្ស។ គាត់បានកត់ត្រាទុកនូវការណែនាំពីបក្សអំពីប្រភេទពិសេសដែលចាត់ទុកថាជាប្រតិកិរិយាដាច់ខាត។ ខ្ញុំសូមដកស្រង់៖ “ក្នុងនោះមានព្រះសង្ឃ បញ្ញាជន ប៉ូលិស ទាហាន និងបណ្តាជនជាតិ”។

លោក លោកស្រី ចៅក្រមជាទីគោរព! គោលនយោបាយក្នុងការកាប់សម្លាប់នាយយោធាសាធារណរដ្ឋខ្មែរ និងមន្ត្រីទាំនាគីជា គឺកើតចេញពីការពង្រីកគោលនយោបាយរបស់ខ្មែរក្រហមដែលមានជាយូរមកហើយដើម្បីកាប់សម្លាប់មន្ត្រីជាន់ខ្ពស់បំផុតនៅក្នុងរបបសាធារណរដ្ឋខ្មែរ។ នៅដើមឆ្នាំ១៩៧២

ក្នុងទស្សនាវដ្ដីទង់បដិវត្ត ខែកញ្ញា និងខែតុលា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់មេដឹកនាំសាធារណរដ្ឋខ្មែរពីររូបគឺ ប្រធានាធិបតី លន់ នល់ និងទ្រង់ សិរិមតៈ ថាជាជនក្បត់ដែលត្រូវកម្ទេចចោលជាដាច់ខាត។ ជួរដឹកនាំបក្សកុម្មុយនីស្តកម្ពុជារួមទាំង នួន ជា និង ខៀវ សំផន បានប្ដេជ្ញាមិនឈប់ឈរនៅក្នុងការកម្ទេចខ្មាំង និងជនក្បត់ និងបុគ្គលផ្សេងទៀតនៅចន្លោះឆ្នាំ១៩៧០ និងខែមេសា ឆ្នាំ១៩៧៥ ពួកគេបានចេញនូវសេចក្ដីថ្លែងការណ៍ជាច្រើនអំពាវនាវ និងលើកសរសើរចំពោះការកាប់សម្លាប់ទាហានសាធា-រណរដ្ឋខ្មែរ។ នៅថ្ងៃទី២៤ និង២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ ប្រាំមួយសប្ដាហ៍មុនពេលបក្សកុម្មុយនីស្តកម្ពុជាបានជម្លៀសទីក្រុងភ្នំពេញ ខៀវ សំផន បានផ្សព្វផ្សាយតាមវិទ្យុនូវសេចក្ដីសម្រេចរបស់សន្និបាតជាតិលើកទី២, ខ្ញុំសូមដកស្រង់៖ “ចាំបាច់ដាច់ខាតត្រូវសម្លាប់មេដឹកនាំ៧រូបរបស់របបសាធារណរដ្ឋខ្មែរ”។

[០៩:៤៩:០៥]

លោក លោកស្រីចៅក្រមជាទីគោរព! ភស្តុតាងនេះ ពុំត្រូវបានតវ៉ាឡើយ។ ខៀវ សំផន មិនដែលធ្លាប់បដិសេធថាគាត់មិនធ្លាប់បានចេញការផ្សព្វផ្សាយនេះទេ។ នេះគឺជាការបញ្ជាក់យ៉ាងច្បាស់អំពីពិរុទ្ធភាពរបស់គាត់ និងការទទួលខុសត្រូវរបស់គាត់ចំពោះការកាប់សម្លាប់នេះ។ នៅក្នុងការផ្សព្វផ្សាយដូចគ្នានេះដែរ គឺនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ ខៀវ សំផន បានធ្វើការគំរាមកំហែងទៅដល់យោធា និងមន្ត្រីសាធារណរដ្ឋខ្មែរថា, ខ្ញុំសូមដកស្រង់៖ “មន្ត្រីរដ្ឋាភិបាលថ្នាក់ទាប និងថ្នាក់ខ្ពស់ទាំងឡាយ នាយទាហាន នាយប៉ូលិស មន្ត្រី អ្នកនយោបាយ អនុញ្ញាតឲ្យចូលរួមជាមួយនឹងរណសិរ្សរួបរួមជាតិកម្ពុជា ដរាបណាពួកគេបានបញ្ឈប់បម្រើជនក្បត់ទាំងប្រាំពីរ និងឈប់សហការជាមួយពួកវា។

តើយើងជឿ -- តើឲ្យអ្នកណាជឿជាក់ទៅថា ប្រសិនបើខ្មែរមិនមន្ត្រីសាធារណរដ្ឋខ្មែរបានចូលរួម -- បានចុះចូលជាមួយនឹង ខៀវ សំផន, នួន ជា ក្នុងពេលដែលអ្នកទាំងពីរនេះធ្វើការជាមួយនឹង ប៉ុល ពត ដើម្បីធ្វើការវាយសម្រុកចុងក្រោយលើទីក្រុងភ្នំពេញ អ្នកមន្ត្រីទាំងអស់នេះនឹងត្រូវបានគេអញ្ជើញឲ្យចូលរួមជាមួយនឹងជួរបក្សកុម្មុយនីស្តកម្ពុជាយ៉ាងម៉េចទៅ? គឺមិនដូច្នោះទេ ពួកគេប្រាកដជាត្រូវចាប់ខ្លួនយកទៅសម្លាប់ចោល។

លោក លោកស្រីចៅក្រមបានស្ដាប់រួចមកហើយថា នាយករដ្ឋមន្ត្រី ឡុង បូរ៉េត និង ទ្រង់ សិរិមតៈ ជនក្បត់ពីររូបដែល ខៀវ សំផន អំពាវនាវឲ្យកាប់សម្លាប់នោះ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្រោយពេលដែលចុះចូលជាមួយនឹងរដ្ឋាភិបាលខ្មែរ។ អ្នកទាំងពីរត្រូវបានចាប់ខ្លួន និងសម្លាប់ចោលរួមជាមួយនឹងនាយទាហាន និងមន្ត្រីសាធារណរដ្ឋខ្មែរផ្សេងទៀត។

[០៩:៤៦:០១]

នួន ជា បានបញ្ជាក់ថា -- នួន ជា បានបញ្ជាក់ប្រាប់ ថេត សម្បត្តិ ក្នុងឆ្នាំ២០០៧ ថា៖ "បក្សកុម្មុយនីស្តកម្ពុជាបានបញ្ជាឲ្យសម្លាប់ជួរដឹកនាំសាធារណរដ្ឋខ្មែរ"។ ថេត សម្បត្តិ គឺជាអ្នកនិពន្ធ -- គឺជាអ្នកកាសែតដ៏គួរឲ្យជឿទុកចិត្តម្នាក់។ នេះជាអ្វីដែលគាត់បានលើកឡើង៖

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ស៖ បាទ អាហ្នឹងវាយ៉ាងម៉េចបាទ គោលនយោបាយបាទ? ឆ៖ គោលនយោបាយគឺកម្ទេច។ និយាយពាក្យងាយៗកម្ទេច។ ព្រោះពួកនេះវាទោសធ្ងន់ណាស់លក់ប្រទេសជាតិ គឺបរិវារគេ។ អាហ្នឹងមានប៉ុណ្ណឹងបាទ"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[០៩:៤៦:៤៧]

**លោក វីល្លៀម ស្មីត៖**

លោក លោកស្រីចៅក្រមជាទីគោរព! គ្មានអ្វីសង្ស័យនោះទេ។ នួន ជា បានទទួលស្គាល់អំពីការធ្វើមនុស្សឃាត ការធ្វើមនុស្សឃាតដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ការទទួលស្គាល់នេះធ្វើឡើងដោយគ្មានសម្ពាធ ដោយម៉ឺងម៉ាត់ ដោយប្រាកដប្រជា គ្មានការសោកស្ដាយ និងដោយគ្មានវិប្បដិសារី។ វាបង្ហាញយ៉ាងច្បាស់តាមរយៈសេចក្ដីថ្លែងការណ៍ និងចម្លើយរបស់ នួន ជា ថា នួន ជា នៅតែជឿជាក់ថា ការកាប់សម្លាប់នៅក្រៅប្រព័ន្ធតុលាការក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានហេតុផលត្រឹមត្រូវ ហើយចាំបាច់ត្រូវធ្វើឡើង។

អៀង សារី ដែលជាសមាជិកអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា និងជាអ្នកធ្វើការងារជាមួយនឹង នួន ជា ក៏បានទទួលស្គាល់ថា "បញ្ជាឲ្យកាប់សម្លាប់មន្ត្រី លន់ នល់ គឺចេញមកពីមេដឹកនាំមជ្ឈិមបក្ស ហើយទំហំនៃការ -- ទំហំនៃបញ្ជាកាប់សម្លាប់នោះមិនមែនកម្រិតត្រឹមតែជួរដឹកនាំសាធារណរដ្ឋខ្មែរប៉ុណ្ណោះនោះទេ"។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយនឹង ស្ទីវហ្វិន ហេដឌ័រ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ អៀង សារី បានទទួលស្គាល់ថា៖ "បញ្ជាឲ្យកាប់សម្លាប់មន្ត្រី លន់ នល់ បានពង្រីករហូតរួមបញ្ចូលអ្នករដ្ឋការថ្នាក់ទាប និងកម្មាភិបាលយោធា"។ ឆ្លើយតបទៅនឹងសំណួររបស់ ហេដឌ័រ ដែលយោងលើឯកសារមួយដែលបង្ហាញច្បាស់ថា អ្នកដែលត្រូវសម្លាប់រួមមាន នាយទាហាន មន្ត្រីជាន់ខ្ពស់ និងភ្នាក់ងារសម្ងាត់។ អៀង សារី បានបញ្ជាក់ថា -- ជួរដឹកនាំបក្សកុម្មុយនីស្តកម្ពុជា -- សូមដកស្រង់៖

"បានសម្រេចធ្វើអ្វីគ្រប់យ៉ាងដើម្បីកុំឲ្យក្រុមនេះអាចក្រោកឡើងប្រឆាំងនឹងបដិវត្តន៍"។

[០៩:៤៨:៥១]

អៀង សារី បាននិយាយថា ខ្ញុំសូមដកស្រង់៖ "សេចក្ដីសម្រេចនេះមិនមែនធ្វើឡើងជាមុននោះទេ វាសម្រេចនាពេលក្រោយមកតែប៉ុណ្ណោះ"។ តាមខ្ញុំដឹងគឺក្រោយថ្ងៃ១៧ មេសា ប្រហែលជាថ្ងៃទី២០ តាមខ្ញុំដឹង។ មានន័យថា ពួកគេសម្រេចធ្វើអ្វីគ្រប់បែបយ៉ាង ដើម្បីកុំឲ្យក្រុមនោះអាចក្រោកឈរឡើងប្រឆាំងនឹងបដិវត្តន៍។ តាមអ្វីដែលគេប្រាប់ខ្ញុំ ក្រុមនោះមានផែនការក្រោយពេលដែលពួកគេចាញ់ គឺផែនការកាប់សម្លាប់ខ្មែរក្រហម ក្រោយពេលពួកគេចូលទីក្រុង និងចាប់យកអំណាចវិញ។ ខ្ញុំបានសួរបន្ថែមទៀត ហើយគេសរសេរថា៖ "នៅពេលដែល -- គេបាននិយាយថា នៅពេលដែលពួកគេឆែកឆេរផ្ទះរបស់នាយយោធាទាំងអស់នោះ ពួកគេឃើញគ្រាប់បែកដៃ និងអាវុធគ្រប់ប្រភេទ។ ដូច្នេះពួកគេត្រៀមខ្លួនធ្វើរដ្ឋប្រហារ។ ដូច្នេះពួកគេធ្វើការជម្លៀសក្រោយពីឃើញចំណុចនេះច្បាស់ ពួកគេបានធ្វើសេចក្ដីសម្រេច"។

សេចក្ដីប្រកាសរបស់ អៀង សារី បង្ហាញអំពីអត្ថិភាពនៃគោលនយោបាយក្នុងការកំណត់គោលដៅ និងកាប់សម្លាប់ទាហានថ្នាក់ទាប និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងអំឡុងពេលជម្លៀសទីក្រុងភ្នំពេញ។ ហើយ អៀង សារី បានពន្យល់នូវហេតុផលនៅពីក្រោយការសម្លាប់ដែលត្រូវបានរៀបចំជាឈុតលើទាហានសាធារណរដ្ឋខ្មែរ និងមន្ត្រីទាំងនោះដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលតែប៉ុន្មានថ្ងៃ និងប៉ុន្មានសប្ដាហ៍តែប៉ុណ្ណោះក្រោយខែមេសា ឆ្នាំ១៩៧៥ គឺថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។ ការសម្លាប់ទាំងនេះកើតឡើងក្នុងមធ្យោបាយ និងវិធីស្រដៀងគ្នានៅតាមទីតាំងភូមិសាស្ត្រធំៗ និងក្នុងចំនួនដូចគ្នា និងស្របជាមួយនឹងគោលនយោបាយមុនៗរបស់បក្សកុម្មុយនីស្ដកម្ពុជាចំពោះមន្ត្រី និងទាហានសាធារណរដ្ឋខ្មែរ។ ដូច្នេះការកាប់សម្លាប់ទាំងនេះអាចធ្វើឡើងក្រោមការបញ្ជា និងការឯកភាពគោលនយោបាយណែនាំរបស់មជ្ឈិមបក្សកុម្មុយនីស្ដកម្ពុជា។

[០៩:៥១:១១]

ខ្ញុំនឹងលើកឡើងអំពីការសម្លាប់អតីតមន្ត្រីសាធារណរដ្ឋខ្មែរនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ជាពីរក្រុម។ ក្រុមទី១ គឺមន្ត្រីទាំងឡាយដែលត្រូវបានគេសម្លាប់នៅក្នុងទីក្រុងភ្នំពេញនៅក្នុងពេលជម្លៀស នៅក្នុងពេលធ្វើដំណើរ ឬនៅពេលទៅដល់គោលដៅថ្មីរបស់ពួកគេ ក្រោយពេលពួកគេត្រូវបានបង្ខំចេញពីទីក្រុងភ្នំពេញ។ បន្ទាប់មកក្រុមទី២ ខ្ញុំនឹងលើកឡើងអំពីការសម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរនៅក្រៅទីក្រុង

ភ្នំពេញ ហើយនិងអ្នកដែលមិនមែនជាកម្មវត្ថុនៃការបញ្ជូនដោយការបង្ខំពីក្រុងភ្នំពេញ។

យោងតាមជំហររបស់សហព្រះរាជអាជ្ញា ការកាប់សម្លាប់ក្រុមទាំងពីរប្រភេទនេះបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយក្នុងការកាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរ ចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។ ការកាប់សម្លាប់ក្រុមទាំងពីរនេះ បានកើតឡើងក្នុងពេលជម្លៀសប្រជាជនដោយបង្ខំពីទីក្រុងភ្នំពេញ ដែលអ្នកទាំងនេះគឺជាបុគ្គលិកសាធារណរដ្ឋខ្មែរ។ ការកាប់សម្លាប់ទាំងនេះ គឺជាផ្នែកនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជនជាប់ចោទកំពុងតែប្រឈមនឹងការជំនុំជម្រះ។

[០៩:៥២:៣០]

ទោះបីជាបក្សកុម្មុយនីស្តកម្ពុជាទទួលជ័យជម្នះលើកម្លាំងសាធារណរដ្ឋខ្មែរនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ក៏ដោយ យើងពុំឃើញមានការទប់ស្កាត់បំណង និងការសម្រេចចិត្តរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក្នុងការកាប់សម្លាប់នោះទេ។ តែ ពក លេខាភូមិភាគកណ្តាលសារភាពប្រាប់ ស្ទីវហ្វិន ហេដឌ័រ ថា “ការសម្លាប់ចាំបាច់ត្រូវធ្វើឡើងជាផ្នែកមួយនៃការវាយប្រហារទៅលើរបបសង្គមចាស”។

ការចុះចាញ់របស់មន្ត្រីសាធារណរដ្ឋខ្មែរ និងទាហាន ពុំមែនបានបញ្ឈប់គោលនយោបាយ និងបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកាប់សម្លាប់ក្រុមនេះទេ។ នៅក្នុងទីក្រុងភ្នំពេញ រួមទាំងទីរួមខេត្តផ្សេងទៀត កងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាបានស្វែងរកកំណត់អត្តសញ្ញាណ បំបែក ឃុំឃាំង និងកាប់សម្លាប់អតីតមន្ត្រី នាយយោធា និងក្រុមគ្រួសាររបស់គេជាលក្ខណៈប្រព័ន្ធ។ ការអនុវត្តគោលនយោបាយនេះ អាចឃើញធ្វើឡើងខ្លាំងនៅពេលបំបែក និងកំណត់ថ្នាក់មន្ត្រីសាធារណរដ្ឋខ្មែរ ដែលកើតឡើងនៅទីស្តីការក្រសួងព័ត៌មានក្នុងទីក្រុងភ្នំពេញ វេលាម៉ោងបួនរសៀលនាថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។

[០៩:៥៣:៥៤]

ហេតុការណ៍នេះ ហេតុការណ៍គួរឲ្យអស់សង្ឃឹមនេះ បានបង្ហាញតាមរយៈរូបថត ដែលលោកលោកស្រីចៅក្រមនឹងពិនិត្យមើលឃើញ ថតឡើងដោយ អាល់ រ៉ុក្កូហ្វ។ អាល់ រ៉ុក្កូហ្វ មានវត្តមាននៅក្នុងទីក្រុងភ្នំពេញនាពេលនោះ។ រូបថតនេះបង្ហាញឲ្យឃើញនូវជោគវាសនារបស់មន្ត្រីសាធារណរដ្ឋខ្មែរជាច្រើន នៅក្នុងពេល និងក្រោយពេលជម្លៀសទីក្រុងភ្នំពេញ។ នៅកន្លែងពីរផ្សេងទៀតនៅក្នុងក្រុងភ្នំពេញ នៅស្ពានជ្រោយចង្វា និងជិតព្រះបរមរាជវាំង ទាហានខ្មែរក្រហមនៅភូមិភាគឧត្តរមួយរូបបានឆ្លើយនៅក្នុងឯកសារ E3/5149 បានរាបរៀបអំពីការសម្លាប់ទាហាន លន់ នល់ ដែលគាត់បានឃើញ។ ខ្ញុំសូមដកស្រង់៖ “ខ្ញុំបានចូលពេលថ្ងៃរំដោះ ១៧ មេសា ១៩៧៥ ខ្ញុំចូលទីក្រុងភ្នំពេញជាមួយទាហាន

កងពលទាំងអស់។ គេឲ្យខ្ញុំទៅយាមនៅវត្តភ្នំ ការពារសន្តិសុខ។ ពេលហ្នឹងគឺឈប់រើហើយ ប៉ុន្តែកន្លែងខ្លះមានទាហានពួននៅតាមផ្ទះថ្មដើម្បីតស៊ូ។ ដូច្នេះ គេបានបិទទីក្រុង ហើយនិងបិទទឹកចំនួនមួយខែ។ ពួកទាហានទាំងនោះក៏បានចេញមក។ ខ្ញុំបានឃើញគេសម្លាប់ទាហានចុះចូលទាំងនោះ នៅស្ពានជ្រោយចង្វា។ ទាហានទាំងនោះ មានបួន-ដប់នាក់ ខ្លះដាច់ដៃ ខ្លះដាច់ជើង ត្រូវគេច្រានទម្លាក់ទឹកតែម្តង។ ម្យ៉ាងទៀត ខ្ញុំបានឃើញផ្ទាល់ភ្នែក ឈ្មោះ រុំ ដែលជាប្រធានកងពល កងធំ នៅក្នុងកងពល៣១០ បាញ់ទាហានលន់ នល់ បីនាក់សក់វែង នៅកន្លែងផែមុខវាំង។ ខ្ញុំបានឃើញគេចាប់កម្មករធ្វើខ្សែភ្លើង ដែលគេយកទុកប្រើ យកទៅសម្លាប់។ តែគេប្រាប់ថាយកទៅបាត់ដំបងទេ។ ខ្ញុំបានដឹងថាគេសម្លាប់ពួកនោះដោយសារឈ្មោះ ហេង ជាប្រធានកងតូចបានប្រាប់ខ្ញុំ។ គាត់ថា គេសម្លាប់ពួកទាំងអស់ហ្នឹង នៅទួលអូញម៉ូញ។ នៅក្នុងកងពលខ្ញុំក៏មានគេចាប់ច្រើនដែរ"។ សូមបញ្ចប់ការដកស្រង់។

[០៩:៥៦:១៩]

ទាហានខ្មែរក្រហមមួយរូបទៀត បានផ្តល់ចម្លើយនៅក្នុងឯកសារលេខ E3/5540 ប្រាប់អ្នកស៊ើបអង្កេត អ.វ.ត.ក ថា៖ "នៅពេលដែលគាត់ចូលទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ មេសា ការងាររបស់គាត់យាមជនស៊ីវិលកុំឲ្យលាយឡំជាមួយនឹងទាហានលន់នល់ និងគេឲ្យគាត់ស្វែងរកទាហានលន់នល់ ដែលកំពុងលាក់ខ្លួនជាមួយជនស៊ីវិល។ បញ្ជាដែលគាត់ទទួលបាន គឺខ្លីៗ ម៉ាត់ៗ និងសាមញ្ញ។ ប្រសិនបើយើងរកឃើញទាហានលន់ នល់ យើងនឹងសម្លាប់ពួកគេតែម្តង"។

ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ បានសម្ភាសជនភៀសខ្លួនរាប់រយនាក់ដែលបានរត់ចេញពីប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៥។ កិច្ចសម្ភាសន៍ទាំងនេះ ត្រូវបានប្រើប្រាស់យកទៅបោះផ្សាយនៅក្នុងសៀវភៅរបស់គាត់ ចំណងជើងថា "កម្ពុជាឆ្នាំសូន្យ"។ គាត់បាននិយាយជាមួយនឹងសាក្សីទាំងនេះ ហើយបានទទួលសក្ខីកម្មផ្ទាល់។ លោកបានពិនិត្យផ្ទៀងផ្ទាត់ និងបានបញ្ជាក់អំពីការហេតុការណ៍កើតឡើងលើពួកគេនៅក្នុងរយៈពេលប៉ុន្មានថ្ងៃ ឬខែ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ៧៥។ រឿងរ៉ាវរបស់ពួកគេនៅកៀកនឹងហេតុការណ៍ដែលពួកគេបានរៀបរាប់។ ផ្អែកតាមបទពិសោធន៍ និងបទពិសោធន៍របស់អ្នកជនភៀសខ្លួនដែលគាត់បានសម្ភាស ប៉ុងសូដ៍ បានផ្តល់សក្ខីកម្មថា៖"កងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាមានបំណងកម្ទេចប្រជាជនទាំងអស់ដែលបម្រើការងារឲ្យរបប លន់ នល់ ដែលពួកគាត់ត្រូវបានចាត់ទុកថា ជាពួកក្បត់"។

[០៩:៥៨:០២]

ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ នៅក្នុងសៀវភៅរបស់គាត់ គឺបានប្រើ -- ខ្ញុំសូមប្រើឈ្មោះរហស្សនាម

ដែលគាត់បានសម្ភាសជាមួយនឹងអ្នកជនភៀសខ្លួននោះ “ឃូ គឹមឡាយ គាត់បានរៀបរាប់នូវអ្វីដែលបានកើតឡើងលើមន្ត្រីសាធារណរដ្ឋខ្មែរ ដែលបានប្រឡប់មកទីក្រុងភ្នំពេញ ក្រោយពេលប្រកាសធ្វើឡើងនៅព្រែកព្នៅ ប្រហែល១៦គីឡូម៉ែត្រខាងជើងទីក្រុងភ្នំពេញ” នេះជាអ្វីដែលគាត់បាននិយាយ ប៉ុងស្វង៍។ “នៅព្រែកព្នៅរថយន្តមួយគ្រឿងប្រកាសតាមមីក្រូ អញ្ជើញទាហាន មន្ត្រីរដ្ឋការ រដ្ឋមន្ត្រី តំណាងរាស្ត្រ អ្នកបច្ចេកទេសទាំងអស់ ចូលក្នុងក្រុងភ្នំពេញវិញ ដើម្បីធ្វើការជាមួយអង្គការ។ ខ្ញុំបានចូលទៅជាមួយអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនអគ្គីសនីកម្ពុជា។ គេនាំយើងទៅកាន់ទីស្ដីការក្រសួងឃោសនាការ។ នៅទីនោះ យើងត្រូវសរសេរប្រវត្តិរូបរបស់យើង ក្រោយមកគេបញ្ជូនយើងទៅសណ្ឋាគារមនោរម្យ ដែលជាទីតាំងកងទ័ពពិសេសរបស់ខ្មែរក្រហម។ នៅពេលខ្ញុំសណ្ឋាគារមនោរម្យនោះ ខ្ញុំបានឃើញនាយទាហានរបស់ លន់ នល់ ជាង២០០នាក់មកដល់។ នៅយប់នោះ គេនាំយកនាយទាហានទាំងនោះ ទៅកាន់កន្លែងមួយដែលគ្មាននរណាដឹង។ រៀងរាល់ថ្ងៃ ខ្មែរក្រហមនាំមនុស្សមកកាន់ទីនេះ ជាង១០០នាក់ ភាគច្រើនជានាយទាហាន។ នៅក្នុងចំណោមនោះ ខ្ញុំស្គាល់ឧត្ដមសេនីយ៍ អ៊ំ រ៉ុង អតីតអ្នកនាំពាក្យយោធារបស់រដ្ឋាភិបាល។ វរសេនីយ៍ឯក លី តិច, លោក ទេព ឈៀវខេង អតីតរដ្ឋមន្ត្រីក្រសួងឃោសនាការ និងជាអតីតនិពន្ធនាយកកាសែត “ឌឺផាស ឌុយខាំបូដស៍”។ ពួកគេបាត់ខ្លួនម្ដងៗម្នាក់ច្រើន នៅពេលយប់។ ក្នុងចំណោមខ្មែរក្រហមនៅសណ្ឋាគារមនោរម្យ ខ្ញុំស្គាល់ម្នាក់ឈ្មោះ មិត្ត ហុក ជាក្មួយរបស់លោក ទូច គីម អតីតទេសាភិបាលធនាគារជាតិ ព្រមទាំងមិត្តសុន ជាមេបញ្ជាការកងពលតូចនៃទ័ពពិសេសផង។ ខ្ញុំសួរគាត់ អ្នកណាចាកចេញពីសណ្ឋាគារមនោរម្យទាំងប៉ុន្មានទៅណា? ហេតុអ្វីបានជាមិនឃើញគេត្រឡប់មកវិញ? គាត់ឆ្លើយថា៖ យើងបាញ់សម្លាប់គេចោលទាំងអស់ព្រោះសុទ្ធតែក្បត់។ ដោយឃើញទាហានសម្លាប់ទាហាន ខ្មែរក្រហមដែលឈឺពិការ ដែលសម្រាកនៅមន្ទីរពេទ្យព្យាបាលព្រះមុន្នីវង្ស ផ្ទាល់នឹងភ្នែក ខ្ញុំជឿថាហេតុការណ៍នេះជាការពិត”។

[១០:០០:៣៨]

យើងឃើញនៅក្នុងសេចក្ដីថ្លែងការនេះអំពីវិធី ដែលបក្សកុម្មុយនីស្តកម្ពុជាបានរៀបចំដើម្បីកាប់ស្លាប់អតីមន្ត្រីសាធារណរដ្ឋខ្មែរ។ វិធីទាំងអស់នេះត្រូវបានរៀបចំ ចាត់ចែងផែនការយ៉ាងមានវិន័យ និងហ្មត់ចត់ ហើយបន្តកើតឡើងនៅទីបញ្ជាការកងកម្លាំងពិសេសរបស់បក្សកុម្មុយនីស្តកម្ពុជាដែលកន្លែងនោះខ្មាំងទាំងនោះត្រូវបានគេបំបែក និងសម្លាប់ចោល។ ឧត្ដមសេនីយ៍ អ៊ំ រ៉ុង ត្រូវបានឃុំនៅសណ្ឋាគារមនោរម្យ ដែលឧត្ដមសេនីយ៍រូបនេះស្ថិតនៅក្នុងបញ្ជីកាប់សម្លាប់ដែលផ្សព្វផ្សាយដោយទីភ្នាក់ងារសារ

ព័ត៌មានបារាំងនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៦។ សហសេវិករបស់ខ្ញុំបានលើកឡើងពីខាងដើមរួចមកហើយ។

ហ្វីលីព ស្ប៊ត នៅក្នុងសៀវភៅរបស់គាត់បានបញ្ជាក់ពីការស្រាវជ្រាវរបស់គាត់ថា សណ្ឋាគារមនោរម្យត្រូវបានប្រើប្រាស់ជាទីតាំងដើម្បីប្រមូលផ្តុំមន្ត្រីសាធារណរដ្ឋខ្មែរជាន់ខ្ពស់ដើម្បីយកទៅសម្លាប់ចោល។ គាត់បានហៅវាថា កន្លែងនោះគឺជាកន្លែងសម្រាប់ទៅឋាននរក។ គាត់ក៏បានលើកឡើងទៀតផងដែរថា នាយករដ្ឋមន្ត្រី ឡុង ប៉ូរ៉េត, លន់ នល់ និងអ្នករដ្ឋការជាន់ខ្ពស់ផ្សេងទៀតត្រូវបានគេយកចេញទៅសម្លាប់ចោលនៅកន្លែងកីឡា មិនឆ្ងាយពីទីស្តីការក្រសួងព័ត៌មានដែលជាកន្លែងឃុំខ្លួនពួកគេនោះទេ។ រួមគ្នាប៉ុន្មានថ្ងៃក្រោយមក អ្នកនយោបាយ ប្រាំពីរ ឬ៨០០នាក់ មន្ត្រីជាន់ខ្ពស់ ប៉ូលិស និងនាយទាហានត្រូវបានគេសម្លាប់ចោល។

[១០:០២:២០]

លោក លោកស្រីចៅក្រមជាទីគោរព! មិនមែនគ្រប់មន្ត្រីសាធារណរដ្ឋខ្មែរ និងទាហានទាំងអស់ដែលចាប់ខ្លួនបាននៅព្រែកព្នៅត្រូវបានបញ្ជូនទៅទីស្តីការក្រសួងព័ត៌មាន និងសណ្ឋាគារមនោរម្យនោះទេ។ ស៊ុំ ជា គឺជាទាហានខ្មែរក្រហមនៅភូមិភាគឧត្តរ បានរៀបរាប់អំពីការកាប់សម្លាប់ជាឈុតដែលមានការរៀបចំទៅលើមន្ត្រីសាធារណរដ្ឋខ្មែរ និងទាហាន ប្រហែលជានៅ២០០ម៉ែត្រពីព្រែកព្នៅ -- ខាងលិចព្រែកព្នៅតែប៉ុណ្ណោះ។ "ក្រោយពីប្រាំពីរ ឬប្រាំបីថ្ងៃ ពួកគេបានរៀបចំមីក្រូផ្សាយទៅដល់ទាហានលន់នល់ថា "អ្នកណាមានជួរអ្វីក៏ដោយ អាចទៅកន្លែងដើមធ្វើការងាររបស់ខ្លួនវិញ"។ ទោះបីជាពួកគេពីមុនជាទាហានតូចតាចធម្មតាក្តី ពួកគេបាននិយាយថាពួកគេជាទាហានស័ក្តិ៣ ឬក៏ស័ក្តិ៤។ អ្នកទាំងអស់នោះបានស្លាប់។ អ្នកខ្លះទៀតចង់រស់ ព្យាយាមលាក់បាំង ប៉ុន្តែពួកគេត្រូវបានចាប់ខ្លួនដោយសារគេស្រាវជ្រាវឃើញតាមរយៈប្រវត្តិរូប។ ក្នុងពេលស៊ើបការណ៍ដែលគេលើកឡើងថាទាហាននឹងបញ្ជូនទៅកន្លែងការងាររបស់គេ។ នៅពេលឡានបួន ទៅ១០ បានដឹកសុទ្ធតែមនុស្សពេញៗ អ្នកទាំងអស់នោះត្រូវបានគេដឹកយកទៅព្រែកព្នៅ។ ក្នុងពេលសម្លាប់នោះ គេបានវ៉ៃម៉ាស៊ីនឡានដើម្បីឱ្យថ្លង់។ ហេតុផលដែលខ្ញុំដឹងថាទាហានទាំងអស់នេះត្រូវបានគេយកទៅសម្លាប់ចោលនៅខាងលិចព្រែកព្នៅ គឺដោយសារទាហានម្នាក់ដែលសម្លាប់នោះប្រាប់ខ្ញុំ។ ទាហានទាំងអស់នោះត្រូវបានគេវាយនឹងត្បូងចបនិងបំពង់ឫស្សី។ កន្លែងសម្លាប់ គឺប្រហែលជា២០០ម៉ែត្រខាងលិចព្រែកព្នៅ។ នៅពេលដែលសាកសពហើមស្អុយ ពួកគេបានប្រើត្រាក់ទ័រដើម្បីធ្វើការកាយកប់សាកសពទាំងអស់នោះ"។

[១០:០៥:២១]

ស៊ុំ ជា បានផ្តល់សក្ខីកម្មនៅក្នុងពេលជំនុំជម្រះបានបញ្ជាក់ទៅលើចំណុចនេះថា ការកាប់សម្លាប់កើតឡើងប្រហែលជាបួន ឬប្រាំថ្ងៃក្រោយការជម្លៀសទីក្រុងភ្នំពេញ។ លោកក៏បានផ្តល់សក្ខីកម្មអំពីការសម្លាប់នៅទួលគោក នៅក្នុងទីក្រុងភ្នំពេញលើទាហានសាធារណរដ្ឋខ្មែរ ដែលអ្នកទាំងអស់នោះត្រូវបានគេបោកបញ្ឆោតឲ្យលាតត្រដាងអត្តសញ្ញាណរបស់គាត់តាមរយៈការផ្សាយតាមមីក្រូក្នុងទីក្រុងភ្នំពេញ។ ទាហានខ្មែរក្រហមមួយទៀតដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញប្រហែលមួយខែក្រោយថ្ងៃ១៧ មេសា ឆ្នាំ ១៩៧៥ ក៏បានបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ឯកសារលេខE3/3962ថា៖ នាយទាហានលន់នល់ និងអ្នកក្រោមបង្គាប់ត្រូវបានគេសម្លាប់ចោលនៅទួលគោក។ ហើយឯកសារនេះក៏បានផ្តល់ភស្តុតាងបង្ហាញអំពីការកាប់សម្លាប់ជាឈុត ដែលធ្វើឡើងក្រោមបញ្ជារបស់ សុន សេន ដែលជានាយអគ្គសេនាធិការរបស់បក្ស កុម្មុយនីស្តកម្ពុជា។ ខ្ញុំសូមដកស្រង់ “ខ្ញុំដឹងថាប្រជាជននៅក្នុងទីក្រុងភ្នំពេញត្រូវបានគេជម្លៀស។ ក៏ប៉ុន្តែអ្នកខ្លះនោះមិនទាន់បានចេញនៅឡើយទេ។ នៅពេលនោះក្នុងខែឧសភា ឆ្នាំ១៩៧៥ ខ្ញុំដឹងថាមានបញ្ជាមកពីមេ សុន សេន ដែលជាប្រធានផ្ទាល់ឲ្យចាប់ខ្លួនអ្នកដែលជាអ្នករដ្ឋការជាន់ខ្ពស់របស់របប លន់ នល់។ ជាពិសេសអ្នកដែលបដិសេធមិនចាកចេញពីក្រុងភ្នំពេញ។ ហើយអ្នកដែលជាអ្នកជំងឺ ដែលកំពុងព្យាបាលដោយទាហាន លន់ នល់ នៅមន្ទីរពេទ្យព្រះកេតុមាលា។ ខ្ញុំតវ៉ាមិនចូលរួម។ ក៏ប៉ុន្តែខ្ញុំដឹងថាមានអ្វីកើតឡើង ពីព្រោះខ្ញុំជាប្រធាននៃកងធំលេខ៣ ក្នុងកងពលលេខ៣១០។ អ្នកដែលចូលរួមក្នុងការចាប់ខ្លួនមនុស្សបានប្រាប់ខ្ញុំដោយផ្ទាល់ថា៖ ទាហាននិងអ្នកបម្រើរបស់គេជាច្រើននាក់ត្រូវបានចាប់ខ្លួនពីទីក្រុងភ្នំពេញហើយបានសម្លាប់ចោលបោះចូលក្នុងអណ្តូងនៅតំបន់ទួលគោក។ ខ្ញុំឃើញដំបងជាមួយនឹងស្លាកស្នាមឈាមដែលគេយកមកវិញ។ ខាន់ ដែលពាក់ព័ន្ធនឹងការកាប់សម្លាប់នេះ បង្ហាញខ្ញុំឲ្យឃើញដំបងនោះ”។

[១០:០៦:៥១]

លោក លោកស្រីចៅក្រមជាទីគោរព! យុទ្ធជនខ្មែរក្រហមមួយរូបទៀតដែលឈរជើងនៅខាងលិចក្រុងភ្នំពេញ ក្នុងពេលជម្លៀសទីក្រុងភ្នំពេញគាត់បានផ្តល់នូវភស្តុតាងផ្ទាល់អំពីការកាប់សម្លាប់ទាហានលន់នល់នៅក្នុងចម្លើយរបស់គាត់។ ឯកសារលេខ E3/5598 ខ្ញុំសូមដកស្រង់៖ “ពួកគេនឹងត្រូវចាប់ខ្លួនដាក់ខ្នោះក្រោយពេលដែលគេពិនិត្យមើលប្រវត្តិរូបនិងផ្ទៀងផ្ទាត់រួចហើយនិងបញ្ជាក់ហើយនោះពួកគេនឹងត្រូវបានគេយកទៅសម្លាប់ចោល”។

លោក លោកស្រីចៅក្រម ដូចដែលខ្ញុំបានលើកពីខាងដើមរួចមកហើយ ភស្តុតាងបង្ហាញថា មន្ត្រីទាហានសាធារណរដ្ឋខ្មែរត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញ។ អ្នកទាំងអស់នេះត្រូវបានគេសម្លាប់នៅកន្លែងផ្សេងទៀតផងដែរ។ នៅក្នុងភូមិភាគពិសេស នៅប្រហែលក្នុងខែមេសា ឆ្នាំ១៩៧៥ សាក្សី TCW-162 ប្រាប់អ្នកស៊ើបអង្កេតអំពីការកាប់សម្លាប់អតីតមន្ត្រីលន់នល់នៅក្នុងភូមិភាគនេះ។ TCW-162 ដែលជាអ្នកស្រុកថ្មីខ្មែរ នៅស្រុកគ្រឡាចលើ ខេត្តកំពង់ឆ្នាំង បានប្រាប់អ្នកស៊ើបអង្កេតអំពីកិច្ចសម្ភាសមួយនៅក្នុងខែមេសា ឆ្នាំ៧៥ នៅសហករណ៍មូលដ្ឋានដែលប្រធានឃុំ យាយភឿន អនុឃុំ និងប្រធានភូមិ មេយោធាបានពិភាក្សាអំពីការកាប់សម្លាប់អ្នកជម្លៀសពីទីក្រុងភ្នំពេញនិងមន្ត្រីសាធារណរដ្ឋខ្មែរ។ នេះគឺជាអ្វីដែលសាក្សីបានឆ្លើយ, ខ្ញុំសូមដកស្រង់៖ "ពួកគេបានមកជួបប្រជុំគ្នានៅ សហករណ៍ភូមិថ្មីខ្មែរ អំពីការកាប់សម្លាប់អ្នក១៧ មេសា និងទាហានលន់នល់។ ខ្ញុំឮយាយភឿន និយាយថាអ្នកទាំងអស់នោះត្រូវតែយកមកសម្លាប់ចោលតាមបញ្ជារបស់ថ្នាក់លើ។ តាលុច្ស បានបែងចែកក្រុមឱ្យអនុវត្តផែនការនេះ។ ការប្រជុំនោះធ្វើឡើងនៅម៉ោងបួនរសៀល។ ខ្ញុំនៅប្រហែលជា៧ម៉ែត្រតែប៉ុណ្ណោះពីកន្លែងប្រជុំ ខ្ញុំឮអ្វីដែលពួកគេនិយាយ ជាពិសេសអំពីការអនុវត្តផែនការរបស់ថ្នាក់លើ។ ពួកគេមិននិយាយថាថ្នាក់លើណានោះទេ ហើយខ្ញុំក៏មិនដឹងថាថ្នាក់លើនោះគឺជាអ្វីដែរ។ បន្ទាប់មកនៅម៉ោងប្រហែលប្រាំ ឬប្រាំមួយល្ងាច កម្មាភិបាលឃុំប្រហែល១០នាក់បានយកប្រជាជនទាំងអស់ នោះទៅសម្លាប់ចោលនៅព្រៃស្រែវាល់ ខាងជើងភូមិថ្មីខ្មែរ ឃុំត្បែងខ្ពស់។ ការប្រជុំនេះបានបង្ហាញឱ្យ យើងឃើញជាថ្មីម្តងទៀតអំពីវិធីដែលមានការរៀបចំមានវិន័យ និងមានរចនាសម្ព័ន្ធ ដែលការកាប់សម្លាប់ត្រូវបានធ្វើឡើង ហើយការកាប់សម្លាប់ទាំងអស់នោះបានធ្វើឡើងតាមបញ្ជាពីថ្នាក់លើ។

[១០:០៩:៥៨]

TCW-162ក៏បានជម្រាបអ្នកស៊ើបអង្កេតអំពីវិធីនៃការកាប់សម្លាប់ និងទីតាំងនៃផ្នូររួមផងដែរ។ គាត់បានផ្តល់ភស្តុតាងថា ខ្មែរក្រហមបានសម្លាប់តាមមធ្យោបាយឃោរឃៅបំផុតជាមួយនឹងវត្ថុជាមូលដ្ឋាន។ ជារៀងរាល់ថ្ងៃវត្ថុទាំងឡាយត្រូវបានគេប្រើប្រាស់យកទៅជាឧបករណ៍កាប់សម្លាប់។ ខ្ញុំឃើញចប ដែកថ្ពួងរទេះ ហើយនិងបំពង់ឫស្សីប្រហែលជាមួយម៉ែត្រ។ ហើយពួកគេកាប់កាំភ្លើងអឹម-ស៊ី ខ្ញុំឮយាយភឿន និង យាយណាន ប្រាប់ពួកគេថា អង្គការខាងលើមានបងប្អូន -- ចង់ឱ្យបងប្អូនទៅកន្លែងផ្សេង ដោយសារតែបងប្អូនមានថ្នាក់ខ្ពស់ ហើយកន្លែងផ្សេងគឺមានការគាំទ្រជាងនេះ។ បន្ទាប់មក ខ្ញុំឃើញកម្មាភិបាលទាំងនេះដឹកនាំប្រជាជនទាំងអស់នេះចេញទៅព្រៃស្រែវាល់ (សូមអធ្យាស្រ័យចំពោះ

ការប្រកបរបស់ខ្ញុំ) នៅព្រឹកថ្ងៃស្អែក នៅព្រឹកថ្ងៃបន្ទាប់ខ្ញុះឃើញពួកគេយកខោអាវ និងសម្ភារៈវិញមកឲ្យប្រជាជនមូលដ្ឋាន។ ខ្ញុំមិនឃើញដោយការកាប់សម្លាប់ដោយផ្ទាល់ភ្នែករបស់ខ្ញុំនោះទេ ប៉ុន្តែពីរ ឬបីថ្ងៃក្រោយមកមានធុំក្លិនស្អុយសាកសពចេញមកពីព្រៃស្រេវ៉ាល់។ កន្លះខែក្រោយមក ខ្ញុំទៅឃ្វាលគោនៅព្រៃស្រេវ៉ាល់ ខ្ញុំឃើញសាកសពនៅក្នុងរណ្តៅជ្រុងមួយប្រហែលជាបីម៉ែត្រម្ខាង ដែលមិនទាន់បានកប់ហើយមានសត្វព្រៃជីកកាយកន្លែងនោះ ហើយមានក្លិនស្អុយខ្លាំង។ ក្រោយមកនៅក្នុងឆ្នាំ១៩៨០ ប្រជាជនជីកាយផ្នូរទាំងអស់នោះដើម្បីរករបស់របរដែលកប់នៅទីនោះ។ ខ្ញុំឃើញនៅក្នុងរណ្តៅនោះគឺឃើញឆ្អឹងមនុស្ស និងឆ្អឹងលលាដ៍នៅពាសពេញកន្លែងនោះ។ ប្រជាពលរដ្ឋនៅភូមិថ្មីខ្មែរបានប្រមូល ហើយយកឆ្អឹងសាកសពទាំងអស់នោះយកមកដាក់នៅវត្តត្បែងខ្ពស់"។

[១០:១១:៥៤]

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! សាក្សីក៏បានផ្តល់ភស្តុតាងអំពីទាហាន លន់ នល់ ដែលត្រូវបានជម្លៀសពីទីក្រុងភ្នំពេញ ហើយត្រូវបានគេសម្លាប់ចោលក្រោយឆ្នាំ១៩៧៥ តែបន្តិចតែប៉ុណ្ណោះនៅភូមិភាគនិរតី។ អ្នកដាក់ពាក្យបណ្តឹងមួយនៅក្នុងបណ្តឹងរបស់គាត់ជូនតុលាការ ឯកសារ E3/5403 បានបង្ហាញអំពីអ្វីដែលទាហាន លន់ នល់ ត្រូវបានគេបំបែកនិងសម្លាប់ចោលនៅកំពត។ ខ្ញុំសូមដកស្រង់៖ "ក្រោយពេលចាប់យកក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសខ្ញុំ ប្តីរបស់ខ្ញុំ កូនរបស់ខ្ញុំពីរនាក់ពីទីក្រុងភ្នំពេញឲ្យទៅរស់នៅក្នុងភូមិឫស្សីដុំ ឃុំព្រះភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត។ ក្រោយពេលស្នាក់នៅភូមិឫស្សីដុំ ប្រហែលជាកន្លះខែ ប្តីរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាប់ខ្លួននៅប្រហែលម៉ោងប្រាំបួនព្រឹក ក្រោយមកប្រធានភូមិបានដើរអមប្តីរបស់ខ្ញុំយកទៅមន្ទីរសន្តិសុខតាមាណ នៅភូមិឫស្សីដុំ ឃុំព្រះភ្នំ ស្រុកអង្គជ័យ ខេត្តកំពត។ ខ្ញុំមិនដឹងថាហេតុអីបានជាខ្មែរក្រហមចាប់ប្តីរបស់ខ្ញុំ ហើយឃុំខ្លួនគាត់នោះទេ ខ្ញុំគ្រាន់តែដឹងថាប្តីរបស់ខ្ញុំគឺជាអតីតទាហានក្រោមរបប លន់ នល់ ហើយគឺជាប្រជាជនថ្មីមួយរូប ខ្ញុំមិនបានឮអ្វីពីគាត់ទេចាប់តាំងពីពេលនោះមក"។

[១០:១៣:៥៨]

សរុបមកវិញ ភស្តុតាងនៅចំពោះមុខលោក លោកស្រីចៅក្រមបង្ហាញថា មន្ត្រីសាធារណរដ្ឋខ្មែរពីមុនរាប់រយ រហូតដល់រាប់ពាន់នាក់ត្រូវបានគេកាប់សម្លាប់នៅក្នុងក្រុងភ្នំពេញ ក្នុងពេលពួកគេជម្លៀស ឬនៅពេលពួកគេទៅដល់ភូមិភាគនានា រួមទាំងភូមិភាគនិរតី ភូមិភាគពិសេស។ ការកាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរទាំងអស់នេះមិនមែនកើតឡើងនៅពេលជម្លៀសទីក្រុងភ្នំពេញនោះទេ ដូចដែលខ្ញុំបាន

លើកឡើងពីមុន វាក៏បានកើតឡើងនៅតាមភូមិភាគផ្សេងទៀតដែលមន្ត្រីសាធារណរដ្ឋខ្មែរ និងយោធាពីមុននោះត្រូវបានគេរកឃើញក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ផងដែរ។

ភស្តុតាងនេះបានបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយដែលមានការសម្របសម្រួលពីមជ្ឈិមនៅក្នុងការធ្វើទុក្ខបុកម្នេញ និងការកាប់សម្លាប់មន្ត្រីលន់នល់ពីមុន និងទាហាននៅទូទាំងប្រទេស។ ចំពោះការកាប់សម្លាប់ទាំងនេះដែលកើតឡើងនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ខ្ញុំនឹងបង្ហាញភស្តុតាងដែលបង្ហាញអំពីទីតាំងភូមិសាស្ត្រ ចាប់ផ្តើមពីភូមិភាគឧត្តរ ភូមិភាគពាយ័ព្យ ភូមិភាគកណ្តាល និងភូមិភាគបូព៌ា។ នៅពេលដែលយើងមើលភូមិភាគឧត្តរនៅសៀមរាប ភស្តុតាងបានបង្ហាញនៅក្នុងពេលជំនុំជម្រះ អំពីរបៀបដែលមន្ត្រីសាធារណរដ្ឋខ្មែរ និងមន្ត្រីយោធាត្រូវបានគេកំណត់ និងសម្លាប់ចោលក្នុងលក្ខណៈស្រដៀង។ ប៉េជុយ ជីបសែ, នៅក្នុងចម្លើយរបស់គាត់, អ្នកស៊ើបអង្កេតបានលើកឡើងថា "វាមិនមែនត្រឹមតែបុរសទេដែលត្រូវបានគេសម្លាប់ គ្រួសារទាំងអស់ក៏ត្រូវបានគេសម្លាប់ផងដែរ។ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឃើញគេជម្លៀសទាហាន ឬអតីតមន្ត្រីរដ្ឋបាល លន់ នល់ ពីខេត្តសៀមរាប ហើយយកទៅដាក់នៅផ្ទះថ្មចាស់មួយនៅផ្សារដីក្រែង ដែលនៅទីនោះពួកគេត្រូវបានគេយាមទាំងយប់ទាំងថ្ងៃ។ ក្រោយមកគេយកអ្នកទាំងនោះទៅសម្លាប់ចោល។ អ្នកទាំងអស់នេះគឺជាមន្ត្រីយោធា និងជាអតីតមន្ត្រីរដ្ឋាភិបាល លន់ នល់ ហើយគ្រួសាររបស់គេក៏ត្រូវបានជម្លៀសចេញពីសៀមរាបផងដែរ។ នៅពេលដែលគេដឹកពួកគេយកចេញទៅសម្លាប់ចោល គេប្រាប់អ្នកទាំងអស់នោះថា គេយកទៅឲ្យរៀនសូត្រ ក៏ប៉ុន្តែការពារពិតគេដឹកយកទៅសម្លាប់ចោលទេ។ មានប្រជាជនទាំងអស់វាបរយនាក់ ហើយការដឹកជញ្ជូនអ្នកទាំងអស់នេះយកទៅសម្លាប់នោះ វាបានបន្តឡើងជាច្រើនថ្ងៃ"។

[១០:១៦:៤១]

ប៉េជុយ ជីបសែ បានបង្ហាញអំពីព័ត៌មានលម្អិត ពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលគាត់បានមកឆ្លើយនៅក្នុងពេលជំនុំជម្រះ។ ខ្ញុំសូមដកស្រង់៖ "យើងឃើញគេដឹកប្រជាជនចេញទៅ ជាពិសេសអ្នកដែលជាមន្ត្រី គឺគេដឹកយកទៅសម្លាប់ចោល។ ហើយប្រជាជនទាំងអស់ត្រូវបានគេបញ្ជូនពីកន្លែងផ្សេងៗដើម្បីសម្លាប់ចោល។ អតីតមន្ត្រី ឬទាហានរបស់របប លន់ នល់ ត្រូវបានគេជម្លៀសទៅកំពង់ក្តី មិនត្រូវបានឃុំខ្លួននោះទេ។ ពួកគេគ្រាន់តែត្រូវបានគេសួរចម្លើយដោយសង្ខេប បន្ទាប់មកបញ្ជូនទៅសម្លាប់ចោល។ ទាហាន លន់ នល់ ដែលត្រូវបានគេជម្លៀសនៅក្នុងឆ្នាំ១៩៧៥ មិនត្រូវបានគេចាប់បញ្ជូនទៅមន្ទីរសន្តិសុខពង្រនោះទេ ពួកគេត្រូវបានសម្លាប់ចោលភ្លាមៗ ក្រោយពេលចាប់ខ្លួនបាន។ ខ្ញុំឮថាពួកគេ

ត្រូវបានគេដឹកជម្លៀស -- ប្រជាជនត្រូវបានដឹកជម្លៀសនោះ គឺជាអតីតទាហាន លន់ នល់ ហើយត្រូវបានគេសម្លាប់ចោលនៅទីតាំងម្នាក់។ មន្ត្រីលន់នល់ និងទាហានលន់នល់ ដែលត្រូវបានគេជម្លៀសទៅជីក្រែង ត្រូវបានខ្មែរក្រហមសម្លាប់ចោល”។

[១០:១៧:៥០]

ជនរងគ្រោះម្នាក់ទៀតបានផ្ដល់ភស្តុតាង ក្នុងឯកសារ E3/5356 ដែលបង្ហាញអំពីដំណើរការដូចគ្នានៃការបោកបញ្ឆោត ការបំបែក ការកាប់សម្លាប់មន្ត្រី និងទាហានលន់នល់ នៅស្រុកក្រឡាញ់ ខេត្តសៀមរាប នៅក្នុងខែមេសា ឆ្នាំ១៩៧៥។ ខ្ញុំសូមដកស្រង់៖ “ទាហានខ្មែរក្រហមបានបញ្ជាឲ្យប្ដីរបស់ខ្ញុំ និងខ្ញុំនៅវត្តក្រឡាញ់ ដោយសារប្ដីរបស់ខ្ញុំគឺជាអតីតទាហានរបបចាស់។ ប្រជាជនភាគច្រើនដែលត្រូវបានគេប្រមូលដាក់នៅវត្តក្រឡាញ់នៅពេលនោះ គឺជាអតីតគ្រួសាររបស់ទាហាន លន់ នល់។ ប្រាំថ្ងៃក្រោយមកអ្នកទាំងអស់ដែលជាអតីតគ្រួសារទាហាន ត្រូវបានគេជម្លៀសទៅឲ្យស្នាក់នៅវត្តស្នួល។ នៅក្នុងពេលប្រជុំ កម្មាភិបាលខ្មែរក្រហមបានលើកឡើងថា -- សូមដកស្រង់៖ “ក្រុមទី១ ក្រុមប្ដីរបស់ខ្ញុំនេះត្រូវបានគេបញ្ជូនទៅអប់រំ” បញ្ចប់ការដកស្រង់។ “រហូតមកដល់សព្វថ្ងៃនេះខ្ញុំមិនដឹងថាតើប្ដីរបស់ខ្ញុំនេះត្រូវគេបញ្ជូនទៅរៀនសូត្រនៅណានោះទេ។ ក្រោយមកខ្ញុំដឹងថាប្ដីរបស់ខ្ញុំត្រូវបានគេសម្លាប់ចោល”។

[១០:១៩:០៤]

សាក្សីមួយរូបទៀត TCCP-152 គឺជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលរៀបរាប់អំពីកិច្ចប្រជុំមួយនៅទីរួមខេត្តក្នុងភូមិស្ទឹងថ្មី ដែលនៅទីនោះគេប្រកាសថា មន្ត្រីរដ្ឋាភិបាលទាំងអស់ នគរបាល ទាហានត្រូវឲ្យទៅចូលរៀនវគ្គអប់រំនយោបាយបីថ្ងៃ។ ក្រោយមកនៅក្នុងឆ្នាំ១៩៧៥ គាត់បានឃើញសាកសពនៅកន្លែងកាប់សម្លាប់នៅបារាយណ៍ទឹកថ្លា។ ខ្ញុំសូមដកស្រង់៖ “ខ្ញុំឃើញសាកសពនៅក្នុងឆ្នាំ៧៥ យោងតាមអ្នកភូមិនៅក្បែរនោះ អ្នករដ្ឋការ នគរបាល ទាហាន ត្រូវបានគេដឹកយកទៅសម្លាប់ចោលនៅកន្លែងនោះ ក្រោយខ្មែរក្រហមកាន់កាប់ខេត្តសៀមរាប។ ខ្ញុំនៅចាំថា នៅពេលខ្មែរក្រហមចូលមកដល់ ពួកគេប្រកាសទៅដល់អ្នករដ្ឋការ ទាហាន និងនគរបាលឲ្យទៅទទួលសម្ដេច សីហនុ។ ខ្ញុំបានទៅដល់កន្លែងនោះ នៅពេលដែលខ្ញុំទៅប្រមូលខស”។

លោក លោកស្រីចៅក្រម ជាទីគោរព! ការបោកបញ្ឆោតដោយកម្មាភិបាលបក្សកុម្មុយនីស្ដកម្ពុជា ដើម្បីឲ្យ អញ្ជើញឲ្យអតីតមន្ត្រីសាធារណរដ្ឋខ្មែរ និងទាហាន ចូលរួមវគ្គអប់រំ ឬទៅទទួលសម្ដេចនោះ ដូចដែលលោក លោកស្រីបានអាន និងបានស្ដាប់ គឺជាយុត្តិសាស្ត្រនៅទូទាំងប្រទេស ដែល

បក្សកុម្មុយនីស្តកម្ពុជាប្រើប្រាស់ដើម្បីទាក់ទាញជនរងគ្រោះទាំងអស់នេះ។ យើងនឹងឃើញយុត្តិសាស្ត្រដូចគ្នានេះ នៅពេលដែលយើងលើកឡើងអំពីការកាប់សម្លាប់នៅទីកាប់សម្លាប់ទួលពោធិ៍ជ្រៃដែលជាកន្លែងកាប់សម្លាប់។

[១០:២០:៥៣]

លោកប្រធាន ខ្ញុំសូមអនុញ្ញាតចូលទៅដល់ភូមិភាគពាយ័ព្យ ជាកន្លែងដែលមានការកាប់សម្លាប់នៃអតីតមន្ត្រីទាហានលន់ នល់ និងជនស៊ីវិល គឺនៅក្នុងឆ្នាំ១៩៧៥។

មានសាក្សីជាច្រើនដែលសាក្សីប្រាប់ទៅអ្នកស៊ើបអង្កេតរបស់តុលាការនេះថា និយាយអំពីការកាប់សម្លាប់។ ជាឧទាហរណ៍ សាក្សីមួយបានប្រាប់អ្នកស៊ើបអង្កេតថា, នៅក្នុងឯកសារ E3/5211, ថាគាត់បានឃើញមេដឹកនាំស្រុកខ្មែរក្រហម តាឆាំ បានចេញបញ្ជាឲ្យគេប្រមូលអតីតទាហានលន់ នល់ ទាំងអស់ឲ្យទៅប្រជុំនៅវត្តភ្នំសំពៅ។ ក្រោយពីការប្រជុំនោះរួចហើយ គាត់បានឃើញមន្ត្រី ហើយនិងពួកយោធាយោធាទាំងអស់នោះត្រូវបានគេចាប់ដឹកតាមឡានចេញទៅ។ ទាក់ទងទៅនឹងមន្ត្រីស៊ីវិល ដែលប្រធានស្រុកនិងប្រធានឃុំវិញ គាត់និយាយថា សូមដកស្រង់៖ "ខ្ញុំឃើញកូនទាហាន តាឆាំ – បានចាប់ប្រជាជនដែលគេបានរកឃើញហើយបានដឹកតាមឡាន – ប្រាប់ពួកគេថាគេយកទៅរៀនសូត្រនៅអង្គការថ្នាក់លើ។ ខ្ញុំបានឮពីអ្នកភូមិថា អ្នកទាំងអស់នោះ ដែលគេបានចាប់ខ្លួននោះ ត្រូវបានគេយកទៅចម្ការប៉េងអានៗនៅក្បែរភូមិស្ទឹង ឃុំស្ទឹង ប្រហែលជា១០គីឡូម៉ែត្រពីភ្នំសំពៅ ហើយយកទៅព្រៃគុប។ គ្មាននរណាម្នាក់នៅក្នុងអ្នកនោះ ត្រឡប់មកវិញទេ ហើយយើងបាត់ដំណឹងអ្នកទាំងអស់ហ្នឹងរហូតមកដល់ពេលនេះ។ អ្នកភូមិបានឃើញសាកសពអ្នកទាំងអស់នេះ ប្រហែលជាបីបួនថ្ងៃក្រោយ។ គេបានបាញ់អ្នកទាំងនោះសម្លាប់ចោល"។ សូមបញ្ចប់សេចក្ដីដកស្រង់។

[១០:២២:៥២]

លោកប្រធានជាទីគោរព! ចម្លើយដែលប្រាប់ទៅអ្នកស៊ើបអង្កេតរបស់តុលាការនេះបានរៀបរាប់អំពីគោលនយោបាយនៃការកាប់សម្លាប់ជាប្រព័ន្ធ នៅក្នុងតំបន់ផ្សេងៗនៅក្នុងភូមិភាគពាយ័ព្យ។ សាក្សីនៅក្នុងចម្លើយ E3/5282 បានរៀបរាប់ពីការកាប់សម្លាប់ជនស៊ីវិល ហើយនិងអាជ្ញាធរយោធា ទាហានថ្នាក់ស្រុក ស្រុកភ្នំស្រុក នៅក្នុងបន្ទាយមានជ័យ ក៏ព្រមទាំងខេត្តបាត់ដំបងផងដែរ។ សាក្សីម្នាក់ទៀត E2/505 បានផ្តល់ភស្តុតាងអំពីការកាប់សម្លាប់នៅបាត់ដំបង នៅភូមិសំពៅ ឃុំភ្នំសំពៅ នៅក្បែរបាត់ដំបង។ E3/5226 បានប្រាប់អំពីការកំណត់អត្តសញ្ញាណជាប្រព័ន្ធនូវទាហានលន់នល់ និងមន្ត្រី

ហើយនិងការបំបែកតាមឋានន្តរសក្តិ ហើយនិងការកាប់សម្លាប់នៅស្រុកបាណន់ ខេត្តបាត់ដំបង។ បទសម្ភាសន៍ ជាមួយជនភៀសខ្លួន នៅក្នុងឆ្នាំ១៩៧៥ ដោយលោក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ ក៏បានបង្ហាញអំពីភស្តុតាងរឿងរ៉ាវដ៏មានតម្លៃមួយចំនួន ដែលថាមានការសម្លាប់នៅភូមិភាគពាយ័ព្យ បន្ទាប់ពីមានការជម្លៀស។ ជនភៀសខ្លួនពីរនាក់ បានរៀបរាប់ពីការកាប់សម្លាប់យោធាដែលបាត់បង់លទ្ធភាពប្រយុទ្ធ ជាពិសេសនៅក្នុងរបបសាធារណរដ្ឋខ្មែរ នៅក្នុងខេត្តប៉ៃលិន។ លោក ប៉ុងសូដ៍ បានបញ្ជូនលោកតុលាការ គាត់បានប្រាប់អំពីការកាប់សម្លាប់មន្ត្រីជាន់ខ្ពស់របស់ទាហានលន់នល់ នៅភ្នំធិបតីក្នុងខេត្តបាត់ដំបង។ អ្នកភូមិមកពីភ្នំធិបតីនោះ បានរៀបរាប់អំពីហេតុការណ៍ដូចគ្នា ហើយគាត់បានឃើញថា គេបញ្ឆោតអ្នកទាំងនោះដឹកតាមឡានទៅ យកទៅសម្លាប់ចោល។ លោក ប៉ុងសូដ៍ បានប្រមូលភស្តុតាងមួយចំនួន និងសក្ខីកម្ម ជាពិសេស គឺទាហានដែលបាត់បង់ដែលការប្រយុទ្ធនៅខេត្តបាត់ដំបង នៅថ្ងៃគោលដែលពាក់ព័ន្ធទៅនឹងជនរងគ្រោះ៣០០នាក់។ ការកាប់សម្លាប់រង្គាលនោះគឺនៅកសិដ្ឋានមេច្បារ ហើយគាត់បានរៀបរាប់ដូចខាងក្រោមនេះ៖ "អនុលោមតាមសាក្សីចំនួនច្រើននោះកសិដ្ឋាននេះគឺកន្លែងកាប់សម្លាប់ដ៏ឃោរឃៅ មនុស្សរាប់រយ បើមិនរាប់ពាន់ទេ ត្រូវបានគេសម្លាប់នៅទីនោះ"។ សូមបញ្ចប់សេចក្តីដកស្រង់។

[១០:២៥:៣០]

លោកប្រធាន! នៅក្នុងភូមិភាគកណ្តាល ឯកសារ E3/5358 បានរៀបរាប់អំពីការស្លាប់របស់ប្អូនរបស់គាត់ដែលជាអតីតទាហានសាធារណរដ្ឋនៅក្នុងខេត្តកំពង់ចាម។ សូមដកស្រង់៖ "នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានសម្លាប់ប្អូនខ្ញុំ គាត់អាយុ២៦ឆ្នាំ ហើយរស់នៅក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម ឌឿន ជាអ្នកសម្លាប់គាត់។ ឌឿន ជាប្រធានសហករណ៍។ ដោយហេតុថាគេដឹងថា ប្អូនខ្ញុំជាទាហានលន់នល់ឆ្នាំ១៩៧៥" សូមបញ្ចប់សេចក្តីដកស្រង់។

លោកប្រធាន! នៅក្នុងភូមិភាគបូព៌ា ការកាប់សម្លាប់មន្ត្រីនិងទាហាន សាធារណរដ្ឋខ្មែរបានកើតឡើងនៅក្នុងភូមិភាគនេះដែលគេប្រមូលអ្នកទាំងអស់នោះ នៅក្នុងពេលជម្លៀសទីក្រុងស្វាយរៀង។ សាក្សី E3/5260 បានផ្តល់ចម្លើយទៅអ្នកអង្កេតរបស់សហចៅក្រមស៊ើបអង្កេតបានរៀបរាប់ពីការសម្លាប់នេះ។ ខ្ញុំសូមដកស្រង់៖ "ចំពោះបុរសដែលគេជម្លៀសមកពីស្វាយរៀង ហើយអ្នកដែលជាមាននិន្នាការជាស៊ីវិល ឬក៏ជាមន្ត្រីយោធារដ្ឋាភិបាល នគរបាល និស្សិត ឬក៏គ្រូដែលពាក់ព័ន្ធទៅនឹងទាហានលន់នល់ ដែលបានត្រឡប់ទៅភូមិរបស់គេវិញ ហើយគេបានចាប់ខ្លួនរបស់អ្នកទាំងនោះក៏យកចេញទៅ

ភាគច្រើនដែលអ្នកជម្លៀសទាំងនោះស្ថិតនៅក្នុងក្រុមនេះដែរ។ មានន័យថាគេបានចាប់ខ្លួន ហើយយកទៅបាត់ខ្លួនរហូត។ សរុបទៅប្រហែលជាមាន៥០នាក់”។

[១០:២៧:១៣]

លោក លោកស្រីចៅក្រម! ដើម្បីបញ្ចប់ផ្នែកនេះភស្តុតាងបានបង្ហាញយ៉ាងទូលំទូលាយថា មានគំរូជាប្រព័ន្ធស្របគ្នាអំពីការកាប់សម្លាប់នៅអតីតទាហានលន់នល់ ហើយនិងមន្ត្រីលន់នល់ទូទាំងប្រទេសភ្លាមៗបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទូទាំងរបបកម្ពុជាប្រជាធិបតេយ្យនោះផងដែរ។ នេះបញ្ជាក់ដោយអ្នកជំនាញ ហ្វីលីព ស្ហរ្ត ដែលបានធ្វើសក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។ ខ្ញុំសូមដកស្រង់៖ “វាមានគំរូមួយទូទាំងប្រទេសនៃការកាប់សម្លាប់អតីតមន្ត្រីទាហានលន់នល់ និងរាជការលន់ នល់ ហើយនិងការកាប់សម្លាប់មន្ត្រីរដ្ឋាភិបាល លន់ នល់ គឺនៅក្នុងបណ្តាស័ក្តិមួយ ឬខ្ពស់ជាងហ្នឹង។ មិនមែនជាលន់ នន់ ហើយទាហានលន់ នល់ ក៏ត្រូវបានសម្លាប់។ មិនមែនមន្ត្រីជាន់ខ្ពស់តែប៉ុណ្ណោះទេ ប៉ុន្តែទូទៅជាលទ្ធផលមានការកាប់សម្លាប់ទូទាំងប្រទេស។

[១០:២៨:២២]

នេះវាមានការស្របគ្នាណាស់ គឺថាគ្រប់ទីកន្លែងដែលយើងបានដឹងគឺទាហាន លន់ នល់ ដែលមានឋានៈស័ក្តិខ្ពស់កម្រិតមួយនោះត្រូវបានគេសម្លាប់ ហើយអ្នកដែលមានឋានៈខ្ពស់ក៏ដូចគ្នានោះដែរ” បញ្ចប់ការដកស្រង់។ លោក ហ្វីលីព ស្ហរ្ត បានធ្វើសក្ខីកម្មអំពីការកាប់សម្លាប់ទាំងអស់នេះថាត្រូវបានអនុវត្តដោយផ្ទាល់អំពីការបញ្ជាពីមជ្ឈិមបក្ស។ មេធាវីការពារក្តីនឹងធ្វើឲ្យលោក លោកស្រីចៅក្រម ជឿថាមេដឹកនាំភូមិភាគមិនគោរពវិន័យ គឺធ្វើការជាស្តេចត្រាញ់សម្រេចអ្វីៗដោយខ្លួនឯង។ ប៉ុន្តែនៅក្នុងការសួរដេញដោលដោយមេធាវីការពារក្តី លោក ស្ហរ្ត នោះបានបញ្ជាក់ពីភស្តុតាងដែលគួរឲ្យជឿជាអ្នកជំនាញថា អំពីលក្ខណៈនៃគោលនយោបាយនៃការសម្លាប់មន្ត្រីរបបសាធារណរដ្ឋ។ ខ្ញុំសូមដកស្រង់៖ “គេមិនអាចធ្វើបែបនោះទៅបាននោះទេ បើសិនជាមេបញ្ជាការភូមិភាគធ្វើអ្វីមិនគោរពទៅតាមគោលនយោបាយដែលគេសម្រេចជាសមូហភាពរួចទៅហើយនោះ។ យើងមិននិយាយអំពីកងទ័ពដែលថាគេស្ថិតនៅក្នុងក្រុមដាច់ដោយឡែកនោះទេ ប៉ុន្តែនេះជាទ្រង់ទ្រាយធំដែលយកបញ្ហាសម្រេចក្នុងដៃរបស់ខ្លួនឯងនោះ។ យើងនិយាយអំពីយោធាដែលមានក្រុមតូច មិនមែនជាកងកម្លាំងធំធេងដែលគ្រប់គ្រងយ៉ាងរឹងមាំ។ បាទ ពិតហើយគឺមានករណីមួយចំនួននៃការលួចឆក់ ប៉ុន្តែវាអាចនឹងមានបែបនោះ។ ប៉ុន្តែទ្រង់ទ្រាយធំជាប្រព័ន្ធនៃការកាប់សម្លាប់នៃក្រុមមួយនោះគឺមិនអាចទៅរួចនោះទេ។ ខ្ញុំមិនឃើញអ្វីដែលគួរ

ឲ្យជឿថា អាចនឹងកើតមានឡើងក្រៅពីមានគោលនយោបាយដែលយល់ស្របគ្នាទាំងស្រុងដែលត្រូវបានកំណត់ជាមុននោះទេ។

សូមបញ្ចប់។ នេះខ្ញុំគិតថាអាចនឹងដល់ពេលសម្រាកលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មមត្រូវសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣០ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីបន្តការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ សូមអញ្ជើញ!

**លោក វីញ្ចៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ផ្នែកចុងក្រោយដែលខ្ញុំបានបញ្ចប់នេះយើងបានពិភាក្សាពីគំរូជាប្រព័ន្ធនៃការកាប់សម្លាប់មន្ត្រីរបបសាធារណរដ្ឋខ្មែរ មានយោធានៅទូទាំងប្រទេសនៅថ្ងៃទី -- នៅខែមេសា ឆ្នាំ១៩៧៥ ដែលបង្ហាញអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដើម្បីសម្លាប់នូវមន្ត្រីទាំងអស់នេះ។

ឥឡូវនេះ ខ្ញុំនឹងចូលទៅដល់ផ្នែកមួយដែលថាក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយនិងពិនិត្យមើលភស្តុតាងដើម្បីរកឲ្យឃើញថា តើគោលនយោបាយនោះបន្តដែរឬទេ? ដើម្បីមើលភស្តុតាងនេះ ដើម្បីបង្ហាញ ហើយនិងបញ្ជាក់គោលនយោបាយនោះពិតជាមានមែននៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យនោះ។ តាមពិត គោលនយោបាយសម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរចាប់ពីខែមេសា ឆ្នាំ១៩៧៥

ហើយនិងមុន ហើយបានកើនកាន់តែខ្លាំងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ដែលមេដឹកនាំកម្ពុជាមានការភ័យខ្លាច និងមានភាពងប់ងល់នឹងការលុបបំបាត់នូវអ្នកដែលគេចោទថា "ខ្មាំង" នោះ វាមានឥទ្ធិពលកាន់តែធ្ងន់ធ្ងរឡើងនោះ។

[១០:៥៤:៤០]

ភស្តុតាងដ៏ច្បាស់មួយបានបង្ហាញថា គោលនយោបាយនេះបានបន្តក្នុងរូបភាពជាបញ្ជារបស់យោធាផងដែរ ដូចដែលបានឃើញនៅក្នុងសវនាការ។ បញ្ជារបស់យោធា គឺជាឯកសារដ៏មានភស្តុតាងដ៏សំខាន់។ គេបង្ហាញអំពីរចនាសម្ព័ន្ធយោធា ការរាយការណ៍ ការបញ្ជា ហើយនិងការត្រួតត្រា ហើយនិងតាមពិតខ្លឹមសារនៃបញ្ជាទាំងអស់នោះ នៅក្នុងករណីមួយចំនួនមានកំណត់អំពីអត្តសញ្ញាណជនរងគ្រោះ គឺការបញ្ជាឲ្យសម្លាប់។

នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៧៥ បញ្ជាយោធា គឺស្របទៅតាមគោលនយោបាយរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាថ្នាក់ខ្ពស់ គឺឲ្យសម្លាប់មន្ត្រីសាធារណរដ្ឋកម្ពុជា។ បញ្ជានេះធ្វើឡើងដោយសមមិត្តពិន ដែលជាមេបញ្ជាការកងពលតូចភូមិភាគពិសេស ហើយបញ្ជាឲ្យសម្លាប់មន្ត្រី ទាហានសាធារណរដ្ឋខ្មែរចំនួន១៧នាក់។ បញ្ជានោះបញ្ជាក់ថា៖"អ្នកទាំង១៧នាក់នេះ ត្រូវបានពិនិត្យដោយបក្សរួចរាល់ហើយ ហើយបក្សបានសម្រេចថាឲ្យកម្ទេចអ្នកទាំងអស់នេះចោល" ហើយក៏បានបញ្ជាក់តទៅទៀត៖ "សមមិត្តត្រូវបានស្នើឲ្យអនុវត្តនូវគោលនយោបាយរបស់បក្ស"។ សូមបញ្ចប់សេចក្តីដកស្រង់។

[១០:៥៦:៣២]

គោលនយោបាយរបស់បក្ស គឺនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៧៥។ លោក លោកស្រីចៅក្រមជាទីគោរព យថាភាពនៃបញ្ជានេះត្រូវបានបញ្ជាក់បន្ថែមដោយ អៀង សារី នៅក្នុងបទសម្ភាសន៍ជាមួយលោក ស្ទីវហ្វិន ហេដឌ័រ។ លោក អៀង សារី ក៏បានបញ្ជាក់ផងដែរថា "បញ្ជាឲ្យកម្ទេចមន្ត្រីសាធារណរដ្ឋខ្មែរដែលស្ថិតនៅក្នុងបញ្ជីដែលគេត្រូវកម្ទេចចោលនោះ"។ សមមិត្ត ពិន ជាអ្នកចេញបញ្ជានោះក្រោយមកត្រូវបានចាត់តាំងឲ្យធ្វើជាលេខាកងពល៣០៣នៃមជ្ឈិម។ ឌុច បានស្គាល់ ពិន ច្បាស់ណាស់ ហើយរៀបរាប់អំពីការសន្ទនាដែលគាត់បាននិយាយជា ពិន អំពីការសម្លាប់មន្ត្រី ហើយនិងអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ។ សូមដកស្រង់សម្តីរបស់ ឌុច៖ "ខ្ញុំដឹងថាក្រោយពីថ្ងៃទី១៧ មេសា ទាហានត្រូវបានគេលុបបំបាត់ចោលជាប្រព័ន្ធ។ គេបានបញ្ជាក់ប្រាប់ខ្ញុំច្បាស់គឺតាមរយៈ ខឹម ពិន គឺ ខឹម ពិន ជាអ្នកប្រាប់ខ្ញុំ ជាលេខាកងពល៧០៣, ហើយ ហ៊ី ជាអនុប្រធានខ្ញុំក៏ប្រាប់ខ្ញុំ។ ក្រោយពីការរំដោះគេបាន

តាមប្រមាញ់ពួកទាហាននោះ ហើយអ្នកទាំងអស់នោះក៏រត់គេចខ្លួន"។ ឌុច ក៏បាននិយាយដែរថា ខឹម ពិន ក៏បាននិយាយអំពីការកម្ទេចនូវឧត្តមសេនីយ៍ដែលគេបញ្ជាក់ឈ្មោះមួយចំនួន។ សូមដកស្រង់៖ "ឧត្តមសេនីយ៍មួយចំនួន ដូចជា គឹម អេង ហើយនិង ឈឹម ឈួន បានប្រាប់គាត់ថា គេនចុះចាញ់ ហើយក្រោយមកគេបានកម្ទេចគេចោល។ ហ៊ា ក៏បានប្រាប់ខ្ញុំដូចគ្នាដែរអំពីឧត្តមសេនីយ៍ ដេង ឡាយ៉ុម ដែលបានបង្ហាញថាគាត់នោះមានសេចក្ដីក្លាយហានណាស់"។ សូមបញ្ចប់សេចក្ដីដកស្រង់។

[១០:៥៨:៣៩]

ខ្ញុំសូមកត់សម្គាល់ថា ឧត្តមសេនីយ៍ពីររូបនេះត្រូវបានបញ្ជាក់អត្តសញ្ញាណដោយ ឌុច គឺ ឈឹម ឈួន ហើយនិង ដេង ឡាយ៉ុម នោះ។ អ្នកទាំងពីរនោះគឺស្ថិតនៅក្នុងបញ្ជីដែលគេសម្លាប់ គឺជាមន្ត្រីសាធារណរដ្ឋខ្មែរ ដូចខ្ញុំបានពិភាក្សាខាងដើម។ បញ្ជីនោះគឺគេបានបោះពុម្ពផ្សាយនៅក្នុងទីក្រុង -- សារព័ត៌មានបាំងកក នៅពីរខែក្រោយមក។

លោក លោកស្រីចៅក្រម! គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីសម្លាប់មន្ត្រី ឬក៏អ្នករដ្ឋការយោធារបប លន់ នល់ បន្តយ៉ាងពេញទំហឹង និងយ៉ាងមានប្រសិទ្ធភាពទូទាំងកម្ពុជាប្រជាធិបតេយ្យ។ ហើយទស្សនាវដ្ដីទង់បដិវត្តក្នុងខែសីហា ឆ្នាំ១៩៧៥ បានជំរុញឲ្យកម្មាភិបាលធ្វើការកាប់សម្លាប់នូវមន្ត្រីសាធារណរដ្ឋខ្មែរ។ សូមដកស្រង់៖ "ដើម្បីការពារទីក្រុងភ្នំពេញ ហើយនិងការកម្ទេចក្រុមចារកម្ម ហើយនិងកម្ទេចអ្នកវិទ្ធង្សនា យើងត្រូវ -- ដែលគេចង់បំផ្លិចបំផ្លាញបដិវត្តន៍របស់យើង យើងនឹងបន្តធ្វើការកម្ទេចខ្មាំងចុះចាញ់ដែលនៅសេសសល់ ដើម្បីប្រមូលផ្ដុំជោគជ័យរបស់យើង"។

[១០:៥៩:៥១]

កំណត់ហេតុអង្គប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃ -- ខែមីនា ឆ្នាំ១៩៧៦ ដែល នួន ជា និង ខៀវ សំផន បានចូលរួមបានកត់ខ្លឹមសារថា សូមដកស្រង់៖"របបសក្ដិភូមិទាំងស្រុងត្រូវបានកម្ទេចចោលជាអចិន្ត្រៃយ៍ហើយ" សូមបញ្ចប់។ ប៉ុន្តែលោក លោកស្រីចៅក្រម ការកាប់សម្លាប់ចេះតែបន្តមិនចេះចប់ ជាពិសេសនៅស-២១ ហើយនិងជាគុកដ៏ធំមួយ ហើយនិងមន្ត្រីជាច្រើនដែលមានឯកសារដែលនៅសេសសល់នោះ ហើយបានបង្ហាញថា មានការកាប់ចាប់ខ្លួន ការឃុំឃាំង ទារុណកម្ម និងការកាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរ។ ការផ្សព្វផ្សាយនៅខែឧសភា ឆ្នាំ១៩៧៦ បានបញ្ជាក់ថា "អតីតទាហានសាធារណរដ្ឋខ្មែរត្រូវ

បានគេសម្លាប់ជាបន្តនៅខេត្តបាត់ដំបង"។ របាយការណ៍ព័ត៌មានឆ្នាំ១៩៧៦ ខែកក្កដា បានរៀបរាប់ថា "ទាហានសាធារណរដ្ឋខ្មែរ៣៥០នាក់ ត្រូវបានគេបាញ់សម្លាប់អារុធស្វ័យប្រវត្តិជាក្រុមនៅ --

ដែលពួកគេមកពីប្រទេសថៃ"។ សារទូរលេខនៅក្នុងខែមីនា ឆ្នាំ១៩៧៨ មកពីភូមិភាគឧត្តរ ទៅមន្ទីរ ៨៧០ថា៖ "នៅក្នុងរដូវប្រាំង ខ្មាំងដែលនៅសេសសល់ បានងើបឡើងវិញ។ យើងបានបោសសម្អាតពួកគេជាប្រព័ន្ធ។ ឥឡូវនេះ ពួកនគរបាល ទាហាន ហើយនិងមន្ត្រីរដ្ឋាភិបាល បានគេចខ្លួន បន្ទាប់ពីយើងបោសសម្អាត២០នាក់ហើយនោះ។ ត្រូវមានវិធានការបន្ថែម ដើម្បីចាប់ពួកគេបន្ថែមទៀត"។ សូមបញ្ចប់សេចក្តីដកស្រង់។

[១១:០១:៤៧]

ដូច្នេះ លោក លោកស្រីចៅក្រម ជ្រាបហើយ ភស្តុតាងបានបង្ហាញយ៉ាងច្បាស់ថា មន្ត្រីសាធារណរដ្ឋខ្មែរត្រូវបានគេសម្លាប់ទូទាំងប្រទេសកម្ពុជា នៅក្នុងព្រៃ នៅតាមវាល នៅក្នុងផ្ទះ នៅតាមប្រឡាយ នៅគ្រប់ទីកន្លែង គេបានឃើញសាកសពអ្នកទាំងអស់នោះ។ ផ្អែកទៅលើបទសម្ភាសន៍យ៉ាងទូលំទូលាយជាមួយជនភៀសខ្លួន ដែលមកភាគច្រើនពីភូមិភាគពាយ័ព្យ មកព្រំដែនថៃ នៅកន្លែងផ្សេងៗទៀត។ លោក ហ្វ្រង់ស្វ័រ ប៉ុងស្វូដ៍ បានបញ្ជាក់ថា សូមដកស្រង់៖ "រឿងរ៉ាវដែលស្ថិតនៅក្នុងបញ្ហានោះ យើងគួរជឿជាក់បាន។ គេបានបញ្ជាក់ពីអ្វីដែលអ្នកទាំងអស់និយាយ អំពីការកាប់សម្លាប់មន្ត្រីរដ្ឋការ ហើយនិងមន្ត្រីយោធារបស់របប លន់ នល់ ទូទាំងប្រទេសផងដែរ"។ សូមបញ្ចប់សេចក្តីដកស្រង់។

មានគំរូដែលស្របគ្នាអំពីការល្បួងជនរងគ្រោះជាច្រើនឲ្យទៅស្លាប់ ដោយមានសន្យាបោកបញ្ឆោត។ ការកាប់សម្លាប់កើតឡើងដោយមានការកម្មវិធីដែលស្របគ្នា ដោយការកត់ប្រវត្តិរូប ហើយនិងការបំបែកជនរងគ្រោះពីគ្នា។ ការកាប់សម្លាប់ត្រូវបានធ្វើផែនការរៀបចំ ហើយនិងបំបែកទៅជាផ្នែកតូចៗលម្អិត។ ក្បាលម៉ាស៊ីននៃការបំបែក ហើយនិងការដឹកជញ្ជូនបានចាប់ផ្តើមពីក្រសួងឃោសនាការនៅសណ្ឋាគារមនោរម្យ គឺឆ្លុះបញ្ចាំងគំរូដូចគ្នាទូទាំងប្រទេស។

[១១:០៣:២៣]

បក្សកុម្មុយនីស្តកម្ពុជាបានមោទនភាពអំពីឋាននុក្រម រចនាសម្ព័ន្ធអំណាចរបស់ខ្លួនថា មានវិន័យខ្ពស់ណាស់នៅក្នុងកងកម្លាំងរបស់ខ្លួន។ នួន ជា មិនមែនស្ថិតនៅក្រោមសម្ពាធអ្វីមួយទេ។ នៅពេលដែលគាត់ទទួលស្គាល់ថា មេដឹកនាំកំពូលរបស់របបសាធារណរដ្ឋខ្មែរ – សូមដកស្រង់ – "ត្រូវបានកម្ទេចនោះ" (សូមបិទទៅវិញ) អនុលោមទៅតាមបញ្ជារបស់មេដឹកនាំនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ នេះគឺជាការទទួលស្គាល់ដ៏ធំធេងអំពីការខូចខាតដែលគាត់បានបញ្ជាក់។ ដូចគ្នាដែរ ខៀវ សំផន មិនអាចលាក់អំពីថា មានការបញ្ជាឲ្យសម្លាប់ជនមហាក្បត់ទាំងប្រាំពីរ ហើយខ្លឹមសារ និងសម្តី ដែលធ្វើឡើង

នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ អំពីសុន្ទរកថាជោគជ័យនោះ។ ហើយយើងសូមបញ្ជាក់ថា បញ្ជាមួយ គឺមានតែសេចក្តីសន្និដ្ឋានមួយទេ ថាការកាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរ ដែលបានធ្វើឡើងទូទាំងទឹកដីកម្ពុជា មុន នៅ ហើយនិងបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥នោះ ត្រូវបានធ្វើឡើង អនុលោមទៅតាមបញ្ជាមកពីមជ្ឈិមបក្ស។

[១១:០៥:៥៩]

លោក លោកស្រីចៅក្រម ជាទីគោរព! ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតចូលទៅដល់ភស្តុតាងមួយដែលបង្ហាញអំពីការកាប់សម្លាប់។ យ៉ាងហោចណាស់មនុស្សរាប់រយនាក់ដែលជាទាហានលន់នល់ និងអ្នករដ្ឋការ លន់ នល់ នៅទួលពោធិ៍ជ្រៃនៅក្នុងខេត្តពោធិ៍សាត់ ក្នុងខែមេសា ឆ្នាំ១៩៧៥។ នេះជាព្រឹត្តិការណ៍ដែលជនជាប់ចោទទាំងអស់នេះត្រូវបានចោទប្រកាន់ពីបទល្មើសនោះ។ លោក លោកស្រី ភស្តុតាងបង្ហាញថាការកាប់សម្លាប់នេះកើតឡើងភ្លាមៗ បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាបានកាន់កាប់ខេត្តពោធិ៍-សាត់។ ការកាប់សម្លាប់នូវបុរសទាំងអស់នេះ ដូចដែលលោកបានជ្រាបហើយមិនមែនជាហេតុការណ៍ដាច់ដោយឡែកនោះទេ ហើយក៏មិនមែនជាអំពើនៃការសងសឹក ហើយក៏មិនមែនជាអំពើកើតឡើងដោយមេដឹកនាំភូមិភាគសាហាវដែលធ្វើតាមអំពើចិត្តនោះដែរ។ នេះគឺជាហេតុការណ៍ដែលបានបង្កប់នៅក្នុងគោលនយោបាយទូទាំងប្រទេស គឺគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីសម្លាប់អតីតមន្ត្រី និងទាហានរបប លន់ នល់ របបសាធារណរដ្ឋខ្មែរ។ វាមានទំនាក់ទំនងទៅនឹងខ្សែសង្វាក់នៃព្រឹត្តិការណ៍នៃការកាប់សម្លាប់ហើយបញ្ជាពីថ្នាក់លើដោយមជ្ឈិមបក្ស។

លោក លោកស្រីចៅក្រមជាទីគោរព! ទោះបីជាសាក្សីបីរូបមាន លឹម សាត, អ៊ុង ឆាត ហើយនិង ស៊ុម អាឡាត់ ដែលបានកោះអញ្ជើញមកធ្វើសក្ខីកម្ម មិនបានឃើញដោយផ្ទាល់ភ្នែកពីការកាប់សម្លាប់នៅទួលពោធិ៍ជ្រៃក៏ដោយ ប៉ុន្តែពួកគេបានផ្តល់ភស្តុតាងដ៏សំខាន់អំពីវិធីដែលការកាប់សម្លាប់នោះត្រូវបានធ្វើផែនការរៀបចំ និងគេបានចាត់ចែង។ ខ្ញុំនឹងរំឭកពីសក្ខីកម្មដោយសង្ខេបដើម្បីបង្ហាញពីវិធីណា ហើយមូលហេតុអ្វីបានជាមានការកាប់សម្លាប់បែបនេះ?

[១១:០៧:០៣]

លោក លោកស្រីចៅក្រម នឹងចាំអំពីសក្ខីកម្មរបស់ លឹម សាត ដែលបានធ្វើសក្ខីកម្មថា ពីរបីថ្ងៃបន្ទាប់ពីការរំដោះទីក្រុងភ្នំពេញគាត់បានចូលរួមកិច្ចប្រជុំ ដែលគណៈភូមិភាគបានបញ្ជាឱ្យមានការសម្លាប់ទាហាន នគរបាលសាធារណរដ្ឋខ្មែរ។ ហើយគេខ្លាចថាអ្នកទាំងនោះនឹងបះបោរប្រឆាំងនឹងពួកគេ។

គាត់បានបញ្ជាក់ថា ខ្មែរក្រហមបានប្រមូលនគរបាល ហើយនិងយោធា ហើយនិងអ្នករដ្ឋបាល រដ្ឋការនៅក្នុងកិច្ចប្រជុំមួយនៅក្នុងសាលាខេត្តពោធិ៍សាត់។ នៅក្នុងការប្រជុំនោះ គឺអ្នកចូលរួមគេបានប្រាប់ថាគេនឹងបញ្ជូនអ្នកទាំងនោះទៅវគ្គសិក្សា។ គាត់បានបញ្ជាក់ថា ភ្លាមៗបន្ទាប់ពីនោះគឺនគរបាល ហើយនិងទាហានត្រូវបានគេដឹកទៅទួលពោធិព្រៃដើម្បីសម្លាប់ចោល។ លឹម សាត បានបញ្ជាក់ថា តួនាទីរបស់គាត់គឺដើម្បីយាមផ្លូវធំដែលចេញពីពោធិ៍សាត់ទៅទួលពោធិ៍ព្រៃ។ ផ្លូវដែលគេយកទៅសម្លាប់ចោលនៅមន្ត្រីសាធារណរដ្ឋខ្មែរ នៅទីនេះ លឹមសាត បានឃើញថា មានឡានធំជាស៊ីវិល ប្រហែលជា៣០ ទៅ៤០នាក់បានដឹកទាហានលន់នល់ចេញពីប្រជុំដែលធ្វើឡើងនៅសាលាខេត្តនោះ។ ឡានទីមួយៗដឹក៣០នាក់។ នៅថ្ងៃដដែលនោះគាត់បានឃើញឡានយ៉ាងហោចណាស់១៥ បានដឹកទាហាន និងមន្ត្រីសាធារណរដ្ឋខ្មែរទៅទួលពោធិ៍ព្រៃ។ ម្តងមានឡានពីរ។ គាត់បានបញ្ជាក់ថា "មានប្រហែល -- យោធាខ្មែរក្រហមប្រហែល៥០ ទៅ ៦០នាក់នៅទួលពោធិ៍ព្រៃ ហើយគេបានជូនដំណឹងតាមវិទ្យុទាក់ទងថា ទាហាននិងអ្នករងគ្រោះដែលយកទៅនោះគឺត្រូវបានសម្លាប់"។ លឹម សាត បានឮស្នូរកាំភ្លើងនៅក្នុងពេលទំនាក់ទំនងទូរសព្ទ័ដោយទាហានខ្មែរក្រហមពីទួលពោធិ៍ព្រៃ។ នៅពេលដែលឡាននោះត្រឡប់មកវិញ ហើយមកតាមផ្លូវទៅពោធិ៍សាត់ដដែលនោះ ឡានទាំងអស់នោះគឺមកវិញទទេ។ បន្ទាប់ពីឡានមួយចំនួនបានចាកចេញ គេបានបញ្ជា លឹម សាត តាមវិទ្យុថាឲ្យឡានចេញតទៅទៀត ទៅកន្លែងគេកាប់សម្លាប់មនុស្សនោះ។ ដូច្នេះនេះគឺជាការពិតហើយដែលថា លឹម សាត មិនបានឃើញដោយផ្ទាល់ភ្នែកគាត់មែនពីការសម្លាប់មនុស្ស។ តើមានការសង្ស័យអ្វីពីសក្ខីកម្មរបស់គាត់ទេ ថាមន្ត្រីនិងយោធាទាំងឡានៗនោះដែលយកទៅពោធិ៍ព្រៃ ហើយត្រូវបានគេសម្លាប់នៅពេលនោះ? បើយើងនិយាយឲ្យច្បាស់ទៅលោកស្រីចៅក្រម សេចក្តីសន្និដ្ឋានដែលមានសមហេតុសមផលនោះដោយផ្អែក លើអង្គហេតុដែលធ្វើសក្ខីកម្មដោយ លឹម សាត នោះគឺថា ជនរងគ្រោះរាប់រយនាក់ត្រូវបានបក្សកុម្មុយនីស្តកម្ពុជាសម្លាប់នៅថ្ងៃនោះនៅទួលពោធិ៍ព្រៃ។ ហើយតាមពិត លឹម សាត មិនមែនជាសាក្សីតែម្នាក់ដែលនិយាយពីហេតុការណ៍នេះទេ។ លោក លោកស្រីចៅក្រមក៏បានឮសក្ខីកម្មរបស់របស់ អ៊ុំង ឆាត់ ដែលគេចាត់តាំងគាត់ឲ្យធ្វើជាអ្នកយាមនៅខាងក្រៅកន្លែងប្រជុំនោះ គាត់បានបញ្ជាក់ថា មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបានចូលរួមនៅក្នុងការប្រជុំនោះដែលមានរយៈពេលប្រហែលជាបីទៅបួនម៉ោង គាត់បាននិយាយថា៖ "អតីតអ្នករដ្ឋការស៊ីវិល ទាហានលន់ នល់ គឺទទួលការណែនាំពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាថា គេទទួលអ្នកទាំងនោះយកទៅរៀនសូត្រ"។ អ៊ុំង ឆាត់ បានបញ្ជាក់ពីសក្ខីកម្មដែលស៊ីសង្វាក់ជាមួយនឹងអ្នកបរឡានដឹកអ្នកទាំង

នោះទៅសម្លាប់ចោលនោះ ហើយត្រូវបានសម្អាសដោយលោក ថេត សម្បត្តិ អំពីខ្សែភាពយន្តទូល ពោធិ៍ជ្រៃ។ អ្នកបើកបរនោះនៅក្នុងវីដេអូនោះក៏បានបញ្ជាក់ថា គាត់ដឹងអំពីផែនការនេះក្នុងការសម្លាប់អ្នកទាំងនេះ ហើយគាត់បានពន្យល់ថា អ្នកដែលគាត់ដឹកនៅក្នុងឡាននោះគេបានបោកបញ្ឆោតអ្នកទាំងនោះ ហើយអ្នកនោះគិតថាគេត្រូវទៅជួបសម្តេចទេ”។

[១១:១១:២៨]

នៅទីបំផុតលោក លោកស្រីចៅក្រម យើងបានស្តាប់សក្ខីកម្មរបស់ ស៊ុម អាឡាត់ ជាទាហានលន់ នល់ ដែលបានបញ្ជាក់ថាគាត់បានចូលរួមប្រជុំដែលទាហានសាធារណរដ្ឋខ្មែរហ្នឹងបានទទួលដំណឹងថា គេនឹងយកទៅទួលពោធិ៍ជ្រៃដើម្បីគេឲ្យទៅទទួលអង្គការ។ សំណាងល្អគឺចំពោះ ស៊ុម អាឡាត់ គឺថាឡាននោះចង្អៀតពេក ដោយសារមានមនុស្សច្រើនពេកគាត់មិនអាចឡើងជិះឡាននោះទៅបាន។

ដូច្នេះ ទោះបីជាសេចក្តីលម្អិតដែលមាននៅក្នុងសក្ខីកម្មនៃសាក្សីទាំងបីនេះអាចនឹងខុសគ្នាបន្តិចបន្តួចក្តី ហេតុការណ៍ជាសំខាន់ទាក់ទងទៅនឹងការស្លាប់ ហើយស្លាប់ក្នុងទ្រង់ទ្រាយធំនៃអតីតទាហាន ហើយនិងមន្ត្រីលន់ នល់ គឺមានភស្តុតាងច្បាស់លាស់នៅក្នុងសក្ខីកម្មទាំងអស់រួមគ្នា។ ភស្តុតាងទាក់ទងទៅនឹងវិធីសាស្ត្រ ហើយនិងវិធីដែលកាប់សម្លាប់ដែលចេញមកពីអ្នកឃើញផ្ទាល់ភ្នែក ហើយនិងអដ្ឋិធាតុសល់នៅក្នុងទីកន្លែងនោះ។ អ្នកដែលត្រូវបានគេសម្លាប់ គឺមិនមានលទ្ធភាពការពារខ្លួនទេ គេចងដៃ ហើយគេបញ្ជូនទាំងក្រុមៗទៅទីនោះដើម្បីសម្លាប់។ គឺថា TCW-644 បញ្ជាក់ថាគាត់បានទៅកន្លែងសម្លាប់នោះគឺថា មួយថ្ងៃបន្ទាប់ពីការកាប់សម្លាប់នៅថ្ងៃទីដប់-- នៅខែមេសា ឆ្នាំ១៩៧៥ ហើយគាត់បានឃើញសាកសពដែលមានស្នាមត្រូវគ្រាប់កាំភ្លើងនឹងក្បាល នឹងទ្រូងផងផង។ គាត់បានបញ្ជាក់ថា ជនរងគ្រោះត្រូវបានគេចងពួរជាប់គ្នា ហើយចងស្លាបសេកទៅខាងក្រោយ។

[១១:១៣:១២]

អ៊ុំង ឆាត់ បានបញ្ជាក់ថា អ្នកភូមិប្រាប់គាត់ថា សាកសពទាំងអស់នោះត្រូវបានគេចងដៃ ហើយចងភ្ជាប់គ្នាជាខ្សែៗពី១៥ ទៅ ២០នាក់ក្នុងមួយចំណងនោះ។ កម្មាភិបាលខ្មែរក្រហមក្នុងខ្សែវីដេអូ ថេត សម្បត្តិ ដែលបានវត្តមាននៅក្នុងកន្លែងសម្លាប់នោះបានបញ្ជាក់ថា “នៅពេលដែលមន្ត្រីសាធារណរដ្ឋខ្មែរត្រូវបានគេដាក់ចេញពីឡាន គេប្រាប់ថាត្រូវចងដៃពីព្រោះគេត្រូវជួបសម្តេច ហើយគេមិនទុកចិត្តអ្នកទាំងនោះនៅឡើយទេ”។ គាត់និយាយបន្ទាប់ថា “បន្ទាប់ពីចងអ្នកនោះ ហើយគេយកទៅផ្នែកខាងក្រោយនៃស្រះមួយ ហើយបឹង ហើយគេសម្លាប់”។ ទាហានខ្មែរក្រហមម្នាក់ទៀតក៏បានបញ្ជាក់នៅក្នុងវីដេអូថា

"គាត់បានឃើញគេចងអ្នកទាំងអស់មុននឹងគេសម្លាប់"។ កម្មាភិបាលម្នាក់នៅក្នុងវីដេអូហ្នឹងបានបង្ហាញថា៖ "គេចងដៃជនរងគ្រោះហើយក្នុងមួយចំណងនោះមាន២០នាក់នៃជនរងគ្រោះ"។

ទាក់ទងទៅនឹងភស្តុតាងជាក់ស្តែងអំពីការសម្លាប់អតីតទាហាន និងមន្ត្រីសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃនៅថ្ងៃ -- នៅឆ្នាំ១៩៧៥ នៅខែមេសា នោះសំខាន់ណាស់។ កសិករនៅកន្លែងនោះនៅក្នុងឯកសារ ថេត សម្បត្តិ នោះគឺថានៅព្រឹកបន្ទាប់ពីការកាប់សម្លាប់នោះ គាត់បានឃើញសាកសព ហើយបានរៀបរាប់ថា៖ "គឺរួញក្រញង់ ហើយក្លិនស្អុយខ្លាំង ដោយសារសាកសពនោះរលួយ"។ សាក្សីម្នាក់ទៀតនៅក្នុងវីដេអូបានបញ្ជាក់ថា៖ "ភ្លាមៗបន្ទាប់ពីការកាប់សម្លាប់នោះ គាត់បានឃើញសាកសពហើមដូចប៉េងប៉ោងអ៊ីចុងដែរ"។

[១១:១៥:០២]

អ្នកបរទេះគោបានបង្ហាញភស្តុតាងទៅអ្នកស៊ើបអង្កេតរបស់ការិយាល័យចៅក្រមស៊ើបអង្កេត, នៅក្នុងឯកសារ E3/5234, គាត់ថា៖ "ប្រហែលជាមួយខែក្រោយពីការកាប់សម្លាប់គាត់បានឃើញស្នាមនៃការកាយ ហើយបានឃើញសាកសពនៅទីនោះ គឺ TCW-699 បានទៅទួលពោធិ៍ជ្រៃក្រោយពីខែមករា ឆ្នាំ១៩៧៩ ហើយបានឃើញគំនរអដ្ឋិធាតុ ហើយនិងឯកសណ្ឋានរបស់សាធារណរដ្ឋខ្មែរ ទាហានសាធារណរដ្ឋខ្មែរ ប្រហែលជារណ្តៅប្រាំ ឬប្រាំមួយនៅទីនោះ។ សាក្សីម្នាក់ទៀតដែលបានឆ្លើយទៅការិយាល័យសហចៅក្រមស៊ើបអង្កេត គឺ E3/5500 បានទៅទួលពោធិ៍ជ្រៃ ហើយបានឃើញឆ្អឹងដែលលៀនចេញមកពីគំនរដីនៅទីនោះ។

លោក លោកស្រីចៅក្រម! ទោះបីជា៣៥ឆ្នាំក្រោយមកក៏ដោយ អ្នកស៊ើបអង្កេតរបស់ការិយាល័យចៅក្រមស៊ើបអង្កេតអាចបានឃើញកម្ទេចឆ្អឹងឆ្អែង ហើយនិងកន្ទុះគ្រាប់កាំភ្លើង ក្បាលគ្រាប់កាំភ្លើង ហើយនិងរបស់លោហធាតុ ដូចជា ក្បាលខ្សែក្រវាត់ រូតខោអាវ ដែលស្ថិតនៅក្នុងលាយលំជាមួយដីនោះផង។ សំបកកន្ទុះទាំងអស់នោះត្រូវបានគេឃើញនៅពាសពេញទីកន្លែងនៃការសម្លាប់មនុស្សនោះឯង។

លោក លោកស្រីចៅក្រម ទាក់ទងទៅនឹងចំនួនជនរងគ្រោះដែលគេបានសម្លាប់នៅទួលពោធិ៍ជ្រៃ សាក្សីបីនាក់បានបញ្ជាក់នៅក្នុងអង្គជំនុំជម្រះថា ប្រហែលជាពី ២០០នាក់ ៥០០នាក់ ត្រូវបានដឹកតាមឡានពីសាលាខេត្តពោធិ៍សាត់ទៅទួលពោធិ៍ជ្រៃនៅថ្ងៃនោះ។

[១១:១៦:៥០]

ភស្តុតាងផ្សេងទៀតដែលបានបង្ហាញជូនលោកស្រីចៅក្រម គឺបានបង្ហាញថាមានជនរងគ្រោះច្រើនណាស់។ TCW-644 បញ្ជាក់ថា គាត់បានឃើញសាកសពចំនួន ១.០០០។ TCW-699 បានប្រាប់អ្នកអង្កេតថា បឹងនៅក្បែរទួលពោធិ៍ជ្រៃ គឺត្រូវបានបំពេញទៅដោយសាកសពប្រហែលជាមានប្រហែល ៥.០០០សាកសពឯណោះ។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលមកពីក្រុមកម្ទេច ដែលបានផ្តល់បទសម្ភាសន៍ទៅវីដេអូ ថេត សម្បត្តិ បានបញ្ជាក់ថា ប្រហែលជាមានជនរងគ្រោះ ប្រហែលជា ១០.០០០នាក់នៅឯទួលពោធិ៍ជ្រៃ។ ការបញ្ជាក់អំពីអដ្ឋិធាតុនៃបឹងធំមួយនៅទួលពោធិ៍ជ្រៃ គឺអ្នកអង្កេត អ.វ.ត.ក បានបញ្ជាក់នៅក្នុងពេលស៊ើបអង្កេតរបស់គាត់ពីទីសម្លាប់នោះ។ របាយការណ៍ដ៏ពិស្តារនោះ គឺស៊ីសង្វាក់ទៅនឹងសក្ខីកម្មរបស់សាក្សីថា មានបឹងមួយធំ ហើយនិងមានរណ្តៅដែលអាចដាក់សាកសពមនុស្សបានរាប់ពាន់នាក់។ នេះជារូបថតដែលបញ្ជាក់នៅក្នុងរបាយការណ៍នោះ ដែលថាបឹងមួយធំជាកន្លែងដែលគេសម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរនៅទីនោះ។ ស្លាយបន្ទាប់មកទៀត គឺជាផែនការ -- បាទ ផែនទីលម្អិតដែលបង្ហាញពីស្រះដែលបង្ហាញនៅក្នុងចំណុច ជី.ភី.អេស ចំណុចទី៣ នៅលើផែនទីនេះ ក៏អាចឃើញនៅចំណុចទី៤ ហើយនិងទី៥ផងដែរ។ ផ្លូវដែលគេដឹកអ្នកនោះតាមឡានទៅបឹងនោះ ដើម្បីសម្លាប់ពួកគេចោល។ ដឹកទៅស្រះនោះបាទ។

[១១:១៨:៤៣]

លោក លោកស្រីចៅក្រម អ្នកស៊ើបអង្កេតពិនិត្យទីកន្លែងកើតហេតុ គឺមិនផ្តល់អ្វីជាចម្លល់ទេ គឺគេបានបញ្ជាក់ប្រាប់គាត់ សាក្សីបញ្ជាក់ប្រាប់គាត់ថា ពិតជាកន្លែងសម្លាប់រង្គាលមែន។ ពួកគាត់បានពិនិត្យទីនោះបន្ទាប់ពីបានសម្ភាសសាក្សី ហើយសូមដកស្រង់៖ "ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានឃើញភស្តុតាងណាមួយនៅពេលនេះ ដែលថាហេតុការណ៍អ្វីមួយដែលមានទំហំដូចគ្នានេះបានកើតឡើង បន្ទាប់ពីការកាប់សម្លាប់នៅក្នុងឆ្នាំ១៩៧៥ នៅកន្លែងជាក់លាក់ទួលពោធិ៍ជ្រៃនេះឡើយ"។ សូមបញ្ចប់សេចក្តីដកស្រង់។

លោក លោកស្រីចៅក្រមជាទីគោរព! ចំនួនអ្នកដែលស្លាប់ពិតប្រាកដហ្នឹង គឺថានៅទួលពោធិ៍-ជ្រៃ នៅថ្ងៃ -- នៅខែមេសា ឆ្នាំ១៩៧៥ នោះមិនដឹងច្បាស់ទេ ប៉ុន្តែទោះជាយ៉ាងណាក្តីយើងមានភស្តុតាងបង្ហាញយ៉ាងច្បាស់ហួសពីសង្ស័យថា មានរាប់រយនាក់នៃជនរងគ្រោះរបបសាធារណរដ្ឋខ្មែរ ដឹកតាមឡានទៅទួលពោធិ៍ជ្រៃ ហើយត្រូវបានគេសម្លាប់នៅទីនោះក្នុងខែមេសា ឆ្នាំ១៩៧៥។

[១១:១៩:៥៧]

លោក លោកស្រីចៅក្រម! ខ្ញុំបានលើកអំពីសេចក្ដីយោងទៅវីដេអូ "មួយថ្ងៃនៅទួលពោធិ៍ជ្រៃ" ដែល ថេត សម្បត្តិ គាត់បានផលិតនោះ។ វីដេអូនេះស៊ីសង្វាក់ទៅនឹងសក្ខីកម្មដែលអង្គជំនុំជម្រះបានស្ដាប់ ហើយនិងចម្លើយដែលបានផ្ដល់ទៅឱ្យអ្នកស៊ើបអង្កេតរបស់ អ.វ.ត.ក។ ដើម្បីបញ្ចប់ផ្នែកនេះខ្ញុំសូមអនុញ្ញាតដើម្បីបង្ហាញវីដេអូខ្លីប្រាំបីមីនុត ដើម្បីបង្ហាញអំពីលក្ខណៈស៊ីសង្វាក់ដ៏មានទម្ងន់ធ្ងន់មួយនៅក្នុងភស្តុតាង ដែលសាក្សីបានបញ្ជាក់ជូនអង្គជំនុំជម្រះនៅក្នុងសវនាការរួចហើយនោះផងដែរ។ លោក លោកស្រីចៅក្រម វីដេអូនឹងប្រើពេលប្រហែលប្រាំបីនាទីបាទ។

[១១:២០:៥២]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*[(មិនស្គាល់អត្តសញ្ញាណ)៖ អ៊ីចឹងពេលនុំងម្នាក់ៗគេមានឈ្មោះ ចង់ទៅជួបសម្ដេចឪហ្នឹងដើម្បីប្រវែលកាឡុង ឃើញទេ! ចង់បានឋានន្តរសក្តិ។ អ៊ីចឹងអត់មានបណ្ដាសក្តិក៏ចេញទៅដែរ។ អ៊ីចឹងបានខ្ញុំចង់និយាយថា ស្ដាប់ច្រើនអីច្រើនហ្នឹងគឺមូលហេតុអ៊ីចឹង។ អាខ្លះហ្នឹងអត់ទាហានសុទ្ធសាធផងទេ តែទិញស័ក្តិ ហើយស័ក្តិនៅផ្សារខ្វះអី អាកាច់ជ្រុងផ្លូវមាត់ស្ទឹងពោធិ៍សាត់នេះ។ អាផ្លូវកាច់ជ្រុងចូលផ្សារអ៊ីចេះ នៅខាងណេះ លក់ស័ក្តិមួយជួរនុំងទាំងអស់។ គេកំពុង បញ្ហាហ្នឹងក៏នៅលក់ស័ក្តិនៅឡើយទេ។ ដល់ថ្ងៃទី៣ បាន១គេបាចលុយចោលពេញហ្នឹងទៅ គេមិនចាយលុយចាយអី បានដឹងខ្លួនលែងលក់លែងអី។*

*(មិនស្គាល់អត្តសញ្ញាណ)៖ គេប្រាប់ទៅ ពីរថ្ងៃគេប្រជុំប្រាប់ ថាយើងក្រោកពីងងឹតម៉ោងបួនជួបជុំគ្នា ឆាប់ក្រោកជួបជុំគ្នាឡើងឡានទៅវ៉ៃពាមជ្រៃអ៊ីចឹង គេថាអ៊ីចឹង។ ដល់ពេលម៉ោងបួនហ្នឹងនាំគ្នាដើបដើបទៅជុំគ្នាទាំងអស់ គេឱ្យឡើងឡាន។ ឡើងជិះពីពោធិ៍សាត់ហ្នឹងមក មកដល់ពាមជ្រៃហ្នឹងវាភ្លឺស្រាងៗ--។*

*(មិនស្គាល់អត្តសញ្ញាណ)៖ កាលហ្នឹងអាប៊ុត្ថឹមគេឡើងប្រកាសលើប្រឡូកូស។ អាប៊ុត្ថឹម ហ្នឹងគេវរសេនាធំអង្គាល់ហ្នឹង។ គេឡើងលើប្រឡូកូសហ្នឹង គេដាក់មីក្រូនិយាយបណ្ដោយហ្នឹង គេនិយាយប្រកាសយកទ័ពយកមកតម្រៀបមនុស្ស ចុះទាំងយើងផងទាំងតំបន់ផង វាជាប់១៨ផង ១៩ផង វាចូលចង់១០០០នាក់ ការពារហ្នឹង។ ហើយពួកខ្ញុំហ្នឹងគេឱ្យរៀប គេប្រជុំហើយកងការពារ គេហៅពួកខ្ញុំពួកការពារណ៎ះ។ ហើយពួកការពារហ្នឹង បើសិនជាមានការថ្លោះធ្លោយរួច -- គេប្រាប់ត្រង់ បើសិនជាអ្នកកម្មេចរួច គឺយើងអ្នកការពារហ្នឹងធ្វើម៉េចកុំឱ្យរួច តែរួចគឺបែកការណ៍ ខូចផែនការរបស់យើង។*

*ស្រាប់តែដល់ថា ម៉ោងប្រាំពីរហើយហ្នឹងឮស្នូរស្នូរឡានមក អាហ្នឹងឡានធំមកមុន ដំបូងឡានធំ។ ឮស្នូរឡានធំហ្នឹងងឺតៗៗមកអ៊ីចឹង គេប្រាប់ថា "កងពិសេសប្រុងប្រៀប!"។]*

[១១:២៣:២០]

*[(មិនស្គាល់អត្តសញ្ញាណ)៖ ថ្ងៃទី៣ហ្នឹងត្រូវដឹកមនុស្សចេញទៅៗពោធិ៍ជ្រៃហើយ។ ប៉ុន្តែយើងដឹងស្ថានការណ៍ហើយថាយកទៅហ្នឹងមិនមែនយកទៅធ្វើអីទេ ពីព្រោះយើងដឹងផែនការថាគេត្រូវកម្ទេចហើយ ព្រោះសុទ្ធអ្នកសំខាន់ៗ។ គេដឹងថា អ៎! ឃ្លាតពីម៉ាដាមមួយយប់ពីរយប់យ៉ាងយូរ ក្រោយពីបានជួបសម្តេចឪហើយមកកាន់ការងាររៀងៗខ្លួន។ អ៊ីចឹងគេនិយាយអ៊ីចឹង គេអត់មានព្រួយបារម្ភពីបញ្ហាថាយ៉ាងណាៗ អត់ទេ។ ហើយគេនិយាយលេងធម្មតា លលេងគ្នាគេហ្នឹងៗ។ "ម៉ាដាមឯងបានស្អីដាក់មក?" អ៊ីចេះមួយអ៊ីចេះពីរអ៊ីចឹងទៅ។ តែតឹនុយស៊ីវិលទេណ៎ា ថៅហ្វាយខេត្តតឹនុយស្លៀកសពាក់សហ្នឹង ពាក់មួកស្លឹកត្នោត។ ធ្វើរបៀបគេហៅថាសាមញ្ញ។ ចុះខ្មែរក្រហមស្លៀកខោរឹតអាវខ្មៅ បង់កន្សែងនៅលើ-កអ៊ីចឹងគេអាររបៀបកសិករដែរ។ គេស្លៀកខោអាវសាមញ្ញអ៊ីចឹងទៅ គេពាក់មួកស្លឹកត្នោតអ៊ីចឹងដែរទៅ។ លេងសើចធម្មតាអ៊ីចឹងទៅក្នុងឡានទុំង បង្កើតបរិយាកាសឪរីករាយ ដូចអត់មានអ្វីសម្រាប់គេហៅថានៅពេលខាងមុខហ្នឹងវាមានវិបត្តិយ៉ាងម៉េចៗ អត់ដឹងខ្លួនទេ។*

*(មិនស្គាល់អត្តសញ្ញាណ)៖ ចុះពីលើឡាន គេភ្លង់មក គេប្រកាស គ្រាន់តែឡានឈប់ដល់គេប្រកាស។ គេប្រកាសមីក្រូថា "ឲ្យសមមិត្តយើងកុំភិតកុំភ័យអី" ប្រាប់បណ្តាទាហានហ្នឹងណ៎ះ! ពេលទៅជួបអង្គការ អង្គការយើងអត់ទុកចិត្តទេ ព្រោះយើងនៅជាប់សមាសភាពទៅជួបសម្តេច គេថាអ៊ីចឹង ទាល់តែចង។ បានមួយៗចងអស់បណ្តើរទៅ ចងអស់មួយឡានបណ្តើរទៅ អស់មួយឡានបណ្តើរទៅ។*

[១១:២៥:០១]

*(មិនស្គាល់អត្តសញ្ញាណ)៖ រួចចុះ បើយើងដាក់ស្តែងហើយថា វាលែងអ៊ីចឹង ដូចថា ផ្ទង! ខាងហ្នឹងមួយទៅ ផ្ទងៗៗ ព្រួសៗ។ ហើយបើខួរក្បាលមនុស្ស ដូចថាផ្ទងៗទៅ បាចឆាវ អាឈាមហើយនិងខួរហ្នឹងវា ស ហើយក្រហមហ្នឹង មើលទៅ (ឮមិនច្បាស់)។ វាមិនបាញ់ពាសវាលទេ អ៊ីចឹងអាពួកឡានមកឃើញហើយ អ៊ីចឹងវាចូលក្នុងស្រះហ្នឹងមើលអត់ឃើញទេ។ ដីវាជ្រៅ ប្អូនឯងទៅឃើញហើយ។ ចូលអ៊ីចឹងទៅ អាឡាននៅឯណោះ មើលអត់ឃើញទេ។ ដល់លើទួលហ្នឹង ដល់មាត់ទួលហ្នឹងបានមើលឃើញខ្មោចបណ្តោយ ដល់លើទួលហ្នឹងមើលទៅ ឃើញខ្មោចនៅក្នុងរណ្តៅហ្នឹង បានវាស្រែក*

យំ បានទន់ដៃទន់ជើងហ្នឹង។ អាហ្នឹង វាអ៊ីចឹងពួកហ្នឹង។ មានអាខ្លះវាៗជេរទៀត វាជេរថា "ទមិឡអត់សាសនា អាតិរច្ឆាន អាអីអ៊ីចឹង" អាណាវានៅចាំស្មារតី គ្រាន់តែវាជិតឃើញខ្មោច គ្រាន់តែឃើញខ្មោចវាជេរតែម្តង ប៉ុន្តែអាខ្លះអត់ទេ អត់មាននិយាយអីកើត ដើរក៏មិនរួចផង។ គេវ៉ៃគេទាត់អីទៅ បានទៅដល់កន្លែងហ្នឹង។ ក្រោយទៀត ដូចនឹកឃើញនៅថ្មីកន្លែងសម្លាប់មនុស្ស ដូចនៅថ្មីៗ។

លាក់ការណ៍ សម្លាប់តែនៅក្នុងស្រះហ្នឹងទាំងអស់ទេ ប៉ុន្តែរកកន្លែងដាក់មិនបាន។ ដាក់មិនបានបានមកក្រោយ វាច្រើនពេកនៅក្នុងស្រះ ដាក់វាពេញនោះ។ គេបាញ់ ខ្ញុំឈរហ្នឹង -- មុនដំបូងគេបាញ់អ៊ីចេះ តម្រៀបដាក់មុខទៅនោះ ឲ្យលុតជង្គង់បែរមុខទៅនោះ។ អាខ្លះក៏បែកក្បាល អាខ្លះក៏រយះរយែងនេះរួច ចុះគ្រាប់កាំភ្លើង វាពិបាកមើលណាស់។ ហើយគ្រាន់តែឈរអ៊ីចឹង ឆ្អាបនៅឈរអត់បានយូរទេ ឈរមើលអត់បានយូរទេ ទាល់តែដើរនៅខាងនោះ ចេះទៅនៅពីលើខ្យល់អ៊ីចឹងគ្រាន់ណ៎។ បើថានៅជិតអ៊ីចឹងទៅ ឆ្អាបនៅអត់បានទេ។ បង (ឮមិនច្បាស់)។ សៈ ហើយបងឯងដើរតាមនេះ? ឆៈ ខ្ញុំ? ដល់ពេលថ្ងៃល្ងាច? សៈ នេះអា--, ឆៈ អ៎! អាដើរពីព្រឹក? បាទ កាលពីព្រឹកសាកសពមានតែក្នុងស្រះ និងពីលិចស្រះទេ ដល់ពេញស្រះវាដាក់ខាងលិច។ ដល់ថ្ងៃល្ងាច ខ្ញុំដើរមក ដល់ថ្ងៃចាប់ពីម៉ោងបួន ខ្ញុំដើរវិញ វារំសាយហើយ រំសាយកន្លែងផ្ទះត្រៀម។ ដល់ដើរមក តាមហ្នឹងសុទ្ធតែសាកសព ពីកើត ពីត្បូង ពីជើងអី សុទ្ធតែសាកសពជុំវិញទាំងអស់ ហើយខ្ញុំដើរក្បែរចុងខាងត្បូងនោះ អែបរបងណោះ ក្បែររបង។ អាតាមនេះ ដើរមិនរួចទេ នៅសុទ្ធតែសាកសព។ ម្ល៉ោះហើយដើរអែបរបង កន្លែង អាកន្លែងប្រឡូកូស ឡើងកន្លែងឡាន ទៅជុំគ្នាឡាន។ សៈ អ៊ីចឹងបងឯងចង់មកកន្លែងនេះដែរ ប៉ុន្តែសាកសពពេញ? ឆៈ សាកសពពេញ ដើរអត់រួចទេ។ ពិបាកដើរនឹងសាកសព ម្ល៉ោះហើយដើរទៅឯណោះ។ ទៅឡើងទៅជុំគ្នាឯណោះ។

ពួកកងរទេះ សួរអាទ្រី អាទ្រីជាអ្នកបាញ់ហ្នឹង។ វាថា "ពួកនាយទាហានដែលគេយកមកកម្ទេចហ្នឹង ប៉ុន្មានវី? គេថា ខ្ទង់ជិត១០.០០០នាក់ដែរហ្នឹង។ សៈ ចុះបង ដែលៗខ្មោចដែលបងមើលឃើញស្លាប់នៅហ្នឹង ចំនួនប្រហែលប៉ុន្មាន តាមបងមើលឃើញស្ថានភាពនៅហ្នឹង បាទ ដែលតាមបង? ឆៈ បាទ ច្រើន មើលទៅវាច្រើនពេញវាលអ៊ីចឹង។ មិនដឹងថាប៉ុន្មាន តែតាមគេនិយាយប្រហាក់ប្រហែលជាសួរអ្នកដែលធ្វើហ្នឹង ខ្ញុំសួរអ្នកដែលគេអ្នកធ្វើឃាតហ្នឹង តាបុល ដែលគេចាត់តាំងឲ្យធ្វើកងរទេះកងអីហ្នឹង ខ្ញុំសួរ "ប្រហែលប៉ុន្មាន បុល ខ្លាំង? ខ្ញុំនិយាយអ៊ីចឹង។ ខ្ញុំថា ប្រហែលប៉ុន្មានទៅ បុល? បុល ថា "បើខ្វះពីម៉ឺន ក៏ខ្វះមួយពាន់ដែរ គេនិយាយអ៊ីចឹង ខ្វះពីម៉ឺន ខ្វះមួយពាន់។ សៈ ខ្ញុំសូមមានប្រសាសន៍បន្តិច

*ដែលតាមបងសួរអ្នកណា? សួរថាយ៉ាងម៉េច ក្រោយពីបាញ់ហើយ? ឆ៖ មិនសួរពេលកន្លែងបាញ់ទេ ដល់ពេលយើងមកសម្រាកពេលហូបបាយថ្ងៃល្ងាច។ មកឡានគេដឹកមកដល់ខេត្តវិញហើយ។ ខ្ញុំសួរ "អ្ហែ! បុល ប្រហែលជាប៉ុន្មាន មើលដូចក្រាលពេញវាលទាំងអស់។ ខ្ញុំនៅក្រៅមិនដឹង។ វាថា ប្រហែលជា -- វាថាតាមវាធ្វើ បើគិតទៅប្រហែលជាថា ធុនតូច ត្រឹមពី៨000 គឺថាក្រោយពីម៉ឺន យ៉ាងច្រើន ១000 វានិយាយអ៊ីចឹង"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១១:២៩:៣៦]

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមជម្រាបថា ភស្តុតាងដែលខ្ញុំដាក់ជូនចំពោះលោក ទាក់ទងទៅនឹងការសម្លាប់ផ្តាច់ផ្តិល និងមនុស្សឃាតទៅលើអតីតទាហាន លន់ នល់ និងរដ្ឋការលន់ នល់ និងគួរឲ្យជឿជាក់។ យើងបានស្តាប់សវនាការលើសក្ខីកម្មដែលបង្ហាញពីអង្គហេតុសំខាន់ៗ ព្រឹត្តិ-ការណ៍ដែលពាក់ព័ន្ធទៅនឹងមនុស្សឃាត ហើយនិងចម្លើយរបស់សាក្សី ដែលបញ្ជាក់អំពីសេចក្តីលម្អិតជាក់លាក់ ដែលមានលក្ខណៈស៊ីសង្វាក់ទៅនឹងភស្តុតាង កោសល្យវិច័យពីអ្នកស៊ើបអង្កេត ជាពិសេសយើងមានរឿងរ៉ាវដ៏គួរឲ្យជឿជាក់អំពីកម្មាភិបាលខ្មែរក្រហម ដែលពាក់ព័ន្ធនឹងការកាប់សម្លាប់ ដែលសារភាពថាខ្លួនបានប្រព្រឹត្តនូវបទឧក្រិដ្ឋនេះផងដែរ នៅក្នុងខ្សែវីដេអូ "មួយថ្ងៃនៅទួលពោធិ៍ជ្រៃ"។

លោក លោកស្រីចៅក្រម! ភស្តុតាងក៏បានបង្ហាញផងដែរថា កាប់សម្លាប់នៅទួលពោធិ៍ជ្រៃ នៅខែមេសា ឆ្នាំ១៩៧៥ ត្រូវបានអនុវត្តស្របទៅតាមគោលនយោបាយរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាកំណត់ទៅលើអតីតយោធា និងអ្នករដ្ឋការសាធារណរដ្ឋខ្មែរ។ លឹម សាត បានបញ្ជាក់យ៉ាងច្បាស់ថា មេបញ្ជាការវរសេនាធំរបស់គាត់បានប្រាប់គាត់ អំពីបញ្ជាឲ្យសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ជនរងគ្រោះនៅទួលពោធិ៍ជ្រៃនោះត្រូវបានមានបញ្ជា។ ខ្ញុំដកស្រង់៖ "ពីព្រោះខ្មែរក្រហមខ្លាចថា ទាហាន និងប៉ូលិសទាំងអស់អាចនឹងងើបបះបោរប្រឆាំងនឹងខ្មែរក្រហម" សូមបញ្ចប់សេចក្តីដកស្រង់។ ការអះអាងនេះគឺជាមូលហេតុដូចគ្នាបេះបិទទៅនឹងដូចអ្វីដែល អៀង សារី បានបញ្ជាក់ដែលគាត់ជាសមាជិក គណៈអចិន្ត្រៃយ៍ដែលថា បញ្ជាក់ប្រាប់ ស្ទីវ ហេដឌ័រ *(Stephen Heder)* ថាគោលនយោបាយនេះដូចគ្នាដែរ។ គាត់និយាយថា ពួកគេបក្សកុម្មុយនីស្តកម្ពុជា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា សម្រេចធ្វើអ្វីគ្រប់យ៉ាងដែលចាំបាច់ដើម្បីកុំឲ្យក្រុមនេះងើប ហើយនិងប្រឆាំងនឹងបដិវត្តន៍បាន។ លោក ខៀវ សំផន ខ្លួនឯងក៏បានបញ្ជាក់ដែរនៅក្នុងបទសម្ភាសន៍ពីមុនថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមានការភ័យខ្លាចអំពីពួក

ដែលសេសសល់មកអំពីទាហានលន់នល់ ទូទាំងភ្នំពេញនោះអាចមកពាសពេញប្រទេស ហើយអាចនឹងងើបឡើងក្នុងការបះបោរ។

[១១:៣២:១១]

លោក លោកស្រីចៅក្រម ការកាប់សម្លាប់នៅទួលពោធិជ្រៃមិនមែនជាហេតុការណ៍ដាច់ដោយឡែកនៃការសងសឹកដូចដែលមេធាវី នួន ជា -- ដែលលោកនួន ជា បានបញ្ជាក់នោះទេ។ ហើយមិនមែនជាបទឧក្រិដ្ឋរបស់ស្តេចត្រាញ់ ស្វយ័តនៅក្នុងភូមិភាគពាយ័ព្យទេ។ ការកាប់សម្លាប់នៅទួលពោធិ៍ជ្រៃដូចនឹងការកាប់សម្លាប់ផ្សេងទៀត នៅទីកន្លែងផ្សេងៗទៀតទូទាំងប្រទេសកម្ពុជា គឺជាលទ្ធផលនៃសេចក្តីសម្រេចដែលបានធ្វើ ហើយនិងគោលនយោបាយដែលបានបង្កើតឡើងដោយមេដឹកនាំមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។

លោក លោកស្រីចៅក្រម ប្រសិនបើយើងផ្អាកត្រង់ចំណុចអម្បាញ់មិញបន្តិចហើយនៅពេលនេះខ្ញុំសូមចូលទៅដល់សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាបង្ហាញអំពីការទទួលខុសត្រូវឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា និងវិធីទាំងឡាយដែលឧក្រិដ្ឋកម្មកើតចេញពីចំណុចទាំងអស់នោះ។ ហើយយើងខ្ញុំនឹងលើកឡើងអំពីបញ្ហានៃការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន ចំពោះបញ្ហាទាំងអស់នេះ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលនីមួយៗចំពោះគោលនយោបាយឧក្រិដ្ឋ និងឧក្រិដ្ឋកម្មនានានោះត្រូវបានចោទប្រកាន់នៅក្នុងការជំនុំជម្រះនេះ។

[១១:៣៣:៤៥]

លោក លោកស្រីចៅក្រមជាទីគោរព ភស្តុតាងបង្ហាញថា នៅពីក្រោយទឹកមុខដ៏ស្រស់ស្រាយនិងញញឹមញញែមរបស់ ប៉ុល ពត គឺចិត្តគំនិតរបស់មួយក្រុមតូចដែលនៅក្នុងនោះរួមមានជនជាប់ចោទ នួន ជា និង ខៀវ សំផន ដែលពួកគេត្រៀមខ្លួនរួចជាស្រេច ធ្វើអ្វីឲ្យតែបានដើម្បីសម្រេចចក្ខុវិស័យផ្តាច់ការ ឬទស្សនៈផ្តាច់ការរបស់ពួកគេមកលើប្រទេសកម្ពុជា។ នួន ជា និង ខៀវ សំផន ព្រមទាំងដៃគូឧក្រិដ្ឋរបស់ពួកគេគឺជាចៅហ្វាយ ហើយប្រជាជនកម្ពុជាគឺជាទាសករ។ ពួកគេគឺជាជនផ្តាច់ការដែលគ្រប់គ្រងប្រជាជនកម្ពុជាតាមរយៈកម្លាំងដ៏ឃោរឃៅនិងការភ័យខ្លាច។ ជាសោកនាដកម្ម សកម្មភាពរបស់ពួកគេក្នុងការដកហូតភាពជាមនុស្សរបស់ប្រជាជនទាំងអស់ តាមរយៈការបំពានអំណាចរបស់ក្រុមរបស់ពួកគេមួយក្រុមតូច មិនមែនជាសកម្មភាពដំបូងបំផុតនៅក្នុងប្រវត្តិសាស្ត្រពិភពលោកនោះទេ។ របបផ្តាច់ការដែលកើតឡើងរាប់រយឆ្នាំមកហើយ ត្រូវបានប្រើប្រាស់មនុស្សជាឧបករណ៍ ដើម្បីផ្តល់

លទ្ធភាពឲ្យពួកគេទទួលបាន និងរក្សាអំណាច និងការគ្រប់គ្រងដាច់ខាត។ ពួកគេធ្វើដូច្នេះដើម្បីសម្រេចនូវទស្សនៈតែមួយរបស់គេ គឺមានតែទស្សនៈមួយគត់របស់ពួកគេដែលនឹងត្រូវសម្រេចបាន។ នួន ជា និង ខៀវ សំផន បានសម្លាប់ បានកាប់សម្លាប់ ដើម្បីអំណាច ពួកគេបានព្រោះឈាម ដើម្បីអំណាច។ ពួកគេប្រព្រឹត្តអំពើឃោរឃៅ និងបន្ទាបបន្ថោក ប្រជាជនរបស់ខ្លួន ហើយនៅតែបន្តបៀមឈាមព្រោះដើម្បីអំណាច។

[១១:៣៦:០៥]

គ្មានអ្វីដែលប្រិមប្រិយចំពោះឈាមទាំងអស់នោះទេ ឈាមទាំងអស់នេះបង្ហាញនូវការឈឺចាប់ ទុក្ខវេទនា ការភ័យខ្លាច និងការស្លាប់។ ឈាមនេះជាសម្រែករបស់ជនរងគ្រោះដែលត្រូវគេបាញ់សម្លាប់ ដែលត្រូវគេកាប់សំពងផ្តាច់ជីវិត ធ្វើទារុណកម្ម បង្អត់អាហារ និងបង្ខំឲ្យធ្វើការរហូតដល់ស្លាប់។ ជាញឹកញាប់ទៅគឺពួកគេទទួលរងបញ្ហាទាំងអស់នេះក្នុងការឈឺចាប់ដែលមិនអាចឲ្យយើងនឹកស្មានបាន។ ឈាមទាំងអស់នេះគឺជាការបាត់បង់ជីវិតមនុស្ស វាតំណាងឲ្យនូវបេះដូងឈឺចាប់របស់ឪពុកម្តាយ ដែលពុំដែលធ្លាប់ឃើញកូនរបស់គាត់ធំធាត់ទៀតនោះទេ ហើយវាតំណាងនូវការឈឺចាប់របស់ប្រជាជនកម្ពុជាដែលមានម្តាយ ឪពុក ប្តី ប្រពន្ធ មិត្តភក្តិប្រុស មិត្តភក្តិស្រី បងប្អូនប្រុស បងប្អូនស្រី មិនដែលវិលត្រឡប់មកផ្ទះវិញជារៀងរហូត។ ឈាមដែលពួកគេបៀមព្រោះនេះ ក៏ជាតំណាងនូវភាពសោកសៅ នូវភាពស្មោគរោគ ភាពក្រោធក្រោធ និងភាពអមនុស្សធម៌ចំពោះអំពើនៃការកាប់សម្លាប់មនុស្សជាតិផ្សេងទៀត។

ឈាមនេះតំណាងនូវស្នាដៃនៃអ្នកកាប់សម្លាប់។ គឺពួកក្មេងប្រុសៗដែលត្រូវបានគេបញ្ជាឲ្យកាប់សម្លាប់អ្នកជិតខាងរបស់ខ្លួន។ ជនរងគ្រោះដែលត្រូវបានគេចងបិទភ្នែក ដែលត្រូវបានគេចងដៃ ហើយ និងការជីកនូវរណ្តៅ ការកាប់សំពងសាកសព ការកម្ទេចនូវលលាដ៍ក្បាល ការកប់សាកសព និងការបោសសម្អាត គឺជាការងាររបស់ពួកពេជ្ឈឃាដ។ គឺពេជ្ឈឃាដដែលកាប់សម្លាប់តែមនុស្ស។ ឈាមនេះគឺជាឈាមដ៏អាក្រក់ ហើយមិនអាចតំណាងនូវទម្រង់ជីវិតរស់នៅរបស់យើងនោះឡើយ។ នៅពេលយើងធ្វើទារុណកម្មនរណាម្នាក់រហូតដល់ស្លាប់ យើងត្រូវតែឈរឲ្យនៅកៀកគេបំផុត ដើម្បីធ្វើឲ្យពួកគេមានការឈឺចាប់ ប៉ុន្តែទោះបីជានៅពេលយើងនៅកៀកពួកគេក៏ដោយ ពួកយើងក៏អាចមើលឃើញភ្នែករបស់ជនរងគ្រោះ ការភ័យខ្លាចក្នុងទឹកមុខរបស់ពួកគេ ហើយនិងភាពមិនគួរឲ្យជឿរបស់ពួកគេនូវអ្វីដែលកើតឡើងចំពោះខ្លួន។ នៅពេលដែលយើងរៀបចំជនរងគ្រោះនរណាម្នាក់យកទៅសម្លាប់ចោល យើងនឹងមើលឃើញភ្នែករបស់គេ។ នៅពេលមនុស្សម្នាក់សូមអង្វរយើងឲ្យទុកជីវិតរបស់ពួកគេ យើង

នឹងមើលឃើញភ្នែករបស់ពួកគេ។ នៅពេលដែលយើងគ្រវីដំបង ព្រនង់ ហើយលើកឡើងខ្ពស់ ដាក់ពីលើក្បាលរបស់ពួកគេ យើងនឹងឃើញភ្នែករបស់ពួកគេ។ មើលឃើញភ្នែករបស់ជនរងគ្រោះដែលយើងនឹងសម្លាប់ គឺវាធ្វើឲ្យយើងពិបាកសម្លាប់គេណាស់។ ហើយប្រសិនបើយើងមើលឲ្យកៀកជាងនេះទៀតនោះ យើងនឹងឃើញខ្លួនឯង យើងនឹងឃើញភាពមនុស្សធម៌របស់យើងនៅក្នុងក្រសែភ្នែករបស់ពួកគេ។

[១១:៣៩:៥៥]

នួន ជា និង ខៀវ សំផន ជ្រើសរើសមិនសម្លឹងមើលក្រសែភ្នែករបស់ជនរងគ្រោះរបស់ពួកគេនោះឡើយ ពួកគេជ្រើសរើសមិនមើលឃើញនូវមនុស្សធម៌របស់ជនរងគ្រោះ។ ការធ្វើដូច្នេះដើម្បីឲ្យពួកគេមានភាពងាយស្រួល។ បានន័យថា មនុស្សធម៌របស់ពួកគេគឺគេជំរុញនឹងលើកទឹកចិត្ត និងបញ្ជាឲ្យអ្នកដទៃធ្វើការងារកាប់សម្លាប់។ ប្រសិនបើអ្នកទាំងពីរនេះមើលក្រសែភ្នែករបស់ជនរងគ្រោះ ពួកគេនឹងមិនប្រាកដថា កេះកៃកាំភ្លើង គ្រវីពូថៅ ចងពួកគេ ឬក៏ជីករណ្តៅសម្រាប់ពួកគេនោះទេ។ ជនទាំងពីរបានបញ្ជាឲ្យអ្នកដទៃធ្វើការងារ ការងារដ៏ស្មោកគ្រោកទាំងនេះ។ ពួកគេបានប្រគល់ការងារដ៏អមនុស្សធម៌របស់ពួកគេ ដើម្បីឲ្យពួកគេមើលឃើញទៅមានលក្ខណៈមនុស្សធម៌ជាងអ្នកដទៃ។ អ្វីៗទាំងអស់នេះគឺដើម្បីចក្ខុវិស័យ និងទស្សនៈរបស់គេដែលមិនអាចខ្វះបាន និងមិនឈប់ឈរនៅក្នុងការបង្កើតសង្គមមួយដែលគេចង់បាន។ ជនទាំងពីរនេះបានប្រើប្រាស់ប្រជាជនកម្ពុជា ដើម្បីសម្លាប់ប្រជាជនកម្ពុជាខ្លួនឯង។ ពួកគេប្រើជនជាតិខ្មែរឲ្យសម្លាប់ជនជាតិខ្មែរខ្លួនឯង។ ពួកគេលេងសើចជាមួយនឹងចិត្តគំនិតនិងរូបរាងកាយរបស់ប្រជាជនកម្ពុជា។ ពួកគេលេងសើចជាមួយនឹងជនរងគ្រោះទាំងអស់នេះ ដូចប្រើប្រាស់ត្រីនៅក្នុងក្តារអុក ហើយបណ្តាលឲ្យមនុស្សជាច្រើននាក់ស្លាប់រាប់រយ រាប់លាននាក់ស្លាប់។ អ្នកត្រូវតែសម្លាប់គេ បើសិនមិនសម្លាប់ទេនោះ គេនឹងសម្រេចទៅលើអ្នក។

លោក លោកស្រីចៅក្រមជាទីគោរព! បុរសមួយរូបដែលលោក លោកស្រីចៅក្រម នឹងមើលឃើញនៅក្នុងខ្សែវីដេអូ នេះនឹងរៀបរាប់ឲ្យយើងនឹកឃើញឡើងវិញអំពីសោកនាដកម្មទុក្ខសោកការឈឺចាប់របស់ជនរងគ្រោះមួយរូប និងរៀបរាប់អំពីលក្ខណៈសាហាវយង់ឃ្នងនៃការងាររបស់ពួកពេជ្ឈឃាដ។ បុរសនៅក្នុងខ្សែវីដេអូនេះ ឲ្យយើងនឹកឃើញអំពីការបាត់បង់នៅមនុស្សធម៌របស់យើង ហើយថាតើវាកើតឡើងដោយរបៀបណា? បុរសរូបនេះនឹងឲ្យយើងគិតថា តើយ៉ាងគួរដាក់កំហុសនៃការកាប់សម្លាប់ដ៏សោកសៅនេះទៅលើនរណា? ខ្ញុំសូមអនុញ្ញាតចាក់បញ្ចាំងនូវខ្សែវីដេអូនេះ។

[១១:៤២:៤៥]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*[ស៖ អង្គាល់បងឯងនឹកឃើញស្រីនុំងម៉េច? នារីដែលសួរមកបងឯង? ឆ៖ នារីហ្នឹងមុខវាស្តើង មុខតូច មុខរាងច្រឹបៗនារីហ្នឹង មុខវែង។ ស អ៎! គួរសមដែរមនុស្ស។ មនុស្សស្អាតណាស់បាទ ហើយគេមកពីកាត់ដេរវាមានទៅសាច់គេអន់អីដូចយើងអ្នកស្រែ។ គេកាត់ដេរវានៅម្តប់នៅអីវាចេះតែស្អាត។ បាទ បញ្ចូនចុងខ្សែចុងក្រោយ វាអស់ហើយ ប៉ុន្តែវានៅមួយហ្នឹង។ ដល់មកនៅមួយហ្នឹង។ អ៊ីចឹងវាមកឱបជើងខ្ញុំហ្នឹង ដល់កាលណាវាមកឱបជើងខ្ញុំអ៊ីចឹង វាសុំខ្ញុំថា “ពូអើយពូ ខ្ញុំសុំនៅជាមួយផង។ បាទ ខ្ញុំសុំនៅជាមួយផង”។ បានខ្ញុំនិយាយថា “នៅជាមួយអញអាម៉េចអ្នុះ! បើត្រូវអ៊ីចឹងទៅហើយ នៅជាមួយអញអាម៉េច?” “ទេ ខ្ញុំសុំនៅផងៗ អាម៉េចក៏ដោយៗ ខ្ញុំសុំនៅផង”។ បានខ្ញុំថា “នៅហ្នឹងឲ្យនៅមួយជីវិតបានឲ្យនៅ បើនៅពាក់កណ្តាលជីវិតអត់ឲ្យនៅទេ”។ អ៊ីចឹងបានថា “ចាស ខ្ញុំនៅមួយជីវិតៗ” លើកដៃអ៊ីចឹង ក៏ឱបខ្ញុំអ៊ីចឹងទៅ។ បានឈ្មោះ អាអេងៗហ្នឹងណ៎ាគេថា “អឿនឯងៗ នៅធ្វើអីអ្នុះ នៅអីទៀត? ម៉េចក៏មិនគិតធ្វើ? បានខ្ញុំចាប់ផ្តើមធ្វើទៀត ធ្វើវាទៅអ៊ីចេះណ៎ា។ បាទ ធ្វើច្រានទម្លាក់រណ្តៅ។ បាទ មកពីខាងកាត់ដេរ បាត់ដំបងកាលសម័យនោះ។ ដល់ទើបនឹងមក មកលេងក្នុងផ្ទះ វាមកលេងនៅនឹងផ្ទះហ្នឹងក៏វាដោយចាប់គេយកមក ដោយមកដែរមក។*

*ទៅវិញហ្នឹងទៅដុសដៃ ស្តីហ្នឹងទៅ ធំក្លិនឆ្អាប ពេលហ្នឹងខ្ញុំបាយមួយម៉ាត់ពីរម៉ាត់ទៅ ខ្ញុំឈប់ទៅ។ ហិតដៃ ហិតអីទៅវារៀងឆ្អាបបាទ ហើយបើសិនជានៅក្នុងកន្លែងសម្លាប់ហ្នឹង គឺឆ្អាបមុតបណ្តោយហ្នឹងបាទ។ ឆ្អាបជាងសាច់គោសាច់ក្របីយើងទៀត ក៏ប៉ុន្តែវាចេះតែទ្រាំទៅធ្វើម៉េច”។]*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១១:៤៥:៣៩]

លោកប្រធាន លោក លោកស្រីចៅក្រមជាគោរព! កំហុសចំពោះមរណភាពលើរូបនារីរូបនេះត្រូវធ្លាក់លើ នួន ជា និង ខៀវ សំផន រួមជាមួយនឹងមេដឹកនាំមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀត។ នៅក្នុងសវនាការជំនុំជម្រះវាបានបង្ហាញថាជនទាំងអស់នេះ -- ជនទាំងពីរនាក់នេះត្រូវបានចោទប្រកាន់ជាមួយនឹងការកាប់សម្លាប់ដែលកើតចេញពីការជម្លៀសបង្ខំ ហើយនិងនៅទួលពោធិ៍ជ្រៃ។ វាមិនបានបង្ហាញច្បាស់ថាតើនារីរូបនេះបានស្លាប់ដោយសារបញ្ហានេះ ការជម្លៀសនេះឬក៏យ៉ាងណានោះទេ។ ក៏ប៉ុន្តែអ្វីដែលច្បាស់នោះ គឺការសម្លាប់នេះ ការប្រព្រឹត្តអមនុស្សធម៌នេះគឺជាអ្វីដែលយើងត្រូវបន្ទោសពួកគេ។ ការបន្ទោសនេះគឺពីព្រោះតែពួកគេបានបង្កើតឲ្យមានអ្នកកាប់សម្លាប់តាមរយៈគោលនយោបាយ

បញ្ហា ការបំពាក់បំប៉ន និងការបណ្តុះបណ្តាលរបស់ពួកគេ។ ប្រសិនបើគ្មានផែនការឧក្រិដ្ឋទាំងអស់នោះទេ ការកំហុស កំហុសនោះគឺកំហុសចំពោះការស្នើសុំរបស់ស្ត្រី ឲ្យទុកជីវិតរបស់គេនោះ គឺវាអាចឲ្យយើងឃើញដូចនៅសព្វថ្ងៃ។

នៅពេលនេះខ្ញុំសូមធ្វើការបង្ហាញអំពីភស្តុតាង ហេតុអ្វីបានជាយើងដាក់សេចក្តីបន្ទោសនេះទៅលើ នួន ជា, ខៀវ សំផន? ហេតុអ្វីបានជាអ្នកទាំងពីរនេះត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ?

លោកប្រធានថាតើនៅពេលនេះ គឺវាជាចំណុចមួយដែលយើងគួរឈប់សម្រាកត្រឹមនេះ ដោយសារវាត្រូវចូលទៅដល់ចំណុចថ្មី ឬក៏យ៉ាងម៉េចដែរ? ប្រសិនបើអនុញ្ញាតខ្ញុំបន្តទៅមុខទៀត។

**ប្រធានអង្គជំនុំ៖**

បាទ សូមចូលទៅចំណុចថ្មីទៀតទៅ ពីព្រោះលោកមានពេលវេលាបីថ្ងៃ ហើយបីថ្ងៃបានបែងចែកឲ្យនេះម្សិលមិញមានបញ្ហា យើងបានបានជួសជុលរួចហើយ។ អ៊ីចឹងពេលវេលាសម្រាប់ភាគីសហព្រះរាជអាជ្ញា គឺកម្រិតត្រឹមបីថ្ងៃ។ អ៊ីចឹងលោកប្រើពេលវេលាដែលបានបែងចែកនេះឲ្យមានប្រសិទ្ធភាព និងអស់លទ្ធភាពរបស់ខ្លួន។

[១១:៤៧:៥៩]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ដើម្បីឲ្យយើងយល់អំពីរបៀបដែល នួន ជា និង ខៀវ សំផន បានចូលរួមនៅក្នុងឧក្រិដ្ឋកម្មទាំងអស់នេះ វាចាំបាច់ឲ្យយើងយល់ថាតើពួកគេយល់ស្របគ្នាយ៉ាងម៉េចទៅនឹងគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា? តើអំណាចរបស់ពួកគេបានអនុវត្តនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាដោយរបៀបណា? ហើយតើពួកគេមានតួនាទីអ្វីនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា? និងចំណុចចុងក្រោយ តើពួកគេនីមួយៗបានចូលរួមចំណែកយ៉ាងដូចម្តេចនៅក្នុងគោលនយោបាយឧក្រិដ្ឋទាំងនេះ?

នៅពេលនេះខ្ញុំសូមបង្ហាញភស្តុតាងពាក់ព័ន្ធទៅនឹងចំណុចទាំងអស់នេះ ក្រោមប្រធានបទបីធំៗ។ ទី១ ជួរដឹកនាំជាសមូហភាព គោលការណ៍ណែនាំ រចនាសម្ព័ន្ធនិងការទំនាក់ទំនងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា តួនាទីនិងអត្តចរិតរបស់ជនជាប់ចោទ និងចំណុចចុងក្រោយការចូលរួមចំណែករបស់ពួកគេនៅក្នុងគោលនយោបាយឧក្រិដ្ឋ រួមទាំងឧក្រិដ្ឋកម្មដែលចោទប្រកាន់នៅក្នុងការជំនុំជម្រះនេះ។

លោក លោកស្រីចៅក្រមជាទីគោរព! ភស្តុតាងដែលលោក លោកស្រីចៅក្រមបានស្តាប់ឮក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះបានបង្ហាញអំពីតួនាទីរបស់ នួន ជា, ខៀវ សំផន និងក្រុមមេដឹកនាំមួយក្រុមតូចរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានបង្កើតនូវអង្គការស្ថាប័នមួយដែលយើងហៅថា "មជ្ឈិមបក្ស"។

[១១:៤៩:០៩]

ភស្តុតាងបានបង្ហាញថា នួន ជា, ខៀវ សំផន, ប៉ុល ពត, អៀង សារី និង ខៀវ សំផន បានរស់នៅ និងធ្វើការរួមគ្នា។ ពួកគេធ្វើសេចក្តីសម្រេចរួមគ្នា ដោយផ្អែកលើមូលដ្ឋានសមូហភាព។ ហើយពួកគេធ្វើសេចក្តីសម្រេចតាមរយៈរចនាសម្ព័ន្ធបញ្ជា ឋានានុក្រម និងរបបរាយការណ៍ដ៏តឹងរ៉ឹងពីខាងក្រោមទៅខាងលើ ពួកគេអនុវត្តការគ្រប់គ្រងផ្តាច់ការពេញលេញលើកម្ពុជាប្រជាធិបតេយ្យ គ្រប់ភូមិភាគ គ្រប់តំបន់ គ្រប់ក្រសួង គ្រប់កងពលយោធា បានរាយការណ៍ទៅមជ្ឈិម។ នៅគ្រប់ទិដ្ឋភាព ទិដ្ឋភាពនៃជិវិតរស់នៅរបស់ប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានគ្រប់គ្រងដោយមេដឹកបក្ស។ កន្លែងដែលពួកគេរស់នៅ អ្វីដែលពួកគេត្រូវធ្វើ អ្នកដែលពួកគេអាចរៀបការ អ្វីដែលពួកគេអាចហូប អ្វីដែលពួកគេអាចនិយាយ ហើយសូម្បីតែអ្វីដែលពួកគេគិតនឹងជំនឿរបស់ពួកគេ។ កម្ពុជាប្រជាធិបតេយ្យ គឺជារដ្ឋទាសករ ហើយហៅហ្វាយរបស់រដ្ឋនេះ គឺមេដឹកនាំដែលគ្រប់គ្រងប្រទេសតាំងពីមន្ទីរក-១ និង ក-៣ នៅក្នុងទីក្រុងភ្នំពេញ។ នៅក្នុងសេចក្តីថ្លែងបើកការចោទប្រកាន់របស់យើងខ្ញុំ តាំងពីខែវិច្ឆិកា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានពិភាក្សាយ៉ាងលម្អិតអំពីតួនាទីរបស់មជ្ឈិមបក្ស។

លោក លោកស្រីចៅក្រម ប្រហែលជានៅនឹកឃើញថា នៅពេលដែល ខៀវ សំផន សម្រេចចិត្តឆ្លើយតបទៅនឹងសេចក្តីថ្លែងបើកការចោទប្រកាន់របស់យើងខ្ញុំ។ ជនជាប់ចោទបានចោទប្រកាន់ថាយើងជាអ្នកប្រឌិតពាក្យថា "មជ្ឈិមបក្ស"។ ខ្ញុំសូមដកស្រង់ជាក់លាក់តែម្តង ចេញពីខ្សែវីដេអូនៅក្នុងបន្ទប់សវនាការនាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១ នៅពេល ខៀវ សំផន បានធ្វើការលើកឡើងមតិយោបល់ដូចខាងក្រោយ និយាយមកកាន់សហព្រះរាជអាជ្ញាអំពីការប្រើប្រាស់ពាក្យ "មជ្ឈិមបក្ស" នេះ។

[១១:៥១:៤២]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*[ខៀវ សំផន៖ ខ្ញុំបានកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានប្រឌិតពាក្យថា "កន្លែងមជ្ឈិមនៃបក្ស – សង់ត្រឺះ ឌុយ ប៉ាកទី"។ ខ្ញុំស្តាប់ឮ កាលពីថ្ងៃចន្ទ និងថ្ងៃអង្គារ ដោយចិត្តបារម្ភ គិតថា*

*លោកប្រើពាក្យនេះ ដើម្បីធ្វើយ៉ាងណា គេច មិនព្រមបែងចែកឲ្យច្បាស់រវាងគណៈមជ្ឈិមបក្ស និងគណៈអចិន្ត្រៃយ៍ ធ្វើឲ្យវារំខានលោក។ តែពីសម័យកាលនោះ វាមានន័យច្បាស់យ៉ាងនេះ។ ដូច្នេះ លោកចង់ធ្វើឲ្យសាធារណជនជឿថា មនុស្សទាំងអស់គ្នាសុទ្ធតែជាត្រីដែលនៅកន្ត្រកតែមួយ។ តែនេះជារឿងភូតកុហក ជាការបំភ្លៃការពិត"។]*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:៥៣:៤១]

សូមអធ្យាស្រ័យ លោក លោកស្រីចៅក្រម។ ភស្តុតាងនៅក្នុងការជំនុំជម្រះនេះបានបង្ហាញយ៉ាងជាក់លាក់ថា មិនមែនសហព្រះរាជអាជ្ញាទេ គឺ ខៀវ សំផន ខ្លួនឯង ដែលព្យាយាមធ្វើការបោកបញ្ឆោតតុលាការនេះ។ នៅពេលនេះ យើងបានឃើញឯកសារចេញពីសម័យកម្ពុជាប្រជាធិបតេយ្យដែលយោងយ៉ាងជាក់លាក់អំពីមជ្ឈិមបក្ស។ យើងបានរកឃើញបង្ហាញចំណុចយោងជាច្រើនលើមជ្ឈិមបក្ស នៅក្នុងទស្សនាវដ្តីទង់បដិវត្ត និងការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀត ដែលអង្គជំនុំជម្រះនេះបានទទួលយក។ ដើម្បីផ្តល់ជាឧទាហរណ៍មួយចំនួន សុន្ទរកថាមួយថ្លែងឡើងដោយ នួន ជា នៅក្នុងឲ្យខួបលើកទី៩ នៃកងទ័ពបដិវត្តន៍កម្ពុជា ហើយបានបោះពុម្ពនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ចុះខែធ្នូ ឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៧ ពួកគេប្រើប្រាស់ពាក្យ "មជ្ឈិមបក្ស" ១១ដង។ នៅក្នុងទស្សនាវដ្តីទង់បដិវត្ត ចុះខែមេសា ឆ្នាំ១៩៧៨ បានប្រកាសថា "មជ្ឈិមបក្សបានពិភាក្សានិងសម្រេចថា ទន្និផលស្រូវប្រាំបីតោនក្នុងមួយហិកតា អាច--" សូមដកស្រង់៖ "ធ្វើឡើង អាចសម្រេចបានក្នុងរយៈពេល ១០ឆ្នាំទៅ ១៥ឆ្នាំ នៅទូទាំងប្រទេស"។ សូមបញ្ចប់ការដកស្រង់។ ស្ទីវហ្វិន ហេដឌ័រ បានផ្តល់សក្ខីកម្មថា ចំណុចនៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ខែមិថុនា ឆ្នាំ១៩៧៤ ដែលសម្រេចវាយសម្រុករំដោះទីក្រុងភ្នំពេញក៏បានយោងទៅលើសន្និបាតរបស់មជ្ឈិមបក្សផងដែរ។

សេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជាចំណាង ជើងថា "តើអ្វីទៅជាមនោគមន៍វិជ្ជារបស់បក្ស និងវិន័យរបស់បក្ស?" បានសង្ខេបអំពីឋានានុក្រមបក្សកុម្មុយនីស្តកម្ពុជា និងគោលការណ៍អង្គការចាត់តាំងដូចខាងក្រោម, ខ្ញុំសូមដកស្រង់៖ "បុគ្គលនីមួយៗត្រូវគោរព និងធ្វើតាមអង្គការថ្នាក់ក្រោម គោរពថ្នាក់លើ បក្សទាំងមូលគោរពមជ្ឈិមបក្ស។ សាក្សីនានាដែលយើងបានស្តាប់ក្នុងពេលសវនាការនេះក៏បានយោងរៀបរាប់ និងកំណត់អត្តសញ្ញាណក្រុមមួយដែលហៅថា "មជ្ឈិមបក្ស"។ ក្មួយរបស់ ប៉ុល ពត ឈ្មោះ សាឡុត បាន បានរៀបរាប់ថា ខៀវ សំផន គឺជាសមាជិករបស់មជ្ឈិមបក្ស។ យុន គីម

ដែលជាប្រធានឃុំបក្សកុម្មុយនីស្តកម្ពុជាយូរមក ហើយនៅខេត្តក្រចេះដែលបានចូលរួមកិច្ចប្រជុំ ដែលនៅពេលនោះ នួន ជា ផ្តល់ការណែនាំអំពីការអនុវត្តសហករណ៍បានផ្តល់សក្ខីកម្មថា នួន ជា នៅជាមួយមជ្ឈិមបក្ស។ ដូច្នេះគាត់ស្ថិតនៅក្នុងជួរដឹកនាំកំពូលរបស់បក្សកុម្មុយនីស្តកម្ពុជា ទាំង សួង ស៊ីគឿន, ទាំង នង សុផង់ បានរៀបរាប់ថាមន្ទីរ៨៧០ គឺជាមន្ទីរមជ្ឈិមបក្ស។ នៅក្នុងសៀវភៅរបស់លោក "សំឡេងពីស-២១" ដេវីដ ឆេនល័រ បានសរសេរថាជួរដឹកនាំសមូហភាពត្រូវបានគេខាងក្រៅហៅថា អង្គការលើ អង្គការ ឬបងខាងលើ ក៏ប៉ុន្តែសមាជិកបក្សកុម្មុយនីស្តកម្ពុជាគេហៅជួរដឹកនាំសមូហភាពនេះថា៖ "ជាមជ្ឈិមបក្ស ឬក៏ក្បាលម៉ាស៊ីន"។ ឆេនល័រ ក៏បានផ្តល់សក្ខីកម្មនៅក្នុងពេលជំនុំជម្រះថា មជ្ឈិមបក្សរួមមាន នួន ជា និង ខៀវ សំផន ក្នុងនោះ។

[១១:៥៧:៣៧]

នៅក្នុងកិច្ចសម្ភាសន៍មួយ នួន ជា បានផ្តល់កិច្ចសម្ភាសន៍នេះទៅកាន់អ្នកកាសែតជប៉ុននៅក្នុងខែតុលា ឆ្នាំ២០០៦ នួន ជា ត្រូវបានសួរថា អ្នកណាជាអ្នកសម្រេចជម្លៀសប្រជាជនពីក្រុង? គាត់ឆ្លើយថា "មជ្ឈិមបក្ស"។ ដូច្នេះ មជ្ឈិមបក្សគឺមិនមែនជាពាក្យមួយដែលប្រឌិតដោយការិយាល័យសហព្រះរាជអាជ្ញានោះទេ។ វាជាក្រុមបុគ្គល វាជាក្រុមបុរសៗមួយក្រុមជាក់ស្តែងដែលបានគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះមានពីររូបដែលកំពុងអង្គុយទល់មុខយើង។ វាគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេ។ ខៀវ សំផន អង្គុយមិនស្រណុកខ្លួនទេនៅពេលដែលងាកទៅពិភាក្សាអំពីមជ្ឈិមបក្ស ដោយសារនៅក្នុងក្រុមនេះហើយដែលគាត់មានអំណាចពិត និងតួនាទីពិត។ ភស្តុតាងបានបង្ហាញថា ខៀវ សំផន គឺជាមេដឹកនាំមួយក្នុងក្រុមមួយក្រុមតូចដែល ប៉ុល ពត ជឿទុកចិត្ត ដែល នួន ជា ជឿទុកចិត្ត។ នួន ជា អនុញ្ញាតឲ្យ ខៀវ សំផន នៅក្បែរគ្រប់ពេលទាំងអស់។ នៅក្នុងពាក្យសម្តីរបស់ប្រពន្ធរបស់លោក ដែលលោក ខៀវ សំផន បាននាំមកផ្តល់សក្ខីកម្មក្នុងតុលាការក្នុងនាមគាត់នោះ ខៀវ សំផន និងមេដឹកនាំកំពូលដទៃទៀតរបស់បក្ស គឺនៅជិតគ្នាជាដរាប នៅក្នុងសង្គ្រាមចន្លោះឆ្នាំ១៩៧២ ដល់ ១៩៧៥។ ចំណុចនេះនាំឲ្យយើងនឹកឃើញការភូតកុហកគួរឲ្យកត់សម្គាល់មួយទៀតដែលបានថ្លែងឡើងដោយ ខៀវ សំផន នៅក្នុងបន្ទប់សវនាការ។ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ នៅពេលឆ្លើយតបសំណួរដែលសួរលោក ខៀវ សំផន ដោយដើមបណ្តឹងរដ្ឋប្បវេណី ខៀវ សំផន បានបដិសេធថា គាត់មិនមែនជា មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ហើយគាត់បានអះអាងថាគាត់បានចូលរួមជាមួយខ្មែរក្រហមដោយចៃដន្យតែប៉ុណ្ណោះ។ ខៀវ សំផន ដែលបន្តបំពាក់ស្លាកខ្លួនឯងថាជាបុគ្គលដែលមានសេចក្តីថ្លៃថ្នូរនិងស្មោះត្រង់

បានសុំឲ្យតុលាការ និងសាធារណជនជឿជាក់ថា គាត់បានចូលរួមជាមួយខ្មែរក្រហមដោយចៃដន្យ។ ក៏ប៉ុន្តែ ខៀវ សំផន ពុំមែនជាសមាជិកចូលរួមដោយចៃដន្យ ឬក៏ពុំមែនជាសមាជិកធ្វើការងារដោយស្ទាក់ស្ទើរនៅក្នុងអង្គការនេះឡើយ។ អ្វីដែលនាំគាត់រត់ចូលព្រៃម៉ាគី និងទៅនៅក្នុង -- ទៅរស់នៅលើទឹកដីបក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ១៩៦៧ ខៀវ សំផន ទំនងជាពេញចិត្តនឹងកន្លែងទាំងអស់នោះ។ គាត់មិនមែនស្នាក់នៅកន្លែងនោះតែមួយសប្តាហ៍ ឬមួយខែ ឬមួយឆ្នាំនោះទេ។ ខៀវ សំផន បាននៅជាមួយខ្មែរក្រហម ហើយចូលរួមបម្រើការងារដោយស្ម័គ្រចិត្តក្នុងនាមជាមេដឹកនាំកំពូលមួយរូប ហើយបម្រើជាតំណាងសាធារណជនរបស់បក្សជិត៣០ឆ្នាំ ដើម្បីការពារគោលនយោបាយសម្លាប់រង្គាល និងដើម្បីរៀបចំរបៀបវារៈរបស់បក្ស។

[១២:០០:៥៥]

លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំសូមអនុញ្ញាតលើកឡើងមួយកថាខណ្ឌទៀត។ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្ញុំ ខ្ញុំនឹងលើកឡើងអំពីការភូតកុហក ការបោកបញ្ឆោតរបស់ជនជាប់ចោទដែលយើងបានឃើញក្នុងពេលសវនាការ។ ពីព្រោះការភូតកុហកទាំងអស់នេះលាយត្រដាងឲ្យយើងដឹងច្រើនអំពីជនជាប់ចោទ វាបង្ហាញឲ្យយើងយល់ដឹងថា អ្នកទាំងអស់នេះដឹងអំពីកំហុសរបស់ខ្លួនឯង និងបង្ហាញអំពីធាតុពិតរបស់ពួកគេ។ បុគ្គលដែលឈរនៅក្នុងបន្ទប់សវនាការនេះហើយប្រាប់ពាក្យភូតកុហកដោយទ្រគោះយង់ឃ្នងបានបដិសេធតួនាទីរបស់គាត់ ការដឹងឮរបស់គាត់ និងការចូលរួមរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មទាំងអស់នេះ។ ប៉ុន្តែពួកគេនេះ គឺមិនស្ម័គ្រចិត្តឆ្លើយតបរៀបរាប់រឿងរ៉ាវរបស់ពួកគេនៅពេលពួកគេប្រឈមនឹងសំណួរដែលសួរពីអង្គជំនុំជម្រះ សហព្រះរាជអាជ្ញា និងមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

លោក លោកស្រីចៅក្រមជាទីគោរព នៅពេលនេះ ខ្ញុំគិតថាដល់ពេលសមរម្យដែលយើងត្រូវសម្រាកហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការសូមភាគី មន្ត្រី បុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះ និងសាធារណជនជ្រាប។

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោម

សាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងនិងសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០២ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីបន្តការងាររបស់ខ្លួន។ សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម! បន្តិចមុនពេលសម្រាកពិសាអាហារថ្ងៃត្រង់ ខ្ញុំបានបញ្ជាក់ជូនអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះបទឧក្រិដ្ឋទាំងនេះ ហើយល្ងាចនេះខ្ញុំនឹងផ្ដល់អារម្មណ៍ទៅលើបញ្ហា តើគេបែងចែកអំណាចដូចម្ដេច? តើគេអនុវត្តអំណាចដូចម្ដេចនៅក្នុងកម្ពុជាប្រជាធិបតេយ្យ? ដើម្បីឲ្យយល់ពីបញ្ហានេះ អំពីថាតើគេអនុវត្តអំណាចដោយមេដឹកនាំ ដូចម្ដេចនោះយើងនឹងអាចយល់ថា តើជននជាប់ចោទទាំងនេះអាចចូលរួមក្នុងបទឧក្រិដ្ឋដោយរបៀបណា? ដូច្នេះក្នុងការពិភាក្សានេះ នៅក្នុងការបែងចែកអំណាចនេះ ហើយនិងគោលការណ៍ ដែលគេអនុវត្តនូវអំណាចនេះ ហើយនិងអំណាច រចនាសម្ព័ន្ធអំណាច ហើយនិងប្រព័ន្ធរាយការណ៍តាមវិធីដែលគេត្រួតត្រាអំណាចនោះ នឹងត្រូវជាចំណុចពិភាក្សារបស់ខ្ញុំល្ងាចនេះ ហើយនៅថ្ងៃចន្ទយើងខ្ញុំនឹងជម្រាបអំពីតួនាទីជាក់លាក់របស់ជនជាប់ចោទ ហើយនិងវិធីដែលពួកគាត់ចូលរួមនៅក្នុងបទឧក្រិដ្ឋ ក្នុងបរិបទដែលថាតើគេអនុវត្តអំណាចដូចម្ដេចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

លោក លោកស្រីចៅក្រមជាទីគោរព! ប្រហែលជាខ្ញុំសូមអនុញ្ញាតរឿងរ៉ាវដំបូង គឺមុនឆ្នាំ១៩៧៥ គឺរឿងរ៉ាវ ប៉ុល ពត, នួន ជា, ខៀវ សំផន។ ពិនិត្យមើលអង្គហេតុដែលទាក់ទងទៅនឹងភស្តុតាងដែលបង្ហាញពីទំនាក់ទំនងការងារជិតស្និទ្ធគ្នារវាងរបស់ពួកគាត់ទាំងបីនោះ គឺយើងឃើញច្បាស់។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧០ ខៀវ សំផន, ប៉ុល ពត, នួន ជា បានជួបគ្នានៅស្ទឹងជីនិត នៅព្រំដែនកំពង់ធំ ហើយនិង

ខេត្តកំពង់ចាម ជាកន្លែងដែលបក្សកុម្មុយនីស្តកម្ពុជាបានបង្កើតទីបញ្ជាការបក្សថ្មីរបស់ខ្លួន។ លោក ខៀវ សំផន បានទទួលស្គាល់ដោយខ្លួនគាត់ថា ទាំងខ្លួន -- នៅក្នុងបទសម្ភាសន៍សហថៅក្រមស៊ើបអង្កេត ហើយនៅក្នុងសៀវភៅរបស់គាត់ដែលគាត់បានសរសេរមុនពេលដែលគេចាប់ខ្លួនគាត់នោះ។

[១៣:៣៣:៤៩]

អង្គជំនុំជម្រះក៏បានស្តាប់ពីសាក្សីពីររូបផងដែរ ដែលវត្តមាននៅក្នុង -- នៅពេលដែលមេដឹកនាំទាំងបីនាក់នេះបានជួបគ្នានៅក្នុងឆ្នាំ១៩៧០។ សាក្សីទាំងអស់នោះមាន ភី ភួន ហើយនិង អឿន តាន។ លោក ខៀវ សំផន បានចំណាយពេលមួយឆ្នាំ ឬពីរឆ្នាំមុននោះ នៅទីបញ្ជាការរបស់ តាម៉ុក នៅភ្នំឱរ៉ាល់។ ប៉ុល ពត បានមកពីទីបញ្ជាការពីមុនរបស់គាត់នៅនៅរតនគិរី។ នួន ជា មកពីភ្នំពេញ ដែលគាត់បានដឹកនាំចលនាតស៊ូតំបន់ភាគច្រើននៅទូទាំងប្រទេស ប្រហែលជាប្រាំពីរឆ្នាំ ក្រោយពី ប៉ុល ពត បានរត់ចូលព្រៃម៉ាគីនៅក្នុងឆ្នាំ១៩៦៣ នៅពេលដែលភូមិសាស្ត្រធ្វើដំណើររបស់គាត់ត្រូវបានរឹតត្បិត។

តាមពិត គឺថាមិនមែនជាលើកដំបូងដែលបុរសទាំងបីនេះបានជួបទេ ជួបគ្នាទេ នួន ជា និង ប៉ុល ពត ត្រូវបានណែនាំឲ្យស្គាល់គ្នាដោយសមាជិករួមបក្សនៅក្នុងឆ្នាំ១៩៥៥ ពួកគាត់ធ្វើការជាមួយគ្នាក្នុងប្រាំឆ្នាំក្រោយមក ក្នុងការរៀបចំលក្ខន្តិកៈបក្ស ហើយនិងយុទ្ធសាស្ត្របក្ស។ ហើយនៅឆ្នាំ១៩៦០ នួន ជា និង ប៉ុល ពត គឺជាមេដឹកនាំកំពូលរបស់ចលនានោះ។ ខៀវ សំផន ហើយនិង ប៉ុល ពត ធ្លាប់ជាមិត្តរួមសាលាជាមួយគ្នានៅខេត្តនៅក្នុងទស្សវត្សរ៍ឆ្នាំ១៩៤០។ នួន ជា បានធ្វើសក្ខីកម្មក្នុងអង្គជំនុំជម្រះនេះថា គាត់បានជួបដំបូងជាមួយ ខៀវ សំផន នៅកន្លែងមួយនៅជិតភ្នំឱរ៉ាល់។ នៅពេលដែល ខៀវ សំផន បាននៅទីបញ្ជាការ តាម៉ុក នៅភ្នំឱរ៉ាល់ពីឆ្នាំ១៩៦៩ ដល់ ៧០ យើងអាចដឹងថាពួកគាត់អាចបានជួបគ្នាលើកទី១នៅទីនោះ។ បើសិនជាពួកគាត់មិនបានជួបគ្នាពីមុននៅក្នុងគណៈកម្មាធិការក្រុងរបស់បក្សនៅភ្នំពេញទេ។

[១៣:៣៥:៥១]

នៅក្នុងខែកញ្ញា ឆ្នាំ១៩៧០ បុរសទាំងបីនាក់នេះ គឺបានចាប់ផ្តើមរស់នៅធ្វើការជាមួយគ្នានៅកន្លែងតែមួយ។ ទំនាក់ទំនងដែលបានបន្តក្នុងរយៈពេល២៨ឆ្នាំបន្តមក។ ទីបញ្ជាការថ្មីរបស់បក្សដែលនៅទីនោះ គឺនៅស្ទឹងជីនិតនោះ ដែលគេហៅថាមន្ទីរស-៧១ ប៉ុល ពត, នួន ជា និងខៀវ សំផន បានរស់នៅក្នុងផ្ទះ នៅជិតៗគ្នា ហើយធ្វើការជាមួយគ្នា ផ្អែកតាមគោលការណ៍ទៀងទាត់។ ភី ភួន ដែលធ្វើការជាអង្គរក្សការពារឲ្យ ប៉ុល ពត ក្នុងសម័យកាលនោះបានរៀបរាប់អំពីការប្រជុំប្រចាំថ្ងៃជាទម្លាប់របស់គាត់

ហើយគាត់បានបញ្ជាក់ក្នុងសក្ខីកម្មក្នុងសវនាការ។ សូមដកស្រង់៖ “សំណួរ ចាប់ពីឆ្នាំ១៩៧១ ដល់ឆ្នាំ ១៩៧៤ តើលោក ខៀវ សំផន និងប៉ុល ពត បានជួបគ្នាញឹកញាប់ទេ? ឆ្លើយ៖ ពីឆ្នាំ១៩៧១ ដល់១៩៧៤ ពួកគាត់បានជួបគ្នាញឹកញាប់ដែរ។ មានពេលខ្លះពួកគាត់បានបែកគ្នា ដោយហេតុថាមន្ទីរត្រូវបាននៅកន្លែងខុសគ្នា។ ប៉ុន្តែក្រោយមកពួកគាត់បានធ្វើមន្ទីរនៅជិតគ្នាវិញ។ ខៀវ សំផន បានមកធ្វើការនៅមន្ទីរមួយជិតនឹងមន្ទីររបស់ ប៉ុល ពត ហើយខ្ញុំក៏បានចង្អុលបង្ហាញពីថ្ងៃមុនដែរថា ពេលខ្លះពួកគាត់ធ្វើការជាមួយគ្នា។ ក្នុងចំណោមអ្នកទាំងបីនាក់ គឺអ៊ំលេខ១ អ៊ំលេខ២ និង ខៀវ សំផន។ ប៉ុន្តែក្នុងឱកាសមួយចំនួន ប៉ុល ពត ជាអ្នកសរសេរ គាត់រៀបចំកំណត់ហេតុនៅក្នុងផ្ទះរបស់គាត់។ ហើយនៅក្នុងឱកាសផ្សេងទៀត ពួកគាត់បានរៀបចំឯកសារដោយឡែកពីគ្នានៅក្នុងកន្លែងរបស់គាត់រៀងៗខ្លួន។ សំណួរ៖ សូមអរគុណ។ ដូច្នេះនៅពេលដែលពួកគាត់ជួបគ្នានោះ តាមដែលលោកសង្កេត ពួកគាត់តែងជួបគ្នាពេលល្ងាយ ឬក៏ពេលល្ងាច? ពួកគាត់បានជួបពេលព្រឹក ហូបអាហារពេលព្រឹក ហើយហូបបបរជាមួយគ្នា ហើយចាប់ផ្តើមការប្រជុំពីម៉ោងប្រាំបីកន្លះ ដល់ម៉ោងដប់មួយ។ ហើយបន្ទាប់មកពេលបាយថ្ងៃត្រង់ពួកគាត់ក៏ជួបគ្នា។ បន្ទាប់មកពួកគេបានសម្រាកបន្តិច ហើយបន្ទាប់មកធ្វើការងារជាបន្តនៅពេលល្ងាចតទៅទៀត។ ហើយបន្ទាប់មកទៀត បន្ទាប់ពីការបញ្ចប់ការងារប្រចាំថ្ងៃ ពួកគាត់ត្រឡប់ទៅទីកន្លែងរៀងៗខ្លួនវិញ ហើយពួកគាត់ហូបអាហារល្ងាចដាច់ដោយឡែកពីគ្នា។ សំណួរ៖ ដូច្នេះតើត្រូវទេ បើយើងនិយាយថាពួកគាត់ជួបគ្នាញឹកញាប់? ចម្លើយ៖ ពួកគាត់ជួប ហើយ-- បាទ នេះជាសំណួរ។ ចម្លើយ៖ បាទត្រឹមត្រូវហើយ”។

[១៣:៣៨:៤៦]

លោក លោកស្រីចៅក្រម បន្ថែមទៅលើការងារប្រចាំថ្ងៃរបស់គាត់ នួន ជា, ខៀវ សំផន ហើយ និង ប៉ុល ពត បានចូលរួមនៅក្នុងកិច្ចប្រជុំជាមួយមេដឹកនាំបក្សផ្សេងទៀតដែលបានធ្វើឡើងនៅទីបញ្ជាការស-៧១។ យ៉ាងហោចណាស់មួយឆ្នាំម្តង ដែលគេធ្វើសេចក្តីសម្រេចសំខាន់ៗលើនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងយុត្តិសាស្ត្ររបស់គេ។ បញ្ហាទាក់ទងទៅនឹងការបិទទីផ្សារសហករណ៍នៅក្នុងតំបន់រំដោះមួយចំនួន។ ហើយនិងយុត្តិសាស្ត្ររបស់បក្សក្នុងការកាន់កាប់ ឬក៏ត្រួតត្រាមនុស្សដោយបណ្តេញប្រជាជនចេញឲ្យអស់ពីទីក្រុងដែលកងកម្លាំងរបស់ខ្លួនបានកាន់កាប់។

លោក លោកស្រីចៅក្រម ខ្ញុំនឹងត្រឡប់ទៅនឹងពិភាក្សាការប្រជុំនេះនៅពេលក្រោយ។ ប៉ុន្តែសូមអនុញ្ញាតពិភាក្សាអំពីការប្រជុំធំមួយដែលបានរៀបចំឡើយក្រោយពី ប៉ុល ពត, នួន ជា ហើយនិង ខៀវ

សំផន បានមកដល់ស្ទឹងជីនិត។ គឺសន្និបាទបក្សលើកទី៣ ដែលបានធ្វើឡើងនៅខែកក្កដា ឬសីហា ឆ្នាំ ១៩៧១ គឺនៅក្នុងសន្និបាទឆ្នាំ១៩៧១នេះហើយដែល ខៀវ សំផន បានទទួលស្គាល់ថា គេបានចាត់តាំងគាត់ឱ្យចូលជាគណៈមជ្ឈិមបក្សជាសមាជិកត្រៀម។ ភី ភួន គាត់បានវត្តមាន ដែលគាត់បានធ្វើជាការអ្នកយាមនៅក្នុងការយាមប្រជុំនោះ។ ហើយគាត់បានចង្អុលបង្ហាញនៅក្នុងរូបថតបីដែលថតនៅពេលសមាជនោះ ហើយខ្ញុំនឹងបង្ហាញរូបថត។ នៅក្នុងរូបថតនេះយើងអាចមើលឃើញគាត់នៅជួរក្រោយនៅកណ្តាល គឺនៅក្បែរខាងឆ្វេងបន្តិចនៃសញ្ញាញញួរ និងកណ្តៀវ។ ប៉ុល ពត នៅត្រង់កណ្តាលជួរខាងមុខអង្គុយនៅលើដី។ ហើយ នួន ជា គឺបានឈរនៅចុងខាងស្តាំនៅក្នុងរូបថត។

[១៣:៤០:៤០]

ស្តាយបន្ទាប់ទៀតនោះ គឺជារូបថតមួយទៀតដែលថតពីកន្លែងប្រជុំដដែលនោះ។ យើងដែលឃើញការប្រជុំកំពុងដំណើរការ ដែល ប៉ុល ពត ជាអ្នកធ្វើជាប្រធាននៅកណ្តាលដែលគាត់បានឈរ ហើយ នួន ជា អង្គុយក្បែរ ប៉ុល ពត។ តួអង្គសំខាន់នៃបដិវត្តន៍របស់ពួកគាត់នោះ គឺមានរូបថតព្យួរនៅជញ្ជាំងរបស់បក្សកុម្មុយនីស្តកម្ពុជាមាន ឡេនីន, ម៉ាក្ស ហើយនិង ស្តាលីន។

អង្គហេតុដែលថា ខៀវ សំផន ត្រូវបានដំឡើងឋានៈឆាប់រហ័សទៅក្នុងធ្វើជាសមាជិកបក្សកុម្មុយនីស្តក្នុងមជ្ឈិមក្នុងឆ្នាំ១៩៧១នោះ គឺដែលគេហៅថាជនខ្មោចពីរនាក់ទៀត ដែលបានរត់ចេញពីភ្នំពេញក្នុងឆ្នាំ១៩៧៨ ហ៊ូ យន់ និង ហ៊ូ នឹម មិនត្រូវបានចាត់ចូលនៅក្នុងមជ្ឈិមបក្សទេ ឬក៏មិនចូលទៅក្នុងវង់ផ្ទៃក្នុងបក្សដឹកនាំបក្សទេ។ ប៉ុន្តែ ខៀវ សំផន បានឡើងខ្ពស់ទៅក្នុងថ្នាក់កំពូលជួរបក្ស។ ហ៊ូ យន់, ហ៊ូ នឹម ក្លាយទៅជនរងគ្រោះនៃការបោសសម្អាតផ្ទៃក្នុងបក្សទៅវិញ។

លោក លោកស្រីចៅក្រម! នេះជាសេចក្តីពន្យល់មួយដែលបង្ហាញពីជោគវាសនាខុសគ្នាដ៏ខ្លាំងរវាងបញ្ញវន្តទាំងបីដែលបានចូលចលនាម៉ាគីនៅក្នុងឆ្នាំ១៩៦៨។ ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ គេបានគេស្គាល់ថាជាជនមានកិត្តិយសនៅកម្ពុជាជាសាធារណៈ ដែលបានចូលរួមក្នុងចលនានោះ។ អ្នកទាំងបីបានធ្វើការក្នុងរបប សីហនុ ហើយបានស្គាល់ សីហនុ យ៉ាងច្បាស់ ហើយបានធ្វើជាស្ពានចម្លងរវាងបក្សកុម្មុយនីស្តកម្ពុជានិងព្រះអង្គ។ ប៉ុន្តែមានតែម្នាក់គត់ទេដែលបានយល់ស្របទាំងស្រុងជាមួយផែនការ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ខៀវ សំផន ត្រូវបានទទួលស្គាល់ឱ្យចូលក្នុងវង់បក្សដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដោយហេតុថាគាត់បានយល់ព្រមជាមួយនយោបាយនោះ។ ពីព្រោះគាត់មានឆន្ទៈ និងធ្វើការ ហើយនិងចូលរួមនឹងផែនការ និងគោលនយោបាយរបស់ពួកគេ។

[១៣:៤២:៥៩]

ម្យ៉ាងទៀត ហ៊ូ យន់ មិនយល់ព្រមជាមួយនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជាការជម្លៀសទីក្រុងភ្នំពេញ និងទីក្រុងផ្សេងទៀតទេ។ ដូចដែលលោក លោកស្រីបានដឹងហើយ គឺថាសាក្សីពីររូបដែលបានធ្វើសក្ខីកម្មដូច នូ ម៉ៅ ហើយនិង ភី ភួន ជាដើម។ ហ៊ូ នឹម គេបានដឹងថាគាត់ជាអ្នកប្រឆាំងនឹងនយោបាយរបស់បក្ស ហើយក៏បានផ្ទុះបញ្ចាំងនៅក្នុងចំណាររបស់ សុន សេន ហើយឌុច ដែលគេរកឃើញនៅក្នុងចម្លើយសារភាពរបស់ កុយ ធួន ដែលចង្អុលបង្ហាញថា កុយ ធួន បានដើរតាមជំហររបស់ ហ៊ូ នឹម ស្តីពីបញ្ហាទីផ្សារ និងការជម្លៀសប្រជាជន។ ហើយគេដឹងគ្រប់គ្នាថា ហ៊ូ នឹម ជាអ្នកជំទាស់នយោបាយបក្សក្នុងការបោសសម្អាតខ្មាំង ហើយជំហរចំពោះខ្មាំងនេះឯង។ ជំហររបស់គាត់ចំពោះខ្មាំងគឺមានលក្ខណៈសន្តិវិធី និងសម្របសម្រួល។ បញ្ញវន្តពីររូបដែលជំទាស់ទៅនឹងនយោ-បាយរបស់បក្សក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង អ្នកទាំងពីរនោះត្រូវបានគេចាប់ខ្លួន ហើយនិងសម្លាប់ចោលជាចុងក្រោយ។

[១៣:៤៤:១៣]

ម្យ៉ាងទៀតលោក ខៀវ សំផន គឺជាបុគ្គលតែមួយរូប ដែលគាំទ្រគោលនយោបាយនេះ បានចូលទៅក្នុងថ្នាក់ដឹកនាំបក្សកំពូល។ គឺតាមភាពឈ្មោះត្រង់ទៅនឹងថ្នាក់ដឹកនាំបក្សនេះហើយ ហើយនិងការយល់ស្របរបស់គាត់ នោះហើយដែលធ្វើឲ្យគាត់បានដំឡើងឋានៈ ហើយគាត់បានក្លាយទៅជាសមាជិកនៃគណៈមជ្ឈិមបក្ស ហើយជាអ្នកចូលរួមជាប្រចាំនៅក្នុងកិច្ចប្រជុំ ហើយនិងជាសមមិត្តរួមអាវុធជាមួយប៉ុល ពត ហើយនិង នួន ជា ក្នុងរយៈពេល២៨ឆ្នាំ។ តួនាទីរបស់ ខៀវ សំផន ហើយសារៈសំខាន់ក្នុងចលនាបដិវត្តន៍បានកើនឡើងយ៉ាងឆាប់រហ័ស គាត់បានក្លាយគឺជាអ្នកនាំពាក្យមុខមាត់របស់ខ្មែរក្រហម ជាអ្នកទទួលខុសត្រូវក្នុងការដឹកនាំគណៈប្រតិភូទៅបរទេស ចេញសេចក្តីថ្លែងការណ៍ជាសាធារណៈក្នុងនាមចលនារណសិរ្សរួបរួមជាតិកម្ពុជា ហើយនិងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។

នៅក្នុងភាពយន្តឯកសារដែលខ្ញុំនឹងបញ្ចាំង ឃើញថា ខៀវ សំផន ប៉ុល ពត និងបក្សកុម្មុយនីស្តកម្ពុជាដែលជាមេដឹកនាំហ្នឹង គឺនៅខែមីនា និងដើមខែមេសា ឆ្នាំ១៩៧០ ពួកគាត់បានធ្វើដំណើរនៅតំបន់រំដោះ ហើយបានទទួលដោយ ខៀវ សំផន នៅទីនោះ។

*(ការបង្ហាញឯកសារជារូបភាព)*

លោក លោកស្រីចៅក្រម នៅក្នុងឯកសារបន្តទៀតនេះ យើងនឹងឃើញ ខៀវ សំផន បានថ្លែង

សុន្ទរកថានៅប្រទេសចិនអំពីមហាជោគជ័យរបស់កម្ពុជានៅក្នុងឆ្នាំ១៩៧៥។ វីដេអូនេះ មានសំឡេងបាទ។

[១៣:៤៦:២២]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ឥឡូវនេះ គាត់ទទួលបន្ទុកជាមេដឹកនាំកំពូលរបស់ខ្មែរក្រហម ប៉ុល ពត ធ្វើការពីក្រោយខ្នង។ រឿងរ៉ាវនេះនឹងធ្វើការបន្តទៅ២៥ឆ្នាំ នៅពេលដែលខ្មែរក្រហមបន្ត។ -- ដែលចេញមកពីសមរភូមិក្តៅបំផុតលើសកលលោកបច្ចុប្បន្ន។ ជ័យជម្នះរបស់ប្រជាជាតិ និងប្រជាជនកម្ពុជាយើងខ្ញុំ មានលក្ខណៈជាយុត្តិសាស្ត្រ"។*

[១៣:៤៧:១១]

លោកប្រធាន លោក លោកស្រីចៅក្រម ភស្តុតាងដែលបង្ហាញនៅក្នុងការជំនុំជម្រះនេះ បង្ហាញពីទំនាក់ទំនងជិតស្និទ្ធរវាង ប៉ុល ពត, នួន ជា និង ខៀវ សំផន។ ហើយទំនាក់ទំនងនេះ បន្តនៅក្នុងឆ្នាំ ១៩៧៤ និង៧៥។ នៅក្នុងពេលដែលបក្សកុម្មុយនីស្តកម្ពុជារៀបចំផែនការវាយប្រហារចុងក្រោយ នៅភ្នំពេញ។ ក្នុងពេលនេះ ប៉ុល ពត បានបង្កើតនូវមូលដ្ឋានជួរមុខនៅខាងលិចឧដុង្គ ដែលនៅជិតសមរភូមិសំខាន់ៗនៅក្នុងមន្ទីរ ប-៥ នៅក្នុងភូមិ ឃុំពាម ជាដើម។ សាក្សី សាឡុត បាន ហើយនិង ភី ភួន បានធ្វើសក្ខីកម្មថា៖ "ខៀវ សំផន ហើយនិង នួន ជា បានចំណាយពេលនៅមន្ទីរប-៥ ហើយបានចូលរួមនៅក្នុងការប្រជុំ ដែលប្រជុំនៅទីនោះជាមួយ ប៉ុល ពត ហើយនិងមេដឹកនាំភូមិភាគ ហើយនិងមេបញ្ជាការយោធា"។

[១៣:៤៨:១០]

ភី ភួន បានបញ្ជាក់ថា សូមដកស្រង់៖ "ប-៥ គឺជាមន្ទីរបញ្ជាដើម្បីវាយប្រហារភ្នំពេញ ដើម្បីរំដោះភ្នំពេញ"។ បញ្ចប់។ នៅពេលដែលសួរពីបញ្ហាប្រជុំនៅ ប-៥, ភី ភួន និយាយថា សូមដកស្រង់៖ "ការប្រជុំទៀងទាត់នៅប-៥ គឺដឹកនាំដោយ អ៊ំ ប៉ុល ពត ដែលនៅកន្លែងជាញឹកញាប់។ ជួនកាល អ៊ំ នួន ជា, អ៊ំ ខៀវ សំផន ក៏បាននៅទីនោះដែរ។ ជួនកាលបីនាក់ទាំងអស់នោះ ជាអ្នកកោះប្រជុំជាទៀងទាត់។ ហើយពួកគាត់បានជួបគ្នាជាមួយនឹងអ្នកមកពីភូមិភាគ មាន៖ សុន សេន, មាន តាម៉ុក, វន វេត, ចេង អន, កុយ ធួន, កែ ពក, សោ ភឹម ហើយនិងតាភ្លុង។ ពួកគាត់ជួបគ្នារៀងរាល់ថ្ងៃ ឬកន្លះខែម្តង គឺអាស្រ័យទៅលើស្ថានការណ៍នៃសមរភូមិ"។ ទីតាំងដែលបង្ហាញនៅក្នុងឯកសារ ភាពយន្តឯកសារដែល

ខ្ញុំនឹងបញ្ចាំងជូន ដែលថា ប៉ុល ពត នួន ជា និង ខៀវ សំផន ធ្វើការជាមួយគ្នានោះ គឺការពិនិត្យមើលផែនទី ហើយពិនិត្យប្រព័ន្ធវិទ្យុទាក់ទងត្រូវបាន ភី ភួន បានបញ្ជាក់ថា៖ "នេះហើយគឺកន្លែង ប-៥"។

*(ការបង្ហាញឯកសារជារូបភាព)*

[១៣:៥០:០២]

ទាំង ខៀវ សំផន ហើយនិង នួន ជា បានទទួលស្គាល់ថា ពួកគាត់បាននៅមូលដ្ឋានជួរមុខរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងពេលដែលសំខាន់ដែលនាំឲ្យមានការចូលកាន់កាប់ទីក្រុងភ្នំពេញ។ នៅក្នុងសៀវភៅរបស់គាត់គឺ "ប្រវត្តិសាស្ត្រថ្មីៗរបស់កម្ពុជា និងមូលហេតុនៃការសម្រេចចិត្តរបស់ខ្ញុំ", ខៀវ សំផន បានសរសេរថា សូមដកស្រង់៖ "នៅចុងខែមីនា ឆ្នាំ ១៩៧៥ គេបានអញ្ជើញខ្ញុំទៅទីបញ្ជាការរបស់បក្សកុម្មុយនីស្តកម្ពុជានៅភូមិដូង នៅខាងលិចឧដុង្គ ដើម្បីតាមដានការវាយប្រហារចុងក្រោយទីក្រុងនៅទីនោះ។ ជារៀងរាល់ថ្ងៃ មាន-- ជាមួយយោធាខ្ញុំបានតាមដានព័ត៌មានពីសមរភូមិនៅថ្ងៃទី១៧ ខែមេសា នៅម៉ោងប្រាំបួន ខ្ញុំសប្បាយចិត្ត ខ្ញុំបានឮពីមេបញ្ជាការអង្គភាពផ្សេងៗនិយាយថា ពួកគេបានចូលដល់ចំណុចជាច្រើននៅក្នុងទីក្រុងហើយ" បញ្ចប់សេចក្ដីដកស្រង់។ ខៀវ សំផន ក៏បានទទួលស្គាល់ដែរថាចំពោះមុខបទសម្ភាសន៍ថៅក្រមស៊ើបអង្កេតថា គាត់បានរស់នៅក្នុងកន្លែងមួយនៅមន្ទីរទីបញ្ជាការរបស់ ប៉ុល ពត ខាងលិចឧដុង្គនៅក្នុងពេលនោះ។ ប្រពន្ធរបស់គាត់ សូ សុជាតិ បានបញ្ជាក់ថា គាត់បានជួបប្ដីរបស់គាត់នៅស្តុកតោល ជាមូលដ្ឋានជួរមុខ បន្ទាប់ពីការដួលរំលំនៃទីក្រុងភ្នំពេញ។

លោក នួន ជា បានទទួល ស្គាល់នៅក្នុងសក្ខីកម្មសវនាការរបស់គាត់ថា គាត់បានទៅ ប-៥ ដើម្បីជួបជាមួយ ប៉ុល ពត។ សៀវភៅដែលបោះពុម្ពដោយ ថេត សម្បត្តិ ផ្អែកតាមបទសម្ភាសន៍ ហើយនិងចំណារសរសេរដៃដែល នួន ជា បានឲ្យទៅគាត់នោះបានបញ្ជាក់ថា មុនពេលចូលភ្នំពេញ នួន ជា បានរស់នៅប្រហែលជាពីរបីសប្ដាហ៍ នៅក្នុងឃុំពាម។ ហើយនៅក្នុងកថាខណ្ឌ៤១៧ នៃ -- នៅក្នុងសេចក្ដីសន្និដ្ឋានរបស់គាត់លោក នួន ជា បាននិយាយទទួលស្គាល់ដូចខាងក្រោមនេះ៖

[១៣:៥២:០០]

"នៅខែមេសា ឆ្នាំ១៩៧៥ នួន ជា បាននៅប-៥ នៅក្នុងខេត្តកំពង់ឆ្នាំងកម្មាភិបាលដែលវត្តមាននៅប-៥ នៅពេលនោះមាន ប៉ុល ពត, កែ ពក, សោ ភឹម, វន វ៉េត, តាម៉ុក និងសុន សេន។ ប្រធានបទដែលពិភាក្សានៅប-៥ នោះ ជាគោលការណ៍នោះគឺការរំដោះ ហើយនិងការជម្លៀសប្រជាជនពីភ្នំពេញបន្ទាប់ពីរំដោះ" សូមបញ្ចប់សេចក្ដីដកស្រង់។

វត្ថុមានរបស់ នួន ជា និង ខៀវ សំផន នៅប-៥ ហើយនិងនៅមូលដ្ឋានមុខផ្សេងៗទៀតនោះ ដែលមុនរំដោះរហូតដល់រំដោះ ហើយនិងក្រោយថ្ងៃរំដោះថ្ងៃ១៧ មេសា ១៩៧៥ នោះគឺជាចំណុចដ៏សំខាន់បំផុតក្នុងរឿងក្ដីនេះ។ ខ្ញុំនឹងពិភាក្សាជាលម្អិតនៅពេលក្រោយអំពីការប្រជុំសំខាន់ៗដែលធ្វើឡើងនៅប-៥ នៅដើមខែមេសា ឆ្នាំ១៩៧៥ ដែលនៅទីនោះទាំង នួន ជា ហើយនិង ខៀវ សំផន បានផ្ដល់ ការឯកភាពចុងក្រោយលើផែនការជម្លៀសទីក្រុងភ្នំពេញ។ ប៉ុន្តែវាសំខាន់ដូចគ្នាដែរ ដែលយើងត្រូវយល់អំពីមុខងារទូទៅរបស់មូលដ្ឋានប-៥ នេះដែលទាក់ទងទៅនឹងតួនាទីដ៏សំខាន់របស់មជ្ឈិមបក្ស ហើយនិងការគ្រប់គ្រងទៅលើយោធារបស់បក្សកុម្មុយនីស្តកម្ពុជា ដែលក្រោយមកគេហៅថា ដែលគេស្គាល់ថាជាកងទ័ពជាតិរំដោះប្រជាជនកម្ពុជានោះ។ នៅក្នុងសំណេរដៃនោះគាត់បាននិយាយថា៖“មូលដ្ឋាននៅពាមនោះ គឺដើម្បីបញ្ជា និងត្រួតត្រាការរំដោះទីក្រុងភ្នំពេញ។ នៅក្នុងចម្លើយ នៅពេលចាប់ផ្ដើមសវនាការថ្ងៃទី២២ វិច្ឆិកា ឆ្នាំ២០១១ នួន ជា បានបញ្ជាក់ថា មូលដ្ឋានជួរមុខនៅឃុំពាមរបស់បក្សនោះ គឺត្រូវបានបង្កើតគឺដើម្បីធានាការជោគជ័យមានប្រសិទ្ធភាព និងចុងក្រោយជាមួយការវាយប្រហារដើម្បីរំដោះទីក្រុងភ្នំពេញ” សូមបញ្ចប់សេចក្ដីដកស្រង់។ ហើយគាត់បានកត់សម្គាល់ថា កម្មាភិបាលដែលវាយប្រហារដណ្ដើមទីក្រុងភ្នំពេញនោះគឺ “បានធ្វើរបាយការណ៍រៀងរាល់ថ្ងៃ”។ សាឡុត បាន បានបញ្ជាក់ក្នុងសក្ខីកម្មថា មូលហេតុដែលបក្សបង្កើតមូលដ្ឋានចល័តនៅក្បែរខដុង្គនោះ គឺសូមដកស្រង់៖ “គឺដើម្បីសម្រួលការបញ្ជាវាយប្រហារលើភ្នំពេញ” បញ្ចប់សេចក្ដីដកស្រង់។

[១៣:៥៤:៥៧]

ភី ភួន ក៏បានបញ្ជាក់ថា “ប-៥ គឺជាមន្ទីរបញ្ជាការ ដើម្បីវាយប្រហារភ្នំពេញដើម្បីរំដោះភ្នំពេញ ហើយនោះជាមូលហេតុនៃការបង្កើតប-៥ ដែលថាជាការបង្កើតដើម្បីចេញបញ្ជា ដើម្បីធ្វើការវាយប្រហារទៅលើទីក្រុងភ្នំពេញ។ ជាទីបញ្ជាការយោធាមួយ ប៉ុន្តែនៅពេលនោះ ការវាយប្រហារក៏ត្រូវអនុវត្តអំពីគ្រប់មុខសញ្ញាចូលទៅក្នុងភ្នំពេញផងដែរ”។ សូមបញ្ចប់សេចក្ដីដកស្រង់។

លោក លោកស្រីចៅក្រម គ្រប់ពេលទាំងអស់នៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់ការដេញដោលនេះគឺមេធាវីការពារក្ដីអះអាងថា៖ “ការជម្លៀសទីក្រុងភ្នំពេញត្រូវបានធ្វើឡើងដោយកងទ័ពភូមិភាគស្វ័យតដែលថាមជ្ឈិមបក្សនោះមិនបានមានទំនាក់ទំនងលើយោធា មិនមានការត្រួតត្រាលើកងទ័ពដែលវាយប្រហារជម្លៀសទីក្រុងភ្នំពេញ ប៉ុន្តែខ្ញុំសូមជម្រាបឲ្យអង្គជំនុំជម្រះចងចាំ ហើយនិងរូបភាពប-៥ នៅខាងមុខនោះ។

ទីបញ្ជាការរបស់បក្សកុម្មុយនីស្តកម្ពុជានោះ គឺដើម្បីយោធាបក្សកុម្មុយនីស្តកម្ពុជា ដើម្បីឲ្យមេដឹកនាំសំខាន់ៗរបស់បក្សដែលប្រមូលផ្តុំ ដើម្បីបញ្ជាកងទ័ព ដើម្បីអនុវត្តប្រតិបត្តិការបេសកកម្ម។ ប៉ុល ពត នៅទីនោះ នួន ជា នៅទីនោះ ហើយ ខៀវ សំផន ក៏នៅទីនោះដែរ សុន សេន នៅទីនោះដែរ។ មេដឹកនាំរបស់កងទ័ពភូមិភាគដែលចាត់តាំងឲ្យជួយជម្លៀសភ្នំពេញនោះក៏នៅទីនោះដែរ គឺ កុយ ធួន មកពីភូមិភាគឧត្តរ, សោ ភឹម មកពីភូមិភាគបូព៌ា, តាម៉ុក មកពីភូមិភាគនិរតី ហើយនិង វន វ៉េត មកពីភូមិភាគពិសេស។ មេដឹកនាំកំពូលបក្សបានប្រមូលប្រជុំគ្នានៅបញ្ជាការ បញ្ជាយោធាប្រហែលជាមិនដល់ ៣០គីឡូម៉ែត្រពីទីក្រុងភ្នំពេញផង។ នៅទីនោះ ភី ភួន បាននិយាយថា៖ "ហើយ ខៀវ សំផន ក៏បានទទួលស្គាល់ដែរ។ នៅក្នុងខ្សែភាពយន្តចុងក្រោយគឺថា គេមានឧបករណ៍វិទ្យុទាក់ទងដែលមានកម្លាំងដែលអាចត្រួតត្រាស្ថានភាពទាំងអស់នៅក្នុងសមរភូមិ ជុំវិញទីក្រុងភ្នំពេញ"។ យើងបានស្តាប់សក្ខីកម្មរបស់មេបញ្ជាការយោធាបក្សកុម្មុយនីស្តកម្ពុជា ហើយនិងទាហាន ដូចជា អ៊ុង វ៉ែន, មាស វឿន, អៀង ផាន, ឆោម សែ ហើយនិង ស៊ុំ ជា នោះ។ ដែលអ្នកទាំងអស់នោះបានចូលរួមនៅក្នុងការចូលដណ្តើម ហើយនិងការចូលជម្លៀសទីក្រុងភ្នំពេញ បញ្ជាក់ថាកងពលរបស់ពួកគាត់បានទំនាក់ទំនងហើយនិងទទួលបញ្ជាគ្រប់យ៉ាងទាំងអស់តាមវិទ្យុទាក់ទង។ អ៊ុង វ៉ែន បានបញ្ជាក់ថា៖ "សារដែលចេញឬចូលមកមេបញ្ជាការកងវរសេនាធំ គឺបញ្ជូនតាមអ្នកកាន់វិទ្យុនោះដែរ"។ ឆោម សែ ជាមេបញ្ជាការថ្នាក់កណ្តាលនៅក្នុងភូមិភាគពិសេស បានបញ្ជាក់ថា៖ "ខ្ញុំតែងតែទទួលបញ្ជាមកពីបញ្ជាការកងពលតាមរយៈវិទ្យុទាក់ទង"។ មាស វឿន បញ្ជាក់ថា៖ "គាត់បន្តព័ត៌មាននេះតាមវិទ្យុទាក់ទងទៅថ្នាក់កងពល"។ ទាហានភូមិភាគឧត្តរ ស៊ុំ ជា បានបញ្ជាក់ថា "ម្នាក់ៗដែលមកពីក្រុងភ្នំពេញគឺមកក្នុងពេលតែមួយ ពួកគេទាក់ទងគ្នាតាមរយៈវិទ្យុទាក់ទង"។ មេបញ្ជាការកងវរសេនាធំភូមិភាគនិរតី អៀង ផាន បានបញ្ជាក់ថា៖ "នៅកងវរំដោះបានទំនាក់ទំនងតាមទូរស័ព្ទទាក់ទង"។

[១៣:៥៨:៥៦]

ដូចសហសេវិករបស់ខ្ញុំបានបញ្ជាក់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៣ នោះ អាល់ រ៉ុក្កូហ្វ បានផ្តល់ព័ត៌មានមួយចំនួនដែលបង្ហាញអំពីការជម្លៀសប្រជាជនចេញពីភ្នំពេញនៅក្នុងថ្ងៃទី១៧ មេសា ១៩៧៥ ថា៖ "ឃើញដោយទាក់ទងដូចម្តេច? គឺថាគាត់ឆ្លើយថា ឃើញគេទាក់ទងគ្នាតាមវិទ្យុ។ មើលឃើញថាមានបណ្តាញវិទ្យុទាក់ទងល្អណាស់។ ពួកគេមានវិទ្យុទាក់ទងរបស់សហរដ្ឋអាមេរិក ភី.អ័រ.ស៊ី ២៥ ហើយនិងមានវិទ្យុទាក់ទងបែបរបស់ចិន ដែលថាអាចមានទំហំប៉ុនគ្នា។ មានវិទ្យុទាក់ទងម៉ូតូរ៉ូឡា

ដូចដែលយើងមាន គឺថាមានមួយចំនួនគួរសមដែរ។ ប៉ុន្តែមិនឃើញមានវិទ្យុទាក់ទងច្រើនទេ ប៉ុន្តែមានអ្នកខ្លះគេទទួលខុសត្រូវ យើងអាចឃើញគេទទួលបន្ទុកដែលមានវិទ្យុ អ្នកកាន់វិទ្យុទាក់ទងនៅទីនោះអ្នកដែលមេនោះ"។ ដូចដែលអាចនឹងឃើញរូបថត ដែលយើងពិនិត្យឃើញដោយអ្នកសារព័ត៌មាន គឺខ្មែរក្រហមបានបង្ហាញខ្លួននៅទីក្រុងភ្នំពេញ ដែលមានឧបករណ៍វិទ្យុទាក់ទង គឺយើងអាចឃើញគាត់ប្រើវិទ្យុនៅនឹងដៃដើម្បីទាក់ទង ហើយមានប្រអប់មួយដែលដាក់នៅនឹងដីសម្រាប់ជាជំនួយនោះ។

[១៤:០០:២៥]

លោក លោកស្រីចៅក្រម មានភស្តុតាងហួសពីវិមតិសង្ស័យថា បក្សកុម្មុយនីស្តកម្ពុជាមានកងទ័ពវាយប្រហារទីក្រុងភ្នំពេញ ចាប់ផ្ដើមនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ហើយដឹកនាំដោយ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលមានទីតាំងនៅមូលដ្ឋានជួរមុខនៅក្បែរឧដុង្គ។ ប៉ុល ពត, នួន ជា, ខៀវ សំផន ហើយនិងមេដឹកនាំបក្សផ្សេងទៀត ក៏បានប្រជុំគ្នានៅមូលដ្ឋានជួរមុខនោះដែរ ហើយបានដឹង ហើយបានត្រួតត្រាសកម្មភាពសំខាន់ៗទាំងអស់នៃកងទ័ពនោះ។ យើងមិនគម្បីជឿជាលើកទី២ អំពីការកុហករបស់ជនជាប់ចោទ ដែលយើងនឹងឃើញនៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់របស់គាត់ទេ ដែលថាមជ្ឈិមបក្សមិនមានការត្រួតត្រាមានប្រសិទ្ធភាពទៅលើយោធាបក្សកុម្មុយនីស្តកម្ពុជានៅខែមេសា ១៩៧៥នោះទេ។ ទំនាក់ទំនងការងារដ៏ជិតស្និទ្ធរវាង ប៉ុល ពត, នួន ជា ហើយនិង ខៀវ សំផន បន្តនៅពេលដែលមេដឹកនាំហ្នឹងចូលមកដល់ភ្នំពេញក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។

អង្គហេតុដ៏សំខាន់ទាក់ទងទៅនឹងការបំលាស់ទី ហើយនិងសកម្មភាពរបស់បក្ស -- មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅក្នុងពេលនេះ គឺ ភី ភួន បានធ្វើសក្ខីកម្មបញ្ជាក់ ហើយនិងអ្នកមកផ្សេងទៀត ហើយ ខៀវ សំផន ក៏បានបញ្ជាក់ថា ដូច្នោះដែរ។ តិចជាងមួយសប្ដាហ៍បន្ទាប់ពីការរំដោះមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានចូលមកភ្នំពេញ ជាដំបូងពួកគេនៅស្ថានីយរថភ្លើង បន្ទាប់មកនៅក្រសួងពាណិជ្ជ-កម្ម ឬក៏ហិរញ្ញវត្ថុ។ ហើយនៅពាក់កណ្ដាលខែឧសភា ឆ្នាំ១៩៧៥ គឺគេបានទៅព្រះកែវមរកត។ នៅក្នុងបទសម្ភាសន៍របស់គាត់ជូនសហចៅក្រមស៊ើបអង្កេត ខៀវ សំផន បានបញ្ជាក់ដូចខាងក្រោមនេះ៖

[១៤:០២:២៥]

សូមដកស្រង់ "នួន ជា ហើយនិង ប៉ុល ពត បានយកខ្ញុំមកពីឧដុង្គមកភ្នំពេញ។ ពួកគាត់នាំខ្ញុំទៅអគារជាច្រើននៅស្ថានីយរថភ្លើង ខ្ញុំបាននៅស្ថានីយរថភ្លើងជាមួយ ប៉ុល ពត និងនួន ជា ហើយអ្នកផ្សេងៗទៀតដែលតែងតែមកកន្លែងហ្នឹង មកទទួលការណែនាំពី ប៉ុល ពត"។ បញ្ចប់សេចក្ដីដកស្រង់។

ភី ភួន បានរៀបរាប់អំពីស្ថានភាពនៅក្នុងដំណាក់កាលដំបូងរបស់មេដឹកនាំកម្ពុជានៅក្នុងភ្នំពេញ ដូចខាងក្រោមនេះ៖

“សំណួរ៖ សូមលោករៀបរាប់ឲ្យយើងច្បាស់បន្តិចទៀត តើប៉ុល ពត, នួន ជា, ខៀវ សំផន, អៀង សារី ហើយនិងមេដឹកនាំផ្សេងទៀតធ្វើអ្វីខ្លះនៅក្នុងពេលដែលពួកគេនៅស្ថានីយរថភ្លើង ហើយនៅក្រសួងពាណិជ្ជកម្មនោះ? តើលោកអាចប្រាប់យើងបន្ថែមទេ តើមានអ្វីកើតឡើងនៅពេលនោះ?” គាត់ឆ្លើយថា៖ “ខ្ញុំបានឃើញពួកគាត់ធ្វើការនៅស្ថានីយរថភ្លើង នៅអតីតក្រសួងពាណិជ្ជកម្ម ពួកគេបានជួប ហើយប្រជុំ ពួកគេជួបច្រើន ជួបទាំងថ្ងៃទាំងយប់។ ប្រជុំគ្នាទាំងថ្ងៃទាំងយប់។ សំណួរ៖ តើលោកបានឃើញគាត់ជួបជាមួយមេដឹកនាំយោធាអ្វី អ្នកណាខ្លះ? នៅស្ថានីយរថភ្លើងឬនៅក្រសួងពាណិជ្ជកម្ម? ចម្លើយ៖ ដល់ពេលនេះ ខ្ញុំចបានបញ្ជាក់ថា នៅស្ថានីយរថភ្លើង។ មេបញ្ជាការយោធាមកពីសមរភូមិនីមួយៗជាឧទាហរណ៍ មុខសញ្ញា តាម៉ុក, វន វ៉េត, កុយ ធួន, សោម ភីម អ្នកទាំងអស់នេះក៏តែងតែមកធ្វើការជាមួយពួកគាត់ជាទៀតទាត់ ហើយមេបញ្ជាការមកពីកងពលនានា ដែលមកប្រជុំនៅស្ថានីយរថភ្លើងដែរ។ បន្ទាប់មកយើងបានប្តូរទៅមន្ទីរ -- ក្រសួងពាណិជ្ជកម្ម ហើយនៅកន្លែងនោះ គឺកម្មាភិបាលមកពីសមរភូមិតែងតែចេញចូលទៅនោះ។ ពួកគេមកប្រជុំនៅទីនោះ ហើយគេធ្វើការនៅទីនោះជាទៀងទាត់។ ពួកគេធ្វើការជារៀងរាល់ថ្ងៃហើយនិងយប់នៅស្ថានីយរថភ្លើង ហើយនៅក្រសួងពាណិជ្ជកម្មនៅពេលណាមានការចាំបាច់ពួកគេបន្តធ្វើការប្រជុំរហូតដល់យប់ជ្រៅមែនទែន។ សំណួរ៖ តើនួនជាជាអ្នកចូលរួមទៀតទាត់នៅក្នុងការប្រជុំនេះទេ? ចម្លើយ៖ បាទ នៅពេលពេលដែលពួកគាត់ជួបគាត់មកជុំគ្នាទាំងអស់។ សំណួរ៖ តើ ខៀវ សំផន ជាអ្នកចូលរួមទៀងទាត់នៅក្នុងការប្រជុំនេះដែរឬទេ? ចម្លើយ៖ បាទ គាត់ទៀងទាត់។ អ្នកទាំងអស់នេះមកធ្វើការជាទៀងទាត់ដែលមាន ប៉ុល ពត, នួន ជា, ខៀវ សំផន, អៀង សារី ,សុន សេន ដែលធ្វើការជាប្រចាំថ្ងៃ ពួកគេធ្វើការជាមួយគ្នានៅទីនោះ”។ សូមបញ្ចប់សេចក្តីដកស្រង់។

[១៤:០៥:២០]

ភី ភួន ក៏បានបញ្ជាក់ផងដែរថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលរស់នៅជាមួយគ្នានៅក្នុងទីកន្លែងទាំងនេះ។ សំណួរ សូមដកស្រង់៖ “នៅក្នុងសម័យនោះ តើមេដឹកនាំនោះនៅជាមួយគ្នានៅស្ថានីយរថភ្លើង ហើយបន្ទាប់មកនៅក្រសួងពាណិជ្ជកម្មនោះ តើពួកគេរស់នៅ ហើយធ្វើការជាមួយគ្នាទាំងថ្ងៃទាំងយប់ឬទេ? តើពួកគេមានកន្លែងដាច់ដោយឡែកសម្រាប់ដេកពេលយប់ទេ? ចម្លើយ៖ អ្វីដែលខ្ញុំបាន

ឃើញ គឺថាអ៊ំ ប៉ុល ពត, នួន ជា, ខៀវ សំផន, អៀង សារី រស់នៅជិតគ្នា លើកលែងតែសុន សេន និងតាម៉ុក, វន វេត ហើយនិងកុយ ធួន ទេដែលរស់នៅដាច់ពីគេ។ សោ ភឹម ក៏មានកន្លែងរបស់គាត់រស់នៅដែរ។

លោក លោកស្រីចៅក្រម លោកស្រី ជា លាង សហសេវិករបស់ខ្ញុំបានពិភាក្សាពីការប្រជុំសំខាន់ៗដែលបានធ្វើឡើងនៅក្នុងពេលនេះរួចហើយ ហើយសេចក្តីសម្រេចដែលត្រូវបានធ្វើឡើងដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅក្នុងការប្រជុំទាំងនោះដែលមានការប្រជុំ១០ថ្ងៃរបស់គណៈមជ្ឈិមបក្សដែលធ្វើឡើងនៅព្រះវិហារព្រះកែវមរកតនៅក្នុងខែឧសភា ឆ្នាំ១៩៧៥។ ខ្ញុំនឹងពិភាក្សាពីចំណុចសំខាន់នៃការប្រជុំទាំងអស់នេះនៅពេលក្រោយ។

[១៤:០៦:៤៥]

លោកប្រធាន នៅពេលក្រោយមកទៀតនៅក្នុងឆ្នាំ១៩៧៥ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅភ្នំពេញក៏បានប្តូរការិយាល័យ -- មន្ទីរអចិន្ត្រៃយ៍ ហើយនិងលំនៅដ្ឋានរបស់គេទៅ ក-១ និងក-៣ ជាកន្លែងដែលនួន ជា, ខៀវ សំផន, ប៉ុល ពត និងអៀង សារី បន្តរស់នៅ ហើយនិងធ្វើការជាមួយគ្នាជារៀងរាល់ថ្ងៃក្នុងពេញមួយសម័យរបបកម្ពុជាប្រជាធិបតេយ្យ។

លោក លោកស្រីចៅក្រមបានឮសក្ខីកម្មទូលំទូលាយពីអ្នកយាម ហើយនិងនីរសាដែលធ្វើការនៅក-៣ ហើយនិងក-១។ សាក្សីដូចជាអ៊ុន តាំ, ស វិ, សូត្រ ទៀង, ពាន ឃាន ហើយនិង ឡេង ឈឿង។ អ្នកទាំងអស់នេះបានបញ្ជាក់ថាជនជាប់ចោទបានរស់និងធ្វើការនៅក-៣ និងក-១ ជាមួយសមាជិកផ្សេងទៀតនៃមជ្ឈិមបក្ស។ លោក ខៀវ សំផន ខ្លួនឯងបានទទួលស្គាល់ពីអង្គហេតុនេះនៅក្នុងសក្ខីកម្មបន្ទាប់របស់គាត់ជាមួយសហចៅក្រមស៊ើបអង្កេតតាមជាបទសម្ភាសន៍នោះ។ សូមដកស្រង់សម្តីគាត់ “ចំពោះខ្លួនខ្ញុំវិញ ខ្ញុំរស់នៅក-៣ បន្ទាប់ពីបាននៅក-១ ប្រហែលជាពីរ ឬបីខែ បន្ទាប់ពីបានយើងចេញ យើងបានចេញព្រះកែវមរកតនៅក្នុងរាជវាំង។ តាមពិតអ្នកដឹកនាំភាគច្រើនរស់នៅក-៣, អៀង សារី, សុន សេន, ហើយនិង នួន ជា។ ចំពោះ ប៉ុល ពត ម្តងម្កាលគាត់រស់នៅក្នុងក-៣ ពីព្រោះគាត់ត្រូវប្រុងប្រយ័ត្ន ហើយនិងប្រុងប្រយ័ត្នគ្រប់ពេលវេលា។ វាមិនមែនជារឿងខុសប្លែកទេដែលគាត់ត្រូវដូរផ្ទះពីកន្លែងមួយទៅកន្លែងមួយនោះ។ គាត់ក៏រស់នៅក្នុងក-១ដែរ។ ការប្រជុំគណៈអចិន្ត្រៃយ៍តែងតែធ្វើឡើងនៅមន្ទីរក-១ ប៉ុន្តែជួនកាលនៅក-៣–មន្ទីរក-៣ ជាផ្ទះរបស់ ប៉ុល ពត ហើយគេអាចធ្វើឡើងនៅផ្ទះបាយ”។ ចប់សេចក្តីដកស្រង់។

លោក ខៀវ សំផន ក៏បានរៀបរាប់អំពីទំនាក់ទំនងប្រចាំថ្ងៃជាមួយ ប៉ុល ពត និង នួន ជា នៅក្នុងកំណត់ត្រាវីដេអូនៃបទសម្ភាសន៍មួយ។

[១៤:០៩:00]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ខៀវ សំផន៖ ចំណែកឯការរស់នៅរាល់ថ្ងៃ ហូបបាយទឹក ទាំងលោក ប៉ុល ពត ទាំងលោក នួន ជា ហូបបាយជាមួយយើងខ្ញុំ ហូបបាយជាមួយខ្ញុំ ទាំងអស់គ្នាហូបបាយរួមអីចឹង។ អត់មានអីដោយឡែក"។*

[១៤:០៩:២៥]

លោក លោកស្រីចៅក្រម! ដូចគ្នានេះដែរយើងឃើញច្បាស់ថា នួន ជា ហើយនិង ខៀវ សំផន ហើយនិងសមាជិកគណៈអចិន្ត្រៃយ៍ ហើយមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាដែលមាន ប៉ុល ពត ធ្វើការ ហើយនិងទាក់ទងគ្នាជាញឹកញាប់ក្នុងកិច្ចប្រជុំ ហើយនិងទទួលភ្ញៀវបរទេសជារៀងរាល់ថ្ងៃ អំពីបញ្ហាការងារ ហើយដែលឃើញវីដេអូអំពីហេតុការណ៍ប្រាំមួយផ្សេងៗទៀត ដែលហេតុការណ៍កើតឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យដែលបង្ហាញពីសមមិត្តភាពដែលជិតស្និទ្ធ ទំនាក់ទំនងការងារ ជាពិសេស នួន ជា, ខៀវ សំផន ហើយនិងសមាជិកផ្សេងទៀតនៃគណៈអចិន្ត្រៃយ៍ផងដែរ។

លោក លោកស្រី គឺថាទី១ គឺនិយាយអំពីគណៈប្រតិភូមេដឹកនាំបក្សកុម្មុយនីស្តវៀតណាមដែលមកដល់ពោធិ៍ចិនតុង ប្រហែលជាថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៧៥ គឺមេដឹកនាំមជ្ឈិមបក្ស ប៉ុល ពត, នួន ជា, វន វេត, ខៀវ សំផន កំពុងស្វាគមន៍ពួកគាត់យ៉ាងកក់ក្តៅ ជាពិសេសក៏បានឱបគ្នា ហើយនិងថើបគ្នាផងដែរ។ គណៈប្រតិភូវៀតណាមបានមកពិភាក្សាអំពីបញ្ហាព្រំដែន។

នៅក្នុងឃ្លីបវីដេអូបន្ទាប់ គឺបង្ហាញពីមេដឹកនាំកំពូលរបស់បក្សកុម្មុយនីស្តវៀតណាម ចេញពីកម្ពុជានៅថ្ងៃទី១០ ខែសីហា ១៩៧៥ លោកឃើញ ប៉ុល ពត, នួន ជា, អៀង សារី ហើយ ខៀវ សំផន ហើយនិង វន វេត បានមកព្រលានយន្តហោះដើម្បីជូនដំណើរ ដែលពួកគាត់មើលទៅជាមនុស្សមានសុខភាពល្អណាស់។

[១៤:១១:៤៣]

ឃ្លីបបន្ទាប់យើងបង្ហាញអំពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន, នួន ជា, អៀង សារី និង វន វេត គឺបក់ដៃស្វាគមន៍ប្រធានាធិបតីឡាវ, សុផាណាវង្ស, ដែលមកដល់នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ

១៩៧៧ នៅពោធិ៍ចិនតុង។ ហើយឃ្លីបនេះបានបង្ហាញ ខៀវ សំផន បានទទួលស្គាល់ថាមាន -- បាទ ប្រធាន ខៀវ សំផន ពិភាក្សាជាមួយប្រធានាធិបតីឡាវ ហើយនៅមាន ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន, វន វេត, សុន សេន, អៀង ធីរិទ្ធ ក៏បានស្វាគមន៍មជ្ឈិមបក្សរបស់ចិននោះមកដែរ នៅពោធិ៍ចិនតុង។ ហើយឃ្លីបវីដេអូចុងក្រោយ គឺបង្ហាញអំពីមេដឹកនាំមជ្ឈិមបក្សមាន ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន, សុន សេន ហើយនិង វន វេត ដែលបានទះដៃស្វាគមន៍ការធ្វើមីទ្ទិងសន្និបាតមួយដែលគេធ្វើឡើងនៅស្តាតអូឡាំពិកនៅក្នុងទីក្រុងភ្នំពេញ ហើយប្រហែលជាធ្វើនៅក្នុងឆ្នាំ១៩៧៥។

[១៤:១៣:០៣]

លោក លោកស្រីចៅក្រម! ក្នុងរយៈពេលសវនាការពីរឆ្នាំកន្លងមកនេះ គឺមានសាក្សីតែមួយរូបប៉ុណ្ណោះដែលព្យាយាមជំទាស់ថា ខៀវ សំផន មិនបានរស់នៅ និងធ្វើការជាមួយ នួន ជា និង ប៉ុល ពត ព្រមទាំងមេដឹកនាំមជ្ឈិមបក្សដទៃទៀតជារៀងរាល់ថ្ងៃនោះឡើយ។ អ្នកដែលផ្តល់សក្ខីកម្មបែបនេះ គឺជាភរិយារបស់គាត់ឈ្មោះ សូ សុជាតិ។ សូ សុជាតិ បានអះអាងថា ក្នុងពេលក្រោយមកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មេដឹកនាំដទៃទៀតបានរើចេញពីក-៣។ សក្ខីកម្មរបស់គាត់គឺមិនស្របជាមួយនឹងសក្ខីកម្មរបស់សាក្សីដទៃទៀតឡើយ។ សក្ខីកម្មរបស់ ខៀវ សំផន ក៏បានបញ្ជាក់ផ្ទុយពីនេះដែរ។ ការពិតទៅពាក្យទាំងអស់នេះគឺជាពាក្យរបស់ភរិយាដ៏ស្មោះត្រង់ ដែលព្យាយាមបង្ហាញថា ប្តីរបស់គាត់មិនបាននៅជិតជាមួយមេដឹកនាំដែទៀតឡើយ ហើយសក្ខីកម្មបែនេះគឺមិនមានភាពអាចទុកចិត្តបាន ហើយត្រូវតែបដិសេធដោយអង្គជំនុំជម្រះ។ លោក លោកស្រីចៅក្រម ទំនាក់ទំនងដ៏ជិតស្និទ្ធ និងភាពមិនអាចផ្តាច់បានរវាង ប៉ុល ពត, នួន ជា និង ខៀវ សំផន គឺមិនមានអ្វីដែលអាចជំទាស់បាននោះឡើយ។ យើងទើបតែបានឮពាក្យសម្តីរបស់ ខៀវ សំផន ដែលនិយាយថា យើងមិនដែលធ្វើអ្វីដាច់ពីគ្នានោះឡើយ។ ភស្តុតាងក៏បានបង្ហាញថា មេដឹកនាំទាំងបីនេះគាំទ្រគ្នា ហើយនិងបានការពារគ្នាទៅវិញទៅមក។

[១៤:១៤:១៥]

នៅពេលដែលគេឆ្លើយដាក់ ខៀវ សំផន នៅក្នុងចម្លើយសារភាព ស-២១ នៅក្នុងឆ្នាំ១៩៧៨ គឺ នួន ជា ធ្វើការការពារគាត់។ យើងបានឮសក្ខីកម្មពីប្រធាន ស-២១ គឺ ឌុច ដែល ឌុច បាននិយាយថា "នួន ជា គំរាមគាត់នៅពេលដែល នួន ជា ដឹងថា ខៀវ សំផន ត្រូវបានគេឆ្លើយដាក់។ ហើយ នួន ជា បានបង្គាប់ដល់ ឌុច ថា បងហែម ដែលជា ខៀវ សំផន ហ្នឹងមិនត្រូវឲ្យមានលើកយកមកនិយាយនៅក្នុងចម្លើយសារភាពស-២១ទៀតឡើយ"។ ហេតុការណ៍នេះត្រូវបានគេពិភាក្សាយ៉ាងលម្អិតនៅក្នុងសៀវភៅ

របស់ ថេត សម្បត្តិ នៅពេលដែល នួន ជា គាត់បានសារភាពថា គាត់ធ្លាប់ជួបប្រជុំជាមួយ ឌុច ហើយ នៅពេលនោះគាត់បាន -- ហើយគេប្រាប់ថាមានការឆ្លើយដាក់ ខៀវ សំផន គឺបងហែម ហ្នឹង។ បន្ទាប់មកទៀត គឺ នួន ជា គាត់បានបង្ហាញអំពីប្រតិកម្មរបស់គាត់ដូចតទៅនេះ។ ខ្ញុំសូមដកស្រង់សម្ដីរបស់ នួន ជា៖ “ខ្ញុំគិតថា ប្រសិនបើឥឡូវនេះ គេចោទប្រកាន់ ខៀវ សំផន។ អ៊ីចឹងមានន័យថាក្រោយមកទៀត ពួកគេអាចចោទមនុស្សទាំងអស់បាន ហើយខ្ញុំស្ថិតនៅក្នុងចំណោមមនុស្សទាំងអស់នោះ។ ប្រសិនបើ ខៀវ សំផន ក្បត់អង្គការ អ៊ីចឹងមានន័យថា មនុស្សទាំងអស់គ្នា ក៏ក្បត់អង្គការដែរ”។ ខ្ញុំសូមបញ្ចប់ការដកស្រង់។

តាមរយៈនេះបានបង្ហាញថា នួន ជា មានទាំងចេតនា មានទាំងសិទ្ធិអំណាចក្នុងការជួយសង្គ្រោះបងប្អូនរបស់គាត់ដែលស្មោះត្រង់គឺ ខៀវ សំផន នេះ។ ហើយក្នុងពេលជាមួយគ្នានេះ គឺថាគាត់ឲ្យមនុស្សរាប់ពាន់ដទៃទៀត ត្រូវបានគេសម្លាប់ ឬក៏ត្រូវបានធ្វើទារុណកម្ម ដោយសារតែចម្លើយសារភាពស-២១ ដែលមិនអាចទុកចិត្តបាននេះ។

[១៤:១៥:៥៦]

លោក លោកស្រីចៅក្រម ចំណងទាក់ទងរវាង នួន ជា, ខៀវ សំផន និង ប៉ុល ពត នៅតែបន្តរហូតមកដល់ក្រោយខែមករា ឆ្នាំ១៩៧៩ ដែលនៅក្នុងពេលនេះ គឺពួកគេរស់នៅតាមតំបន់ភ្នំ នៅតាមព្រំដែនថៃ បន្តធ្វើការងារជាមួយគ្នា ជាមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម រហូតដល់ថ្ងៃចុងក្រោយរបស់ពួកគេ គឺការបញ្ចប់ដោយឈឺចាប់របស់ចលនាបដិវត្តន៍របស់ពួកគេ។ នៅក្នុងឆ្នាំ១៩៩៧ បន្ទាប់ពីពួកខ្មែរក្រហមដ៏ទៃទៀតបានចាប់ ប៉ុល ពត ដាក់ឃុំខ្លួនក្នុងផ្ទះ។ នួន ជា បានបដិសេធមិនប្រគល់ ប៉ុល ពត ទៅអាជ្ញាធរកម្ពុជា ឬក៏អាជ្ញាធរអន្តរជាតិ ដើម្បីធ្វើការជំនុំជម្រះឡើយ។ ដោយគាត់និយាយថ្លែងនៅក្នុងកាសែតបាងកកប៉ុស្ដិ៍ថា៖ “យើងត្រូវតែមានសីលធម៌។ យើងត្រូវតែការពារមិនឲ្យគេយក ប៉ុល ពត ទៅណាបានឡើយ”។

នៅក្នុងសៀវភៅ ថេត សម្បត្តិ, នួន ជា បានពិពណ៌នាអំពីការដែលគាត់ និង ខៀវ សំផន បានដើរជាមួយគ្នា ហើយការជជែកគ្នាជាសម្ងាត់ បន្ទាប់ពី ប៉ុល ពត ស្លាប់នៅឆ្នាំ១៩៩៨។ ហើយបន្ទាប់មកពួកគាត់ទាំងពីរនាក់សម្រេចចិត្តថា វាដល់ពេលដែលត្រូវចេញពីពួកខ្មែរក្រហម ហើយចុះចូលជាមួយរដ្ឋាភិបាលកម្ពុជាហើយ។ នៅពេលដែលពួកគាត់មកដល់ទីក្រុងភ្នំពេញ នួន ជា ហើយនិង ខៀវ សំផន បានធ្វើសន្និសីទកាសែតមួយរួមគ្នា នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨។ ពេលនោះ គឺពួកគាត់បានថ្លែងច្បាស់

ទៅកាន់ពិភពលោក ថាពួកគេមិនមានការសោកស្ដាយ ហើយក៏មិនបានខ្វល់ខ្វាយអំពីជនរងគ្រោះនៃរបបខ្មែរក្រហមនោះឡើយ។ ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតចាក់ខ្សែវីដេអូ។

[១៤:១៧:៤០]

*(ការបង្ហាញជាឯកសារសំឡេង-រូបភាព)*

*"គឺថាបំភ្លេចចោលទៅ អ្វីដែលហួសហើយ វាឲ្យហួសទៅ។ អ្វីដែលកន្លងហួសហើយ យើងត្រូវបំភ្លេច វាជាដំណោះស្រាយដ៏ល្អបំផុត។ គឺជាដំណោះស្រាយល្អសម្រាប់ប្រជាជនកម្ពុជា"។*

ហើយឥឡូវនេះ ខ្ញុំសូមអនុញ្ញាតចាក់នូវឃ្លីបវីដេអូបន្តទៀត ដែលគេដកស្រង់ចេញពីសន្និសីទកាសែតដដែល ហើយនេះគឺជាអ្វីដែល នួន ជា បាននិយាយ។

*"យើងសែនសោកស្ដាយជាទីបំផុត មិនមែនត្រឹមតែអាយុជីវិតរបស់ប្រជាជនទេ សូម្បីតែអាយុជីវិតរបស់សត្វទាំងឡាយដែលមានជីវិត ដែលយើងថា ហើយត្រូវគ្រោះថ្នាក់ដោយសារសង្គ្រាម។ យើងខ្ញុំសោកស្ដាយជាទីបំផុត"។*

[១៤:១៨:៥១]

លោក លោកស្រីចៅក្រម! ដោយសារតែពួកគាត់មានទំនាក់ទំនងជិតស្និទ្ធជាមួយគ្នា ក្នុងនាមជាមេដឹកនាំខ្មែរក្រហមអស់រយៈ២៨ឆ្នាំមកហើយនោះ។ ខៀវ សំផន ហើយនិង នួន ជា ប្រាកដណាស់ថាពួកគេស្គាល់គ្នាច្បាស់។ បញ្ហានេះធ្វើឲ្យខ្ញុំគិតទៅដល់ការកុហកមួយទៀត ដែលយើងបានស្ដាប់ឮពីជនជាប់ចោទនៅក្នុងពេលសវនាការនេះ។ ទោះបីថាគាត់ធ្លាប់ធ្វើការជាមួយគ្នាជិតស្និទ្ធជាមួយ ខៀវ សំផន ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៩៨ ក៏ដោយ គឺថាសឹងថាគ្រប់ពេលទាំងអស់ នៅពេលដែលគេសួរសំណួរអំពី ខៀវ សំផន នៅក្នុងការជំនុំជម្រះនេះ នួន ជា តែងតែអះអាងថា គាត់មិនដឹងអ្វីទាំងអស់អំពីបុរសរូបនេះ។ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ នួន ជា បានបញ្ជាក់នៅក្នុងតុលាការនេះថា៖ "ខ្ញុំមិនស្និទ្ធស្នាលជាមួយលោក ខៀវ សំផន ទេ។ ខ្ញុំគ្រាន់តែដឹងថា គាត់មកពីប្រទេសបារាំង ហើយគាត់ជាសមាជិកបក្ស"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។ ពីរបីនាទីក្រោយមក ចៅក្រម ឡាវែន៍ បានសួរ នួន ជា "ថាតើគាត់ដឹងថា ខៀវ សំផន គឺជាសមាជិករបស់មជ្ឈិមបក្សដែរឬទេ?" គាត់ឆ្លើយថា "លោកចៅក្រមខ្ញុំមិនដឹងទេ" បញ្ចប់ការដកស្រង់។ នួន ជា ក៏ចូលចិត្តនិយាយ ពង្វាងដូចគ្នានៅពេលដែលព្រះរាជអាជ្ញាសួរអំពី ខៀវ សំផន នៅពេលដែលគេសួរថាតើ ខៀវ សំផន គឺជាប្រធាននៃគណៈប្រធានរដ្ឋដែលឬអត់? នួន ជា បានឆ្លើយថា៖ "លោកប្រធាន ខ្ញុំមិនពាក់ព័ន្ធនឹងការងាររដ្ឋបាលនោះទេ ខ្ញុំពាក់ព័ន្ធតែទៅនឹងការអប់រំ"។

គាត់អះអាងថា គាត់មិនដឹងថាតើពេលណាដែល ខៀវ សំផន ចូលបក្សនោះឡើយ។ ហើយថាគាត់មិនដឹងអ្វីទាំងអស់ពី ខៀវ សំផន ដែលរត់ចេញពីទីក្រុងភ្នំពេញ ហើយបានចូលព្រៃម៉ាគីនៅក្នុងឆ្នាំ១៩៦៧ នោះឡើយ។ នួន ជា គាត់អះអាងថា គាត់មិនអាចប្រាប់អង្គជំនុំជម្រះបានអំពីតួនាទីរបស់ ខៀវ សំផន នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ឬក៏រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានោះឡើយ។ នៅពេលដែលគេសួរថាតើគាត់ដឹងថា ខៀវ សំផន ស្នាក់នៅទីណាដែរក្នុងចន្លោះឆ្នាំ១៩៧០ រហូតមកដល់ខែមេសា ១៩៧៥ គាត់ឆ្លើយថា “ខ្ញុំមិនដឹងទេ ពីព្រោះថាវាគឺជាកិច្ចការសម្ងាត់”។ នួន ជា ក៏បានអះអាងផងដែរថា គាត់មិនដែលចូលរួមការប្រជុំជាមួយ ខៀវ សំផន នោះឡើយ។ ប្រាកដណាស់ថាគាត់មិនបានដឹងថា ខៀវ សំផន ខ្លួនគាត់បានសារភាពរួចទៅហើយថាគាត់បានចូលរួម ជាទៀងទាត់នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នោះ។ គឺថាចូលរួមនៅក្នុងការប្រជុំដែល នួន ជា បានចូលរួមផងដែរ។ ការនិយាយកុហកមិនសមហេតុផលទាំងអស់នេះរបស់ នួន ជា គឺប្រាកដណាស់ថា គឺគាត់និយាយថា គាត់កម្រនិយាយ ឬក៏គាត់កម្រទាក់ទងជាមួយ ខៀវ សំផន ដោយសារ ខៀវ សំផន ស្ថិតនៅក្រុមបញ្ញាជន។

[១៤:២១:៥៧]

លោក លោកស្រីចៅក្រម ខ្ញុំសូមលើកឡើងថា ហេតុផលសម្រាប់ការផ្តល់សក្ខីកម្មដែលពុំគួរ ឲ្យជឿរបស់នួនជា នោះគឺវាមានលក្ខណៈងាយស្រួលនោះទេ។ ដូចដែលគាត់ធ្វើនៅក្នុងឆ្នាំ១៩៧៨ នៅពេលដែលឈ្មោះរបស់ ខៀវ សំផន ត្រូវបានគេសរសេរនៅក្នុងចម្លើយសារភាពស-២១ នួន ជា គឺព្យាយាមការពារមិត្តភក្តិជិតស្និទ្ធ ហើយនិងបងប្អូនរបស់គាត់មិនឲ្យមានការជំនុំជម្រះនោះឡើយ។ ហើយគាត់ព្យាយាមនិយាយកុហកគ្រប់មធ្យោបាយដើម្បីការពារបងប្អូនរបស់គាត់។ ខ្ញុំនឹងនិយាយពីបញ្ហានេះនៅពេលក្រោយ នៅពេលដែលយើងនិយាយអំពីការប្រជុំដែលគេធ្វើឡើងនៅពេលដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាសម្រេចដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយដែលជាប្រធានបទមួយដែល នួន ជា គាត់ទទួលស្គាល់ថា គាត់បានចូលរួមនៅក្នុងការប្រជុំនេះ ប៉ុន្តែគាត់និយាយកុហកអំពីការចូលរួមរបស់សហជនជាប់ចោទរបស់គាត់។

[១៤:២៣:០០]

លោកប្រធាន លោក លោកស្រីចៅក្រម ដើម្បីឲ្យយើងអាចយល់ច្បាស់អំពីការអនុវត្តសិទ្ធិអំណាចរបស់ជនជាប់ចោទទាំងអស់នេះយើងត្រូវតែគិតផងដែរអំពីដំណើរការធ្វើការសម្រេចចិត្តនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ហើយយើងនឹងពិនិត្យមើលអំពីតួនាទី និងការចូលរួមរបស់ជនជាប់ចោទនៅក្នុង

ឧក្រិដ្ឋកម្មនេះ។ គោលការណ៍សំខាន់គឺថា ប្រជាធិបតេយ្យប្រមូលផ្តុំ និងការសម្រេចចិត្តជាសមូហភាព ហើយវាគោលការណ៍ដ៏សំខាន់របស់បក្សកុម្មុយនីស្តកម្ពុជានិងកម្ពុជាប្រជាធិបតេយ្យ។ វាមិនអាចជៀសរួចទេ ដែលថានៅក្នុងការជំនុំជម្រះបែបនេះ ជនជាប់ចោទតែងតែមានពេលណាមួយព្យាយាមចង្អុល ឬក៏បន្ទោសទៅលើអ្នកដទៃទៀត គឺថាបន្ទោសថាអ្នកដទៃគឺជាអ្នកទទួលខុសត្រូវ ហើយមិនមែនខ្ញុំទេ គឺវាជា ប៉ុល ពត, មិនមែនខ្ញុំទេ វាគឺជាលេខាតំបន់ជាដើម។

លោក លោកស្រីចៅក្រម នៅទីនេះជនជាប់ចោទគាត់មានបញ្ហាជាច្រើននៅក្នុងការលើកទឡ្ហីករណ៍បែបនេះ ព្រោះថានៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ការសម្រេចគឺមិនមែនធ្វើឡើងដោយបុគ្គលនោះឡើយ។ ការសម្រេចត្រូវធ្វើជាសមូហភាពដោយមជ្ឈិមបក្សហើយនិងគណៈកម្មាធិការដឹកនាំ ដែលនៅក្នុងគណៈកម្មាធិការនោះគឺ នួន ជា ហើយនិង ខៀវ សំផន បានចូលរួមហើយបានដើរតួនាទីយ៉ាងសំខាន់។ គោលការណ៍ជាមូលដ្ឋាននេះបានបង្ហាញយ៉ាងច្បាស់នៅក្នុងឯកសារសំខាន់បំផុតដែលគ្រប់គ្រងទៅលើសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ដែលឯកសារនោះគឺលក្ខន្តិកៈមជ្ឈិមបក្ស លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា។ ជំពូកបីនៃលក្ខន្តិកៈនេះគឺបាននិយាយថា អំពីលក្ខខណ្ឌចាត់តាំងរបស់បក្ស ហើយមាត្រា៦ បានចែងថា "បក្សកុម្មុយនីស្តកម្ពុជា ប្រកាន់យកគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ធ្វើការជាមូលដ្ឋានចាត់តាំងរបស់ខ្លួន។ គឺថាគ្រប់អង្គការដឹកនាំរបស់បក្សត្រូវអនុវត្តរបបដឹកនាំសមូហភាព ហើយមានបុគ្គលទទួលខុសត្រូវដោយឡែកពីគ្រប់ការសម្រេចផ្សេងៗរបស់បក្ស ត្រូវធ្វើឡើងដោយសមូហភាព"។ សូមបញ្ចប់ការដកស្រង់។

[១៤:២៥:២៦]

"មាត្រា៣(ក) នៃលក្ខន្តិកៈគឺទទួលស្គាល់អំពីសិទ្ធិរបស់បក្ខជន ដែលខ្ញុំសូមធ្វើការដកស្រង់៖ "បេក្ខជនពេញសិទ្ធិគ្រប់រូបសុទ្ធតែមានសិទ្ធិដូចតទៅនេះ៖ ពិគ្រោះ ពិភាក្សា និងរួមមតិសម្រេចកិច្ចការទាំងអស់របស់បក្ស ដោយធ្វើទៅតាមលាក់ការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។ នៅពេលដែលគេសួរ នួន ជា អំពីលក្ខន្តិកៈបក្ស ហើយនិងគោលការណ៍នៃការធ្វើការសម្រេចសមូហភាព ហើយនៅពេលដែលចាប់ផ្តើមសវនាការនេះ។ សក្ខីកម្មរបស់គាត់ និងការទទួលស្គាល់របស់គាត់អំពីបញ្ហាហ្នឹងគឺមានសារៈសំខាន់ ចំពោះគោលការណ៍សំខាន់នៃសំណុំរឿងនេះ។ គឺអត្ថិភាពនៃផែនការឧក្រិដ្ឋកម្មរួមដែលជនជាប់ចោទបានឯកភាព។ ហើយខ្ញុំឥឡូវនេះចង់ឲ្យលោក លោកស្រីចៅក្រម ពិនិត្យមើលទៅលើសក្ខីកម្មទាំងអស់នេះជាលម្អិត។

នៅក្នុងសក្ខីកម្មដំបូងដែលខ្ញុំអានគឺដកស្រង់ចេញពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ គឺនៅក្នុងសវនាការតុលាការនេះ នៅពេលដែលគេសួរ នួន ជា ឲ្យពិពណ៌នាអំពីគោលការណ៍នៃប្រជាធិបតេយ្យប្រមូលផ្តុំ និងការសម្រេចជាសមូហភាពនោះ គាត់បានបកស្រាយថា -- លោក នួន ជា បានឆ្លើយថា៖ "លោកប្រធាន! ប្រជាធិបតេយ្យប្រមូលផ្តុំ សំដៅទៅលើការប្រមូលគំនិត និងទស្សនៈ ព្រមទាំងចំណេះដឹងពីបក្ខជន ហើយនិងមជ្ឈិមបក្ស។ ហើយប្រជាធិបតេយ្យប្រមូលផ្តុំនេះត្រូវបានអនុវត្តជាទូទៅ និងជាទូលំទូលាយ។ ទាំងអស់នេះគឺអនុវត្តផងដែរ ចំពោះសាខាបក្សនៅតាមភូមិ ហើយនិងឃុំ។ ពួកគេក៏អនុវត្តអំពីប្រជាធិបតេយ្យប្រមូលផ្តុំ ដែលថាប្រមូលផ្តុំនូវគំនិតទាំងអស់របស់សមាជិកបក្ស ហើយប្រសិនបើមិនមាន ឬក៏ប្រសិនបើមានគំនិតខុស ពេលនោះសមាជិកបក្សនៅកម្រិតស្រុកអាចធ្វើការកែ ឬក៏អាចបន្ថែមទៅលើគំនិតទាំងអស់នោះ"។ សំណួរ៖ ខ្ញុំចង់ឲ្យលោកនិយាយយោងទៅលើមាត្រា៦(២) ដែលបានចែងថា "សេចក្តីសម្រេចទាំងអស់របស់បក្សត្រូវតែធ្វើជាសមូហភាព"។ តើគោលការណ៍នៃការធ្វើការសម្រេចជាសមូហភាព គឺជាគោលការណ៍នៃប្រជាធិបតេយ្យប្រមូលផ្តុំដែរឬទេ? ឆ្លើយ៖ លោកប្រធានមាត្រា២ ការសម្រេចចិត្តទាំងអស់របស់បក្សត្រូវតែធ្វើជាសមូហភាព គឺមានន័យថា ការសម្រេចចិត្តរបស់បក្ស ត្រូវតែធ្វើជាសមូហភាពមិនមែនធ្វើជាបុគ្គលនោះទេ។ សំណួរ៖ តើគោលការណ៍ ការធ្វើសេចក្តីសម្រេចចិត្តប្រមូលផ្តុំ សេចក្តីសម្រេចចិត្តជាសមូហភាព និងប្រជាធិបតេយ្យប្រមូលផ្តុំគឺជាផ្នែកមួយនៃលក្ខន្តិកៈបក្សដែលត្រូវបានអនុម័តនៅក្នុងសមាជបក្សនៅក្នុងឆ្នាំ១៩៦០ ដែរឬទេ? ចម្លើយ៖ លោកប្រធាន ប្រជាធិបតេយ្យប្រមូលផ្តុំ គឺជាផ្នែកមួយនៃការដឹកនាំជាសមូហភាព ហើយការដឹកនាំជាសមូហភាព គឺជាផ្នែករបស់ប្រជាធិបតេយ្យប្រមូលផ្តុំ។ គោលការណ៍នេះត្រូវបានអនុម័ត ហើយអនុវត្តនៅក្នុងគ្រប់កិច្ចប្រជុំទាំងអស់នៃសមាជបក្ស។ ហើយបក្សគោរពទៅតាមគោលការណ៍នេះយ៉ាងខ្ជាប់ខ្ជួន។ សំណួរ៖ តើនេះគឺជាគោលការណ៍ដែលគេអនុវត្តក្នុងពេលដែលលោកមានតួនាទីជាអនុលេខាបក្ស តើវាត្រឹមត្រូវដែរឬទេ? ចម្លើយ៖ លោកប្រធានគឺវាត្រឹមត្រូវ។

[១៤:២៩:១២]

បន្ទាប់មកទៀត នួន ជា ត្រូវបានគេសួរឲ្យបញ្ជាក់ ថាតើគោលការណ៍នៃការធ្វើសេចក្តីសម្រេចចិត្តជាសមូហភាពត្រូវបានគោរពនៅតាមកិច្ចប្រជុំនៃគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមបក្សរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬអត់។ "សំណួរ៖ តើគោលការណ៍នៃការធ្វើការសម្រេចចិត្តជាសមូហភាពត្រូវបានគេគោរពនៅក្នុងការប្រជុំគណៈមជ្ឈិមនិងគណៈអចិន្ត្រៃយ៍ដែលលោកបានចូលរួមដែរឬទេ? ចម្លើយ៖

បាទ លោកចៅក្រមគឺវាត្រូវបានគេអនុវត្តបែបនេះមែន។ សំណួរ៖ តើលោកអាចពណ៌នា ឬក៏ពន្យល់មកដល់អង្គជំនុំជម្រះអំពីដំណើរការដែលអង្គការបក្សដូចជាគណៈអចិន្ត្រៃយ៍ ឬក៏គណៈមជ្ឈិមធ្វើការសម្រេចជាសមូហភាពដែរឬទេ? ចម្លើយ៖ លោកប្រធានសមូហភាព គឺមានន័យថា គ្រប់គ្នាចូលរួមនៅក្នុងការប្រជុំដើម្បីបង្ហាញពីគំនិតរបស់ពួគេ។ ការប្រជុំទាំងអស់ គឺគោរពទៅតាមគោលការណ៍នេះ ហើយមិនមែនតែនៅក្នុងមជ្ឈិមបក្ស គណៈមជ្ឈិមនោះទេ គឺថាសូម្បីតែគណៈអចិន្ត្រៃយ៍ក៏មានដែរ។ ហើយបន្ទាប់មកទៀត គឺលេខាបក្ស គឺប្រមូលផ្តុំនៅគំនិតទាំងអស់ និងទស្សនៈទាំងអស់ ប្រសិនបើសមាជិកទាំងអស់មិនពេញចិត្ត បន្ទាប់មកទៀតហ្នឹង ពួកគាត់ទាំងអស់គ្នាហ្នឹងអាចលើកនៅការជំទាស់របស់ពួកគាត់ ឬក៏ការប្រឆាំងរបស់ពួកគាត់រហូតដល់ពួកគេអាចឈានទៅដល់ការព្រមព្រៀងជាឯកឆ្ឆន្ទ។ បន្ទាប់មកទៀត គឺការសម្រេចចិត្តហ្នឹង គឺជាការសម្រេចចិត្តផ្លូវការ។ ហេតុដូច្នេះ ប្រសិនបើមិនមានការឯកភាពទាំងស្រុងនោះទេ គឺចាំបាច់ត្រូវឲ្យមានការពិភាក្សាជាបន្តបន្ទាប់ទៅមុខ។ សំណួរ៖ តើការពណ៌នាដែលលោកបានរៀបរាប់នៃកាឈានទៅដល់ការសម្រេចជាសមូហភាពហ្នឹង ថាតើវាជាការអនុវត្តដែលគោរពទៅដោយគណៈអចិន្ត្រៃយ៍ ឬក៏គណៈមជ្ឈិមដែរឬទេក្នុងពេលដែលលោកធ្វើជាអនុលេខាបក្ស? តើវាជាការត្រឹមត្រូវដែរឬទេ? ចម្លើយ៖ មិនមែនតែត្រឹមក្នុងពេលដែលខ្ញុំធ្វើជាអនុលេខាបក្សប៉ុណ្ណោះទេ វាគឺធ្វើនៅគ្រប់ដំណាក់កាលទាំងអស់ នៅគ្រប់ពេលទាំងអស់។ គោលការណ៍នេះត្រូវបានអនុវត្តជាទូទៅ ហើយវាជាគោលការណ៍ជារួមសម្រាប់បក្ស។ វាត្រូវបានអនុវត្តចាប់ពីលេខាបក្សរហូតទៅដល់គណៈមជ្ឈិម។” សូមបញ្ចប់ការដកស្រង់។

[១៤:៣១:៣៩]

លោក លោកស្រីចៅក្រម ទោះបីថាមានបុគ្គលមួយចំនួន ឬក៏អ្នកនិពន្ធសៀវភៅមួយចំនួនបានធ្វើការចោទសួរថា តើថ្នាក់ដឹកនាំបក្សគោរពទៅតាមគោលការណ៍នៃការសម្រេចជាសមូហភាព ឬក៏អត់នោះក៏ដោយ ប៉ុន្តែពួកគាត់មិនអាចទទួលព័ត៌មានឲ្យបានលម្អិត ហើយនិងច្បាស់លាស់ដែលលោក លោកស្រីចៅក្រមបានស្តាប់ឮពីអនុលេខាបក្សរបស់បក្សកុម្មុយនីស្តកម្ពុជានោះឡើយ។ នៅក្នុងពេលមួយដែលគាត់និយាយដោយស្មោះត្រង់នៅក្នុងសវនាការនេះ នួន ជា គាត់មិនអាចបញ្ជាក់អ្វីឲ្យបានច្បាស់ជាងពេលនោះឡើយ គឺថាសេចក្តីសម្រេចត្រូវធ្វើជាសមូហភាព មិនមែនធ្វើជាបុគ្គល ហើយវាជាគោលការណ៍ជារួមដែលបក្សត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួន ហើយនិងត្រូវបានអនុវត្តនៅគ្រប់កម្រិតទាំងអស់។ គឺជាគោលការណ៍ដែលទាមទារឲ្យមានការពិភាក្សា ដែលត្រូវបន្តរហូតទៅដល់ពេលមានការឯកភាពជា

ឯកឆ្ឆន្ទ ហើយនេះគឺជាសារៈសំខាន់បំផុតនៃសហកម្មឧក្រិដ្ឋកម្មរួម។ ទោះបីថាមេធាវី នួន ជា នៅតែព្យាយាមជំទាស់ជាមួយចំណុចទាំងអស់នេះ នៅក្នុងកថាខណ្ឌ១៨៩ នៃសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ពួកគេក៏ដោយ ហើយដែលថាខ្លួនមិនអាចឲ្យមានការពិភាក្សាបន្តដោយគ្មានពេលបញ្ចប់នោះក៏ដោយ។ ពួកគេមិនបានជំទាស់ថា លក្ខខណ្ឌតម្រូវនៃការសម្រេចជាសមូហភាព គឺជាគោលការណ៍សំខាន់នៃបក្សកុម្មុយនីស្តកម្ពុជានោះឡើយ។ ទោះបីថាមេធាវីរបស់គាត់មានជំនាញ ឬក៏ឆ្លាតយ៉ាងណាក៏ដោយ ក៏ពួកគេមិនអាចជៀសផុតពីការទទួលស្គាល់កូនក្តីរបស់ខ្លួនដែលថា គាត់បានធ្វើបែបនេះនៅក្នុងសវនាការនោះឡើយ។

[១៤:៣៣:២៩]

លោក លោកស្រីចៅក្រម !ខៀវ សំផន ក៏បានទទួលស្គាល់អំពីលក្ខខណ្ឌតម្រូវនៃការធ្វើការសម្រេចជាសមូហភាព និងជាឯកឆ្ឆន្ទដោយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផងដែរ។ នៅក្នុងកិច្ចសម្ភាសន៍មួយដែលគាត់បានពិភាក្សាអំពីការជម្លៀសប្រជាជនចេញពីទីក្រុង ខៀវ សំផន បានបញ្ជាក់ថា ខ្ញុំសូមដកស្រង់៖ “ប្រសិនបើមានការជំទាស់តែមួយទៅលើការជម្លៀសប្រជាជននោះ ប្រហែលជានៅពេលនោះមិនមានការជម្លៀសប្រជាជននោះឡើយ”។

លោក លោកស្រីចៅក្រម ខ្ញុំសូមអនុញ្ញាតចាក់បង្ហាញនូវឃ្លីបវីដេអូមួយដែលជាការសម្ភាស ខៀវ សំផន។ ឥឡូវនេះ ខ្ញុំសូមបង្ហាញជូន។

[១៤:៣៤:១២]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*ប៉ុន្តែដល់ជម្លៀសទៅ វាមានបញ្ហាស្មុគស្មាញច្រើន មានស្លាប់មានអីអ៊ីចឹងច្រើន អាចកម្មាភិបាលផ្ទៃក្នុងយើងខ្លះក៏ប៉ះពាល់ដល់បងប្អូនគេស៊ីៗគេអ៊ីចឹងទៅ នាំឲ្យកើតមានទំនាស់ ហើយអ្នកដែលនៅក្នុងគណៈអចិន្ត្រៃយ៍ដែលយល់ស្របជម្លៀសហើយ វាទៅជាដកថយវិញ វាថយវិញ វាទៅជាទំនាស់។ ពេលនុ៎ង បើមានសំឡេងតែមួយប្រឆាំងមិនឲ្យជម្លៀសក៏អត់ជម្លៀសកើតទេ។ ប៉ុន្តែយល់ស្របហើយដោយសារឃើញថា បើមិនជម្លៀសវាងាប់ ពីព្រោះវាអត់បាយ។ អ៊ីចឹងយល់ស្របថាជម្លៀស។ ហើយដល់ជម្លៀសហើយ រៀបចំជាសហករណ៍។ រៀបចំជាសហករណ៍ ដល់សហករណ៍កម្រិតខ្ពស់អ៊ីចឹងទៅ។ (បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:៣៥:៣០]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំគិតថាឥឡូវនេះយើងដូចជាដល់ពេលសម្រាកហើយ ថាតើលោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្ត ឬក៏សម្រាកនៅពេលនេះ?

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៦ នាទី ដល់ម៉ោង ១៤:៥៦ នាទី)*

[១៤:៥៦:២១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនសហព្រះរាជអាជ្ញាដើម្បីបន្តការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

យើងបានឈប់សម្រាកមុននេះ ដែលមុននេះយើងនិយាយអំពីគោលការណ៍នៃប្រជាធិបតេយ្យប្រមូលផ្តុំនិងការសម្រេចចិត្តនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ហើយឥឡូវនេះខ្ញុំបន្តពិភាក្សាអំពីប្រធានបទបន្ថែមនេះ មុនពេលដែលយើងពិនិត្យបន្តទៀតទៅលើគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ហើយតួនាទីនៃការរាយការណ៍ ព្រមទាំងការបញ្ជូនព័ត៌មានពីថ្នាក់លើទៅក្រោម និងពីថ្នាក់ក្រោមមកថ្នាក់លើនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។

[១៤:៥៧:៤១]

លោក លោកស្រីចៅក្រម! គោលការណ៍ និងលក្ខខណ្ឌតម្រូវនៃប្រជាធិបតេយ្យប្រមូលផ្តុំ និង

ភាពជាអ្នកដឹកនាំសមូហភាពហ្នឹងត្រូវបានសង្កត់ធ្ងន់នៅក្នុងទស្សនាវដ្ដីទង់បដិវត្តរបស់បក្ស។ ទស្សនាវដ្ដីទង់បដិវត្តចុះខែកញ្ញា តុលា ឆ្នាំ១៩៧៧ បានណែនាំថា៖ "ផែនការត្រូវបានតែស្នើឡើងជាសមូហភាពដោយគោរពទៅតាមប្រជាធិបតេយ្យប្រមូលផ្ដុំ"។ ហើយទស្សនាវដ្ដីបានរិះគន់លេខាបក្សតាមមូលដ្ឋានដែលមិនគោរពទៅតាមគោលការណ៍នេះ។ ហើយការរិះគន់មានដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ក្នុងការអនុវត្តកម្រិតនីមួយៗមិនធ្វើការប្រជុំជាសមូហភាព ដើម្បីធ្វើការពិភាក្សា និងសម្រេចនោះឡើយ ហើយមិនធ្វើការប្រជុំដែលទាញយកមកបទពិសោធន៍របស់អ្នកដទៃឡើយ គឺគេផ្ដោតទៅតែលើការអនុវត្តដាច់តែឯង ដែលសំដៅទៅលើមេដឹកនាំ។ ពេលខ្លះវាហាក់ដូចជាមានការប្រជុំប្រមូលផ្ដុំដែរ ប៉ុន្តែសមមិត្តលេខាមិនជំរុញឲ្យមានប្រជាធិបតេយ្យ ឬក៏លើកទឹកចិត្តឲ្យសមាជិកបក្សធ្វើការពិចារណាអំពីបញ្ហាដើម្បីបញ្ចេញមតិយោបល់ឡើយ។ ការប្រជុំ គឺគ្រាន់តែធ្វើការប្រជុំដើម្បីយល់ស្របជាមួយរបាយការណ៍របស់សមមិត្តលេខា ដែលមិនមានការពិភាក្សា ឬក៏មានការពិភាក្សាតិចតួចប៉ុណ្ណោះ គឺប្រជុំដើម្បីគ្រាន់ប្រជុំប៉ុណ្ណោះ។ បញ្ហានេះនាំទៅដល់ចំណុចខ្សោយរបស់ -- ទៅដល់ភាពទន់ខ្សោយនៃគុណភាពដឹកនាំរបស់បក្ស។ យើងទាំងអស់គ្នាត្រូវតែយកឈ្នះចំណុចខ្សោយទាំងអស់នេះ។ ជាគោលជំហររបស់យើង យើងត្រូវតែយល់ដឹងអំពីបញ្ហានេះថា មេដឹកនាំដែលមិនគោរពទៅតាមសមូហភាព ដែលមិនអនុវត្តទៅតាមសមូហភាព ដែលមិនឲ្យតម្លៃទៅលើសមូហភាព ហើយនិងមិនគោរពទៅតាមការងារ។ យើងត្រូវតែបង្កើតទម្លាប់មួយដែលថា យើងត្រូវគោរពសមូហភាព ហើយនិងជំហរនៃការគោរពទៅតាមការចាត់តាំង"។ សូមបញ្ចប់ការដកស្រង់។

[១៤:៥៩:៤១]

ដូច្នេះ លោក លោកស្រីចៅក្រមគឺវាបានបញ្ជាក់ច្បាស់ថា លក្ខខណ្ឌតម្រូវនៃការប្រជុំជាសមូហភាព និងការសម្រេចជាសមូហភាពមិនមែនជាគ្រាន់តែជាទម្រង់ការណ៍ ឬក៏ជាអ្វីដែលគ្រាន់តែធ្វើជារូបរាងនោះតែប៉ុណ្ណោះនោះឡើយ។ ទស្សនាវដ្ដីទង់បដិវត្តចេញខែវិច្ឆិកា ឆ្នាំ១៩៧៦ បានបញ្ជាក់ថា៖ "នៅពេលដែលមានមនុស្សតែម្នាក់ ឬក៏ពីរនាក់ ធ្វើការដឹកនាំ ឬក៏មានតែគណៈកម្មការមួយដឹកនាំ គេថាបញ្ហាទាំងអស់មិនអាចមើលឃើញឲ្យបានច្បាស់លាស់នោះឡើយ"។ សារាចរបស់បក្សកុម្មុយនីស្តកម្ពុជាដែលមានចំណងជើងថា "អ្វីជាមនោគមន៍វិជ្ជារបស់អង្គការ និងអ្វីជាវិន័យរបស់អង្គការនោះ បានរៀបរាប់នូវការពន្យល់អំពីអត្ថន័យនៃពាក្យថាប្រជាធិបតេយ្យប្រមូលផ្ដុំដូចតទៅនេះ"។ ខ្ញុំសូមដកស្រង់៖ "ក្នុងពេលប្រជុំសមូហភាព បក្ខជនទាំងអស់មានសិទ្ធិ និងមានសេរីភាពក្នុងការបញ្ចេញមតិយោបល់ ធ្វើការ

ពិភាក្សា រិះគន់ និងជំទាស់ ព្រមទាំងផ្តល់ជាមតិយោបល់ចំពោះមាគ៌ាបក្ស។ ចំពោះគោលនយោបាយ ចំពោះពាក្យស្លោក ហើយនិងគោលដៅ ឬក៏ចំពោះផែនការទាំងមូលរបស់ថ្នាក់ដឹកនាំបក្ស។ ហើយ សមាជិកបក្សមានសិទ្ធិអំណាចក្នុងការស្នើសុំឲ្យធ្វើការពិភាក្សាទៅលើអ្វីមួយប្រសិនបើគាត់មិនយល់ស្រប ជាមួយនឹងសេចក្តីសម្រេចជារួម"។

[១៥:០១:០៥]

លោក លោកស្រីចៅក្រម ភស្តុតាងនៅចំពោះមុខលោក លោកស្រីចៅក្រម បានបង្ហាញឲ្យហួស ពីវិមតិសង្ស័យថា នួន ជា ហើយនិង ខៀវ សំផន បានចូលរួមក្នុងនាមជាសមាជិកមជ្ឈិមបក្សនៅក្នុង ការសម្រេចជាសម្ងហភាពទៅលើគោលនយោបាយ និងផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា។ ភស្តុតាង រួមទាំងបញ្ចូលនៃចម្លើយជាច្រើនរបស់ ខៀវ សំផន ហើយនិងចម្លើយរបស់ នួន ជា ដែលពួកគាត់ ខ្លួន គាត់ផ្ទាល់បានបង្ហាញអំពីការគាំទ្រ ការលើកសរសើរ ព្រមទាំងការយល់ស្របជាមួយនឹងសេចក្តីសម្រេច របស់ ប៉ុល ពត និងរបស់បក្ស។ នៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រ កម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់"។ ខៀវ សំផន បានសរសើរពី ប៉ុល ពត គឺសរសើរ ទៅលើការវិភាគបញ្ហារបស់ ប៉ុល ពល ដែល ខៀវ សំផន បញ្ជាក់ថា៖ "ដំណោះស្រាយរបស់ ប៉ុល ពត ជាទូទៅ គឺតែងតែត្រឹមត្រូវ"។ ហើយគាត់បាននិយាយថា "ប៉ុល ពត គឺតំណាងឲ្យអ្នកដឹកនាំប្រវត្តិ សាស្ត្រ ដែលមិនដែលចេះខុស។ នៅពេលដែលគាត់ធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ"។ នៅក្នុងការដក ស្រង់មួយដែលខ្ញុំចង់ចាក់បង្ហាញនៅពេលនេះ គឺដកស្រង់ចេញពីខ្សែភាពយន្តដែលមានចំណងជើងថា "ប្រឈមមុខជាមួយនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍"។ ខៀវ សំផន បានពិពណ៌នាបន្ថែមទៀត អំពី ទំនាក់ទំនង ហើយនិងការគាំទ្ររបស់គាត់ចំពោះ ប៉ុល ពត។

[១៥:០២:៣៤]

*(ការបង្ហាញជាឯកសារសំឡេង-រូបភាព)*

*"ខ្ញុំតាមគាត់គ្រប់ពេល ដូចស្រមោលអន្ទោលតាមប្រាណ។ សួរ៖ តើគាត់បាននិយាយអ្វីខ្លះ នៅ ក្នុងកិច្ចប្រជុំទាំងនោះ? ឆ្លើយ៖ គាត់និយាយអំពីសភាពការណ៍នយោបាយបច្ចុប្បន្ន បន្ទាប់មកនិយាយអំពី សតិអារម្មណ៍ស្នេហាជាតិ ផ្សាភ្ជាប់នឹងសតិអារម្មណ៍វណ្ណៈរបស់បក្ស។ និយាយអំពីពលិកម្ម និង វីរភាព។ គាត់សូមឲ្យកម្មាភិបាលទាំងអស់ធ្វើ គិត និងរស់នៅដូចកសិករដែរ។ ចំពោះខ្ញុំផ្ទាល់ ខ្ញុំបាន ប្រឹងប្រែង ប៉ុន្តែខ្ញុំមិនអាចធ្វើបានទេ។ បន្ទាប់មកគឺមាននិយាយអំពីបញ្ហាទំនាស់លទ្ធិម៉ាក្សនិយម។ អ្វីៗ*

*សុទ្ធតែទាក់ទងគ្នា អ្វីៗផ្លាស់ប្តូរ។ បក្សជាអ្វីៗទាំងអស់។ តើឥឡូវនេះ អ្នកគិតអ៊ីចឹងហើយឬនៅ? ពីព្រោះថា ជាគោលការណ៍ អ្នកមិនត្រូវមានប្រតិកម្មទេ។ ពេលមានហេតុការណ៍ណាមួយកើតឡើងនោះ។ អ្នកមិនអាចមានអារម្មណ៍រីករាយ ឬមានអារម្មណ៍សោកស្តាយនោះទេ។ ត្រូវព្យាយាមវិភាគហេតុការណ៍ដោយត្រជាក់ចិត្ត រកឲ្យឃើញចំណុចវិជ្ជមាន និងអវិជ្ជមានម្រាប់ចលនា ហើយព្យាយាមចាត់វិធានការ។ ខ្ញុំឃើញគាត់ជានិច្ចនៅទីនេះ ឬនៅផ្លូវភ្នំក្រវាញ។ ខ្ញុំចងចាំរូបភាពគាត់ក្នុងចិត្តខ្ញុំជានិច្ច។ សួរ៖ តើលោកនឹក ប៉ុល ពត ទេ? ឆ្លើយ៖ បាទ ពីព្រោះចំពោះយើងគាត់គឺជាមនុស្សពូកែគិតដឹកម្រេកបាន។"*

[១៥:០៥:៣០]

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ចម្លើយបន្ទាប់របស់ ខៀវ សំផន គឺបានបង្ហាញអំពីការគាំទ្រយ៉ាងខ្លាំងក្លារបស់គាត់ចំពោះការដឹកនាំរបស់ ប៉ុល ពត។

*"ការបង្ហាញកម្ពុជាបង្ហាញ ប៉ុល ពត ថាជាបិសាចដើម្បីបំភ្លេចស-២១ ដែលកម្ពុជាក្រោមចោទ ប៉ុល ពត ថាជាជនផ្តាច់ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ មិនត្រឹមត្រូវទេ មេដឹកនាំចលនាដ៏ធំមិនអាចធ្វើបែបនេះបានទេ បើគាត់ធ្វើអ៊ីចឹងមែននោះក៏មិនអាចបង្កើតចលនាបែបនេះបានទេ។ ខ្ញុំនឹងស្រែកបែបនេះនៅចំពោះមុខតុលាការ"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:០៦:៤៦]

លោក លោកស្រីចៅក្រម ប៉ុន្តែរហូតមកដល់ពេលនេះយើងមិនដែលឃើញ ខៀវ សំផន គាត់ស្រែកដូចដែលអ្វីដែលគាត់បានបញ្ជាក់នោះទេ។ ប៉ុន្តែយើងនៅតែចាំមើលថាតើ ខៀវ សំផន អាចនឹងងើបមកឈរហើយស្រែកនៅក្នុងសវនាការនេះបានដែរឬទេ ដើម្បីបង្ហាញពីរូបរាងពិតរបស់គាត់គឺជាបុរសម្នាក់ដែលគាំទ្រ និងយល់ស្របព្រមទាំងឈរនៅក្បែរប៉ុលពត ជារៀងរាល់ពេលជិតរយៈពេល ២៨ ឆ្នាំ។ ទោះបីជារូបរាងពិត របស់ខៀវ សំផន ដែលលាក់ក្នុងស្រោមដែលបិទបាំងភាពអាក្រក់របស់គាត់ក៏ដោយ ប៉ុន្តែយើងធ្លាប់ឃើញរូបរាងពិតរបស់ នួន ជា គឺបង្ហាញអំពីចេតនាបដិវត្តន៍ដែលគាត់សុខចិត្តលះបង់គ្រប់យ៉ាង គ្រប់អ្វីៗទាំងអស់ក្នុងឈ្មោះជាអង្គការ។ នៅពេលដែលគាត់ធ្វើការសម្ភាសជាមួយ ថេត សម្បត្តិ, នួន ជា និយាយដោយបើកចំហអំពីទំនាក់ទំនងរវាងគាត់ជាមួយនឹង ប៉ុល ពត។ នៅក្នុង

ឃ្លីបវីដេអូបន្តទៅទៀតនេះ នួន ជា បាននិយាយអំពីការដែល ប៉ុល ពត ក្លាយជាលេខាបក្ស ប៉ុន្តែពួកគេឯកភាពគ្នាថាធ្វើការជាក្រុម ហើយតែងតែពិភាក្សាអំពីបញ្ហាសំខាន់ៗជាមួយគ្នា។

[១៥:០៧:៥៩]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"សូមជម្រាបការពិតយ៉ាងនេះ។ ការដែលប៉ុលពត ឈរលេខាបក្សពេលនោះគឺអ៊ីចេះ ខ្ញុំទេ ដែលត្រូវធ្វើលេខាបក្សពីព្រោះអត់ពីតាទូទៅ។ តាទូគាត់ជាលេខា ហើយខ្ញុំក៏អនុតាទូ ពីព្រោះខ្ញុំសង្កេតឃើញអ៊ីចេះ ប៉ុល ពត គាត់មានលក្ខណៈឯករាជ្យ ហើយគាត់មានសមត្ថភាពក្នុងការវិភាគ ក្នុងការអីៗ ហើយពេលនោះយើងនៅត្រូវការបញ្ញាជនមួយចំនួនដើម្បីទៅចូលរួមក្នុងការតស៊ូ ដូច្នោះបានជាខ្ញុំយល់ឃើញថា ខ្ញុំមិនមែនជា -- ខ្លះគេថាខ្ញុំបញ្ញាជន ប៉ុន្តែមិនមែនទេ ខ្ញុំបញ្ញាជនថ្នាក់ក្រោម។ ដល់អ៊ីចឹងបានខ្ញុំ គិតអ៊ីចឹងបានជាខ្ញុំទៅប្រាប់ ប៉ុល ពត ថាក្នុងសភាពការណ៍បច្ចុប្បន្ននេះ ខ្ញុំទទួលនាទីជាលេខាមិនសមរម្យទេ មិនបានចម្រើនដល់បក្សទេ ស្នើសមមិត្តទទួលយកភារកិច្ចនេះទៅ ឲ្យ ប៉ុល ពត ទទួលយកភារកិច្ចជាលេខាទៅ។ គាត់គិតមួយសន្ទុះ គាត់គិតវិភាគអីមើល បានថា មានអី បើថាអ៊ីចឹងយល់ព្រម ប៉ុន្តែយើងរួមគ្នាធ្វើការងារទាំងអស់គ្នា។ អានេះបញ្ហាមានប៉ុណ្ណឹង។ ដូច្នេះ គាត់ធ្វើលេខាបក្សតាំងពីហ្នឹងមក។ ដូច្នោះគ្មានបញ្ហាអីទេ។ ឯម្យ៉ាងទៀត មួយទៀតដែលខ្ញុំភ្លេច--"។*

លោកប្រធាន ឃ្លីបវីដេអូបន្តទៅទៀតនេះពណ៌នាអំពីទំនាក់ទំនងការងារដ៏ជិតស្និទ្ធដែល នួន ជា គាត់មានជាមួយប៉ុលពត។ ហើយចំពោះការលើកឡើងរបស់ នួន ជា ដែលថា គាត់មិនមែនជាបញ្ញាជនគ្រប់គ្រាន់សម្រាប់ក្លាយជាលេខាបក្សនេះ យើងនឹងពិភាក្សានៅពេលក្រោយបន្តិចទៀតនេះ។

[១៥:១០:០៦]

*[ស៖ គាត់កាន់ឆ្នាំ៦០។ ផ៖ បាទ។ ស៖ ប៉ុល ពត ធ្វើអ្វីត្រូវពិភាក្សាជាមួយអ៊ំដែរនោះ? អ៊ីចឹងបានន័យថា គាត់នៅគោរពពាក្យសន្យាគាត់ទេ? ផ៖ ទេ គាត់នៅ -- ការធម្មតា ការអី ចុះវាមានអ៊ីចេះជួនមិនហៅ ជួនណាមិនមែនប្រជុំទេ គេហៅថា ជួបគ្នាផ្លាស់ប្តូរមតិគ្នា។ អានេះមិនមែនជារូបភាពប្រជុំទេ។ បើប្រជុំផ្សេង វាទៅអង្គុយអីស្រួលបួល។ អានេះវាអត់ជួបគ្នា "មក! មិត្តខ្ញុំមានបញ្ហាមួយចង់ពិភាក្សា មក"។ អានេះ គេហៅថា ពិគ្រោះពិភាក្សាៗគ្នា។ សួរមតិគ្នាខាងក្រៅប្រជុំ ដូច្នោះនោះ មានអ៊ីចឹងវារហ័ស។ ទាក់ទងអ៊ីចឹងណ៎ា មានការអីទាក់ទងគ្នាភ្លាម។ ដូចខ្ញុំថា "មិនបាច់ប្រជុំក៏បានដែរ មក! គេហៅថា ផ្លាស់ប្តូរមតិគ្នា!"។ ពាក្យប្រើកាលណោះ "ផ្លាស់ប្តូរមតិគ្នា"។ អានេះត្រូវធ្វើញឹកញាប់ដែរ*

*ពីព្រោះមានការអីមិនចេះតែហៅប្រជុំទេ ពីព្រោះវាគ្មានពេលប្រជុំផង។ បន្តិចរឿងនេះ បន្តិចរឿងនោះ ដូច្នេះមានរឿងអីផ្លាស់ប្តូរគ្នា។ អាហ្នឹងវាអ៊ីចឹង។ ហើយជាពិសេសដោះស្រាយរឿងជីវភាពប្រជាជន រឿងអីៗនេះ។ អូ! ស្មុគស្មាញណាស់ក្មួយអើយ!។"]*

[១៥:១១:៣០]

លោក លោកស្រីចៅក្រម ខ្សែវីដេអូបន្ត គឺថាគេសួរ នួន ជា ថាតើគាត់ធ្លាប់មានការខ្វែងយោបល់គ្នាជាមួយនឹង ប៉ុល ពត ដែរឬក៏អត់?

*"ស៖ អ៊ំ និង ប៉ុល ពត ធ្លាប់មានការពិភាក្សាណាមួយដ៏តឹងរ៉ឹងនឹងគេទេបាទ ពេលគ្រប់គ្រងអំណាចក្រោយ ៧៥-៧៩ បាទ? ឆ៖ ដូចគ្មានទេ។ គ្មានទេ។ មិនមានទេ ៧៥-៧៩។ មិនមានបញ្ហាអីនឹងគ្នាទេ មិនទេ"។ (បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៥:១២:៣១]

លោកប្រធាន នៅក្នុងការសម្ភាសមួយដែល នួន ជា គាត់ផ្តល់នៅក្នុងខែតុលា ឆ្នាំ២០០៦ នួន ជា បានបញ្ជាក់ច្បាស់ថា សេចក្តីសម្រេចរបស់បក្សត្រូវធ្វើជាសមូហភាព យោងទៅតាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ហើយខ្ញុំសូមធ្វើការដកស្រង់៖ "សំណួរ៖ តើ ប៉ុល ពត គាត់មានសមត្ថភាពគ្រប់គ្រាន់ដើម្បីគ្រប់គ្រងទៅលើចលនាទាំងមូលដែរឬក៏អត់នោះ? នួនជា បានឆ្លើយថា៖ ចំពោះបញ្ហានេះ គឺមិនមែនគាត់ធ្វើដោយខ្លួនគាត់នោះទេ គឺថាយើងទាំងអស់គ្នាធ្វើការជាមួយគ្នា។ គាត់ចូលរួមតាមចំណែករបស់គាត់។ យើងធ្វើការចូលរួមតាមចំណែករបស់យើង។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើនួន ជា -- តើ ប៉ុល ពត មានការផ្តាច់មុខទៅលើសិទ្ធិអំណាចដែរឬទេ? នួន ជា ឆ្លើយថា៖ ទេ គឺថាយើងផ្តោតទៅលើប្រជាធិបតេយ្យប្រមូលផ្តុំ"។

លោក លោកស្រីចៅក្រម! ប្រធានបទបន្តដែលខ្ញុំចង់ពិភាក្សា គឺវាស្ថិតនៅក្នុងចំណុចស្នូលនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ គឺទាក់ទងទៅនឹងរចនាសម្ព័ន្ធរាយការណ៍ និងរចនាសម្ព័ន្ធអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ។ ភស្តុតាងបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនេះ គឺបង្ហាញហួសពីវិមតិសង្ស័យថា តាំងពីមុនថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ រហូតដល់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលតែម្តង មេដឹកនាំមជ្ឈិមបក្សទទួលនូវរបាយការណ៍ជាទៀងទាត់ និងជាលម្អិតពីភូមិភាគ យោធា និងអង្គភាពដទៃទៀត។ ទោះបីថា ខ្មែរក្រហមបំផ្លាញនូវឯកសារជាច្រើនមុនពេលដែលពួកគេរត់ចូលទៅព្រៃនៅក្នុងខែមករា ឆ្នាំ៧៩ក៏ដោយ គឺមានរបាយការណ៍និងសារទូរលេខ

មួយចំនួនធំដែលនៅសល់រហូតមកដល់ពេលនេះ ហើយតាមរយៈនេះបានបង្ហាញនូវទិដ្ឋភាពច្បាស់លាស់។ ទី១) គឺលក្ខណៈនៃព័ត៌មានដែលមេដឹកនាំបក្សបានទទួលពីមូលដ្ឋាន។ ទី២) គឺការគ្រប់គ្រង និងសិទ្ធិអំណាចរបស់មជ្ឈិមបក្សទៅលើអង្គការតាមភូមិភាគ និងយោធា ហើយទី៣) គឺផែនការឧក្រិដ្ឋកម្ម ហើយនិងគោលនយោបាយរបស់មជ្ឈិមបក្សដែលត្រូវបានអនុវត្តជាប្រព័ន្ធដោយអង្គការទាំងអស់នោះ។

[១៥:១៤:៤០]

និយាយដោយសាមញ្ញ ការអះអាងរបស់ជនជាប់ចោទដែលថា ពួកគេមិនដឹងអំពីការចាប់ខ្លួន ការសម្លាប់ ការខ្វះម្ហូបអាហារ ឬក៏បញ្ហាជំងឺ ឬក៏ការអត់ឃ្លាននៅក្នុងប្រទេសកម្ពុជា ឬក៏ថា ភូមិភាគធ្វើការអនុម័តដោយស្វ័យភាព ដោយមិនមានការណែនាំពីមជ្ឈិមបក្សនោះ គឺថាត្រូវបានបង្ហាញដោយឯកសារទាំងអស់នេះថាជាការកុហកយ៉ាងងងើល។ នៅក្នុងការជំនុំជម្រះនេះ តុលាការបានស្តាប់ឮសក្ខីកម្មយ៉ាងច្រើនពីកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលទទួលខុសត្រូវចំពោះការរាយការណ៍ និងការបញ្ជូនព័ត៌មាន។ គឺការបញ្ជូន និងការបកស្រាយសារទូរលេខ ការផ្សាយសារទូរលេខ ហើយនិងរបាយការណ៍ ព្រមទាំងសារនានាទៅមេដឹកនាំបក្ស និងមកពីមេដឹកនាំបក្សទាំងមុន និងបន្ទាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ ភស្តុតាងបានបង្ហាញថាមានប្រព័ន្ធរៀបចំគ្រប់គ្រាន់នៃការរាយការណ៍ដែលចាប់ផ្តើមតាំងពីដើមទស្សវត្សរ៍១៩៧០ នៅពេលដែលមេដឹកនាំបក្សមានមូលដ្ឋាននៅស្នាក់ការស-៧១ នៅស្ទឹងជីនិត។ សាក្សីមួយរូបគឺ នង សុផង់ ដែលធ្វើការងារនៅក្នុងអង្គភាពសារទូរលេខនៅស្នាក់ការបក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ១៩៧៣។ គាត់បានផ្តល់សក្ខីកម្មថា "ភូមិភាគតំបន់ និងមូលដ្ឋានព្រមទាំងអង្គភាពកងពលនីមួយៗគឺតម្រូវឲ្យមានផ្នែកទំនាក់ទំនង និងផ្នែកសារទូរលេខ។ គាត់រៀបរាប់អំពីទូរលេខដែលទទួលបានមកពីមូលដ្ឋាន និងសមរភូមិមុខដែលរួមបញ្ចូលរបាយការណ៍អំពីស្ថានភាពនៅសមរភូមិ ហើយនិងសារទូរលេខដែលត្រូវបញ្ជូនចេញដែលជាការណែនាំពីអាជ្ញាធរថ្នាក់លើទៅលើអាជ្ញាធរថ្នាក់ទាប ដើម្បីអនុវត្តដោយរួមទាំងវិធានការ ការណែនាំ ឬក៏សារាចរសម្រាប់អនុវត្តនៅថ្នាក់មូលដ្ឋាន។ លោក នង សុផង់ បានបញ្ជាក់យ៉ាងច្បាស់ថានៅក្នុងរយៈពេលមុនខែមេសា ១៩៧៥ សារទូរលេខរួមមាន ការណែនាំឲ្យវាយប្រហារគោលដៅជាក់លាក់មួយចំនួន ហើយនិងសំណើរពីមូលដ្ឋានសុំគ្រឿងសព្វាវុធដើម្បីឲ្យការវាយប្រយុទ្ធហ្នឹងប្រព្រឹត្តទៅដោយប្រសិទ្ធភាព។ លោក គីម វុន ដែលធ្វើការនៅស្នាក់ការបក្សនៅស្ទឹងជីនិត នៅក្នុងរយៈពេលមុនឆ្នាំ១៩៧៥ បានបញ្ជាក់ផងដែរថាមេដឹកនាំបក្សទទួលសារទូរលេខដែលរាយការណ៍អំពីស្ថានភាពជាក់ស្តែងនៅតាមសមរភូមិនីមួយៗ ដោយរួម

បញ្ចូលទាំងសមរភូមិនៅជុំវិញទីក្រុងភ្នំពេញ។

[១៥:១៧:៣៤]

លោក លោកស្រីចៅក្រម ពាក់ព័ន្ធទៅនឹងការបញ្ជូនសារទូរលេខនៅក្នុងរយៈពេលមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោក នង សុផង់ បានផ្ដល់សក្ខីកម្មថាពេលខ្លះគាត់ត្រូវធ្វើការទាំងយប់ ទាំងថ្ងៃដើម្បី បញ្ជូនសារទូរលេខទាំងអស់នោះចេញ ហើយគាត់បានពន្យល់បន្ថែមទៀតថា ពាក់ព័ន្ធចំពោះបញ្ហាសារ ទូរលេខ ការបញ្ជូនសារទូរលេខហ្នឹង គឺផ្អែកទៅលើស្ថានភាពជាក់ស្ដែងរបស់ភូមិភាគនីមួយៗ។ ជា ឧទាហរណ៍ ប្រសិនបើមានការវាយប្រយុទ្ធខ្លាំងក្លា នៅពេលហ្នឹងគឺថាសារទូរលេខត្រូវបានគេបញ្ជូនទៅ វិញទៅមក ២៤ម៉ោង លើ ២៤ម៉ោង។ ប៉ុន្តែចំពោះតំបន់ដែលត្រូវបានគេរំដោះរួចទៅហើយនោះ ពេល នោះគឺការបញ្ជូនសារទូរលេខ គឺហាក់ដូចជាមិនសូវជាញឹកញាប់ប៉ុន្មានទេ។ ឧទាហរណ៍ខាងភូមិភាគ បូព៌ា គេត្រូវតែធ្វើការបញ្ជូនញឹកញាប់ច្រើនជាងគេ ពេលខ្លះវាត្រូវធ្វើការ២៤ម៉ោង លើ ២៤ម៉ោង។

សក្ខីកម្មរបស់សាក្សីទាំងអស់នេះបានបញ្ជាថារចនាសម្ព័ន្ធនៃការវាយការណ៍គឺមានរួចទៅហើយ តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៧០។ ហើយគាត់ត្រូវបានបញ្ជាក់បន្ថែមនៅក្នុងទស្សនាវដ្ដីទង់បដិវត្តន៍ចេញ ខែកញ្ញា តុលា (១៩)៧២ ដែលបក្សបានផ្ដល់ការណែនាំដើម្បីលើកកម្ពស់គុណភាពនៃការវាយការណ៍ពី មូលដ្ឋានរហូតមកដល់ថ្នាក់លើ។ ទស្សនាវដ្ដីនេះបានបញ្ជាក់ថា គោលការណ៍ការងារចាំបាច់គឺត្រូវវាយ ការណ៍ជាមូលដ្ឋានជាទៀងទាត់ ហើយច្បាស់លាស់។ ហើយថារបាយការណ៍មកពីខាងមូលដ្ឋានមិនត្រូវ វាយការណ៍ត្រឹមតែសកម្មភាពយោធានោះឡើយ។ គឺថាទស្សនាវដ្ដីនេះបានបញ្ជាក់អំពីប្រធានបទប្អូន ដែលត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍។ ទី១) គឺខ្មាំង ទី២) គឺប្រជាជន ទី៣) ពីសកម្មភាពការងារ គ្រប់ផ្នែក និងទី៤) ពីទិស និងវិធានការដោះស្រាយ។ ទាំងអស់នេះហើយគឺជាបទដ្ឋានដែលត្រូវបាន អនុវត្ត ហើយយើងឃើញនៅក្នុងរបាយការណ៍ជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលចាប់ផ្ដើម ជាដំបូង គឺនិយាយអំពីខ្មាំង។ បន្ទាប់មកទៀតគឺអំពីប្រជាជន ហើយនិងស្ថានភាពការងាររបស់ប្រជាជន ព្រមទាំងការផលិតស្រូវ ក៏ដូចជាការកសាងទំនប់។

[១៥:២០:០២]

លោក លោកស្រីចៅក្រម ទស្សនាវដ្ដីទង់បដិវត្ត ឆ្នាំ១៩៧២ គឺមានដូចតទៅនេះ៖ “វាយការណ៍ មានពីរសណ្ឋាន គឺវាយការណ៍សាមញ្ញ និងវាយការណ៍ពិសេស ដើម្បីឲ្យខ្លួនឯងនិងថ្នាក់លើក្ដាប់ សភាពការណ៍បានច្បាស់លាស់ ហើយណែនាំជាក់ស្ដែង។ យើងត្រូវវាយការណ៍ឲ្យច្បាស់ ដោយលើក

ឧទាហរណ៍ខ្លីច្បាស់មកបញ្ជាក់។ ត្រូវចៀសវាងរាយការណ៍រួមៗ ដោយឃ្លាប្រយោគបែបអក្សរសាស្ត្រ នាំឲ្យវែង។ ត្រូវមានខ្សែសង្វាក់ មិនមែនជាការរាយកាណ៍ពីនេះមួយចុប មួយនោះមួយចុប ហើយរាយការណ៍ច្បាស់លាស់ និងទៀងទាត់ឲ្យថ្នាក់លើក្តាប់សភាពការណ៍បាន និងម្ចាស់ការបាន ហើយជួយណែនាំវិញច្បាស់លាស់និងទាន់ពេលវេលា។ យើងត្រូវបំពាក់ទាំងបក្ស និងក្រៅបក្ស អំពីរបបរបាយ-ការណ៍នេះ ដែលជាមាគ៌ាដំណើរការរបស់យើង។ គ្មានការរាយការណ៍ ដឹកនាំ និងធ្វើការងារមិនបានទេ"។ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មពី ភី ភួន និងនីរសារដែទៀតដែលបានបញ្ជូនសារ និងលិខិតពីមេដឹកនាំបក្សដែលមានមូលដ្ឋាននៅស្ទឹងជីនិត រហូតទៅបញ្ជូនទៅតាមភូមិភាគនានានៅក្នុងអំឡុងពេលមុនឆ្នាំ១៩៧៥។ លោក ភី ភួន ធ្លាប់រួមអមដំណើរ ប៉ុល ពត ហើយនិង នួន ជា ធ្វើដំណើរទៅតាមមុខភូមិភាគនានា ដែលនៅទីនោះគឺពួកគេបានជួបជាមួយគណៈភូមិភាគ ធ្វើការសិក្សាអប់រំ ហើយនិងផ្តល់ការណែនាំលម្អិត ពាក់ព័ន្ធទៅនឹងស្ថានភាពជាក់ស្តែងនៅក្នុងភូមិភាគ ឬក៏តំបន់ជាក់លាក់ ឬក៏ស្រុកជាក់លាក់នោះ ហើយនិងផ្តល់អំពីវិធានការដែលត្រូវធ្វើ។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក៏ប្រើប្រាស់សារាចរជាលាយលក្ខណ៍អក្សរ ក្នុងពេលនោះ ដើម្បីបញ្ជូនមាគ៌បក្ស ហើយនិងគោលនយោបាយទៅដល់ថ្នាក់ខាងក្រោម។ ទស្សនាវដ្តីទង់បដិវត្តខែកញ្ញា ឆ្នាំ១៩៧២ បានណែនាំដល់ភូមិភាគ តំបន់ និងគណៈស្រុកអំពីការអនុវត្តសារាចរនៅក្នុងភូមិភាគរបស់ពួកគេ ដើម្បីឲ្យមានការគោរពជារួមនៅទូទាំងប្រទេសទៅលើមាគ៌ាបក្ស។

[១៥:២២:២៥]

លោក លោកស្រីចៅក្រម ភស្តុតាងទាំងអស់នេះបានបង្ហាញថា ការរាយការណ៍ជាមូលដ្ឋាន ការទំនាក់ទំនង និងរចនាសម្ព័ន្ធអង្គការត្រូវបានបង្កើតតាំងពីមុនខែមេសា ឆ្នាំ១៩៧៥ មកម្ល៉េះ។ វាបង្ហាញថាមេដឹកនាំមជ្ឈិមបក្សបានទទួលរបាយការណ៍២៤ម៉ោងលើ២៤ម៉ោងក្នុងមួយថ្ងៃ អំពីស្ថានភាពនៅតាមសមរភូមិនៅពេលដែលទាហានបក្សកុម្មុយនីស្តកម្ពុជាធ្វើការវាយប្រយុទ្ធ ហើយនិងចូលកាន់កាប់ទីក្រុងភ្នំពេញ។ ហើយសំខាន់បំផុត គឺវាបានបង្ហាញថា មជ្ឈិមបក្សធ្វើការគ្រប់គ្រងដែលប្រសិទ្ធភាពទៅលើកងពលយោធានៅតាមមុខភូមិភាគ ហើយពួកគេមានសិទ្ធិអំណាចអនុវត្តមាគ៌បក្ស និងការសម្រេចគោលនយោបាយនៅក្នុងអង្គការតាមភូមិភាគនានា។

រចនាសម្ព័ន្ធរាយការណ៍ និងសិទ្ធិអំណាចនៅតែបន្តបន្ទាប់ពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានឡើងកាន់អំណាចនៅថ្ងៃទី១៧ មេសា ១៩៧៥។ លក្ខន្តិកៈបក្សតម្រូវឲ្យសាខាទាំងអស់ គណៈកម្មការ

គណៈស្រុក និងគណៈតំបន់ រក្សានូវប្រព័ន្ធនៃការរាយការណ៍ទៅថ្នាក់អំពីស្ថានភាព និងការងារ ហើយតម្រូវឲ្យគណៈភូមិភាគរាយការណ៍ទៅគណៈមជ្ឈិមអំពីស្ថានភាព និងការងាររបស់ភូមិភាគ។

[១៥:២៣:៥៥]

សេចក្ដីសម្រេចថ្ងៃ៣០ មីនា ១៩៧៦ របស់គណៈអចិន្ត្រៃយ៍ ហើយនិងដែលជាសំដៅទៅលើរបបនៃការរាយការណ៍ប្រចាំសប្ដាហ៍ទៅមន្ទីរ៨៧០។ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរាយការណ៍ ឬក៏ប្រព័ន្ធដែលត្រូវបានអនុវត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះបានស្ដាប់សក្ខីកម្មលម្អិតរបស់ នង សុផង់ ទាក់ទងទៅនឹងមន្ទីរសារទូរលេខក-១៨ នៅក្នុងទីក្រុងភ្នំពេញ។ សក្ខីកម្មរបស់ សួន កាណិល ទាក់ទងទៅនឹងមន្ទីរទូរលេខភូមិភាគមជ្ឈិម ហើយនិងសក្ខីកម្មរបស់ ផាន់ វ៉ាន ហៅ ខាំ ផាន់ ពាក់ព័ន្ធនឹងការទទួល និងការបញ្ជូនទូរលេខដោយមន្ទីរតំបន់១០៥នៅមណ្ឌលគិរី។ សាក្សីទាំងអស់នេះបានបញ្ជាក់យថាភាពនៃទូរលេខ ហើយនិងរបាយការណ៍ដែលត្រូវបានទទួលយកដោយអង្គជំនុំជម្រះនេះ។ ហើយសមាជ -- ហើយកម្មាភិបាលភូមិភាគ និងតំបន់ដទៃទៀតក៏អាចបញ្ជាក់អំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបានពិភាក្សានៅក្នុងទូរលេខ និងរបាយការណ៍ដែលបញ្ជូនទៅមជ្ឈិមបក្ស។

អង្គជំនុំជម្រះក៏បានស្ដាប់ឮសក្ខីកម្មរបស់សាក្សីជាច្រើន ដែលជាអ្នករៀបចំសារទូរលេខទាំងអស់នេះ រួមបញ្ចូលទាំងលេខាភូមិភាគ១០៥ សៅ សារុន និងអនុលេខា កងពល៨០១ គឺ អ៊ុង វ៉ែន។ នង សុផង់ និងកម្មាភិបាលដទៃទៀតដែលធ្វើការនៅមន្ទីរ-ក នៅទីក្រុងភ្នំពេញ ក៏បានផ្ដល់សក្ខីកម្មអំពីនីតិវិធីដែលសារទូរលេខ និងរបាយការណ៍នោះត្រូវបានគេបញ្ជូលទៅមេដឹកនាំបក្ស។ ជាទូទៅ សារទូរលេខមួយច្បាប់ត្រូវបានរៀបចំសម្រាប់សមាជិកទាំងអស់របស់គណៈអចិន្ត្រៃយ៍ ហើយនិងរបស់មន្ទីរ៨៧០។ អឿន តាន ដែលបំពេញការងារសន្តិសុខនៅក-១ បានផ្ដល់សក្ខីកម្មនៅក្នុងអង្គជំនុំជម្រះនេះទេ "ហោចណាស់ ក៏មានពីរទៅបីដងក្នុងមួយថ្ងៃ ដែលគាត់បានទទួល និងបញ្ជូនសំបុត្រឯកសារទៅ ប៉ុល ពត។ ហើយបន្ទាប់មកទៀត គាត់បញ្ជូនឯកសារបន្តទៅ នួន ជា បន្ទាប់ពី ប៉ុល ពត បានអានឯកសារទាំងអស់នេះ"។

[១៥:២៦:១៥]

លោក លោកស្រីចៅក្រម ក៏បានដឹងសារទូរលេខជាច្រើនដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលមានចម្លងជូនដែលនៅលើលិខិតនោះថា "អ៊ំនួន" ជាអ្នកទទួលឯកសារ។ នេះជាឧទាហរណ៍មួយនៃបញ្ជីទទួលឯកសារ ដែលយើងទទួលបាននៅក្នុងសារទូរលេខជាច្រើនរបស់កម្ពុជាប្រជា

ធិបតេយ្យ។ ដូចដែលលោក លោកស្រីចៅក្រមបានឃើញហើយ នៅក្នុងបញ្ជីចែកជូននេះ គឺថាសារទូរលេខមួយ គឺបានចែកដាក់ថា "មន្ទីរ, បងនួន, បងខៀវ, បងវ៉ាន់, សុន សេន និងអៀង សារី"។ នងសុផង់ បានបញ្ជាក់ថា ដែលបញ្ជាក់ថា មន្ទីរ គឺបងឌឿន ជាអ្នកទទួល ហើយរក្សាទុកនៅមន្ទីរ៨៧០។ រីឯច្បាប់ដែលបញ្ជាក់ថា "ឯកសារ ឬក៏ទុកជាឯកសារ" រក្សាទុកនៅមន្ទីរទូរលេខក-១៨។ ភស្តុតាងចំពោះមុខតុលាការបានបញ្ជាក់ថា ខៀវ សំផន បានទទួល ឬក៏អាចទទួលបានសារទូរលេខ ឬរបាយការណ៍ដែលរក្សាទុកនៅមន្ទីរ៨៧០។ លោក ខៀវ សំផន បានទទួលស្គាល់ថា នៅក្នុងបទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតនៅតុលាការនេះថា "គាត់ និង ឌឿន គឺជាសមាជិកតែពីររូបនៃមន្ទីរគណៈ៨៧០" ដែលគេហៅថា ការិយាល័យនយោបាយ៨៧០។ ហើយនៅពេលដែលគេចាប់ខ្លួន ឌឿន បាត់ខ្លួន នៅក្នុងឆ្នាំ១៩៧៧។ នៅក្នុងបទសម្ភាសន៍ឆ្នាំ២០០៥ ខៀវ សំផន បានទទួលស្គាល់ថា មុខងារមួយរបស់ ឌឿន នៅក្នុងមន្ទីរ៨៧០ គឺទទួលរបាយការណ៍ពីភូមិភាគដែលបញ្ជូនទៅ៨៧០។

[១៥:២៨:០៧]

មានសេចក្តីសន្និដ្ឋានតែមួយគត់អំពីអង្គហេតុនេះ នោះគឺថា លោក ខៀវ សំផន មានលទ្ធភាពទទួលទូរលេខ ហើយនិងរបាយការណ៍ដែលបញ្ជូនមកមន្ទីរ៨៧០ នៅពេលដែលគាត់នៅទីនោះ ហើយនិង ឌឿន ជាសមាជិកតែពីរនាក់នៃគណៈ៨៧០។ ហើយលោក ខៀវ សំផន នេះឯង ដែលបានទទួលការខុសត្រូវបន្តក្នុងការរក្សា ហើយនិងការថែទាំមន្ទីរឯកសារ៨៧០ បន្ទាប់ពីគេចាប់ខ្លួន ឌឿន នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧។ សេចក្តីសន្និដ្ឋាននេះ គឺគាំទ្រដោយសក្ខីកម្មរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលគាត់បានបញ្ជាក់ថា៖ "ឯកសារទាំងអស់ គឺស្ថិតនៅក្នុងដៃរបស់ ខៀវ សំផន"។ សូមចប់សេចក្តីដកស្រង់។ ហើយក៏បានបញ្ជាក់ផងដែរ ដោយភស្តុតាងដល់សំខាន់មួយ គឺសក្ខីកម្មដែលបញ្ជាក់ដោយ ភី ភួន ក្នុងសវនាការ។ ដូច ឌុច, សាឡុត បាន, ដេវីដ ឆេនដ័ល័រ, ហ្វីលីព ស្សត។ ភី ភួន បានបញ្ជាក់ថា "លោក ខៀវ សំផន គឺជាអ្នកមកជំនួស ឌឿន ជាប្រធានមន្ទីរ៨៧០"។ សក្ខីកម្មរបស់ ភី ភួន គឺផ្អែកទៅលើការងារប្រចាំថ្ងៃរបស់គាត់ ក្នុងឋានៈជាប្រធានរដ្ឋបាលនៃក្រសួងការបរទេស។ ម្តងម្កាលមេរបស់ ភី ភួន, អៀង សារី ត្រូវជួប ត្រូវបញ្ជូនសំបុត្រ ឬក៏លិខិតផ្សេងៗទៅខេត្តនានា។ លិខិតណែនាំផ្សេងៗពីភ្នំពេញទៅភូមិភាគ ហើយក៏លិខិតណែនាំ ឬសំបុត្រទាំងឡាយពីភូមិមកភ្នំពេញ ក៏បានឆ្លងកាត់មន្ទីរ៨៧០ទាំងអស់។ ក្រោយពីការចាប់ខ្លួន ហើយការបាត់ខ្លួន ឌឿន, ភី ភួន បានណែនាំពី អៀង សារី ថា ឌឿន ត្រូវ បានជំនួសដោយ ខៀវ សំផន ហើយចាប់ពីពេលនេះតទៅ ភីភួន ត្រូវតែទាក់ទងជាមួយលោក

ខៀវ សំផន នៅពេលដែលក្រសួងការបរទេស មានសំបុត្រអ្វីត្រូវបញ្ជូនទៅភូមិភាគ។ ភីភួន បញ្ជាក់ថា គាត់បានបញ្ជូនលិខិតទាំងអស់នោះទៅឲ្យ ខៀវ សំផន នៅ ក-១ និង ក-៣ ហើយ ខៀវ សំផន ប្រាប់គាត់ថា គាត់រៀបចំនឹងបញ្ជូន ហើយនិងផ្ញើសំបុត្រមួយចំនួនទៅភូមិភាគនានា។ ភស្តុតាងបានបង្ហាញពីបញ្ហាសំខាន់ៗចំនួនពីរក្នុងការជំនុំជម្រះនេះ។ ទី១ គឺថា ខៀវ សំផន បានទទួលតំណែងបន្តពី ឌឿន ក្នុងឋានៈជាប្រធាននៃមន្ទីរគណៈ៨៧០ ហើយទី២ថាការទទួលខុសត្រូវរបស់លោក ខៀវ សំផន នៅក្នុងមន្ទីរ៨៧០ រាប់បញ្ចូលទាំងការទទួលការប្រគល់ បញ្ជូនចេញនូវលិខិតទាក់ទងរវាងភ្នំពេញនិងភូមិភាគនានា។ ជាពិសេសទៅទៀត តួនាទីរបស់គាត់នៅមន្ទីរ៨៧០ដែលគេបញ្ជូនសារទូរលេខនិងរបាយការណ៍ទៅគាត់រក្សាទុក។ គាត់ជាមេដឹកនាំម្នាក់នៃបក្សកុម្មុយនីស្តកម្ពុជា ជាមួយ នួន ជា ហើយនិងប៉ុល ពត ដែលចូលរួមជាទៀងទាត់នៅក្នុងកិច្ចប្រជុំអចិន្ត្រៃយ៍ ដែលគេពិភាក្សាអំពីរបាយការណ៍មកពីភូមិភាគ ហើយនិងការប្រជុំរវាងមជ្ឈិមបក្ស ហើយនិងមេដឹកនាំមកពីភូមិភាគ និងតំបន់ផ្សេងៗដែលស្តាប់របាយ-ការណ៍ផ្ទាល់មាត់នៅក្នុងកិច្ចប្រជុំលើបញ្ហាទាំងអស់នោះ។

[១៥:៣១:៤៩]

អ្នកយាមមកពីក-១ និងក-៣ បានបញ្ជាក់នៅក្នុង សវនាការថា ហើយបានកំណត់អត្តសញ្ញាណស្របគ្នាថា ខៀវ សំផន ហើយនិង នួន ជា គឺជាមេដឹកនាំ ពីររូបនៃបក្សកុម្មុយនីស្តកម្ពុជាដែលបានចូលរួមជាប្រចាំនៅក្នុងកិច្ចប្រជុំជាមួយកម្មាភិបាលភូមិភាគ និងតំបន់នៅពេលដែលគេមកភ្នំពេញ។ សក្ខីកម្មទាំងអស់នេះគឺស៊ីសង្វាក់ទៅនឹងកំណត់ហេតុនៃកិច្ចប្រជុំថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ របស់គណៈអចិន្ត្រៃយ៍និយាយពីការងារមូលដ្ឋាន ឯកសារនោះកត់ត្រាថា នួនជា និង ខៀវ សំផន បានចូលរួមដែលនៅក្នុងកិច្ចប្រជុំជាមួយលេខាសៀមរាប តំបន់១០៦ ហើយនិងព្រះវិហារតំបន់១០៣ ហើយនិងអនុលេខាភូមិភាគឧត្តរ រាយការណ៍ទៅមេដឹកនាំមជ្ឈិមបក្ស អំពីសភាពការណ៍នៅក្នុងតំបន់រាប់បញ្ចូលទាំងការចាប់ខ្លួនខ្មាំង ការបង្កបង្កើនផលស្រូវ ការសាងសង់ ភ្លឺស្រែ ហើយនិងសុខភាព ហើយនិងជីវភាពរបស់ប្រជាជន។

លោក លោកស្រីចៅក្រម ភស្តុតាងបានបង្ហាញចំពោះលោកទាំងអស់ថា គឺមានហួសពីវិមតិសង្ស័យថា ជនជាប់ចោទទាំងពីរហ្នឹងបានទទួលរបាយការណ៍ចូលរួមក្នុងកិច្ចប្រជុំ ដែលគាត់បានទទួលព័ត៌មានពីសភាពការណ៍ពីភូមិភាគហើយនិងតំបន់ស្វយ័តនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ។

[១៥:៣៣:២០]

ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតចូលទៅដល់ខ្លឹមសារនៃរបាយការណ៍ទាំងអស់នោះ។ នៅក្នុងកថាខណ្ឌ

២០៣ នៃសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា គាត់មិនបានជំទាស់ថា មិនបានទទួលរបាយការណ៍ពីលេខាភូមិភាគ និងតំបន់ស្វយ័តទេ ប៉ុន្ដែគាត់អះអាងថាព័ត៌មានដែលមាននៅក្នុងរបាយការណ៍ទាំងនោះគឺមានលក្ខណៈមានកម្រិត ឬមិនពេញលេញ ពីព្រោះព័ត៌មានបានឆ្លងកាត់លំដាប់ថ្នាក់ជាច្រើនមុននឹងមកដល់មជ្ឈិមបក្ស។ នេះជាការលើកឡើងមួយដែលយើងអាចធ្វើការវាយតម្លៃហើយនិងច្រានចោលយ៉ាងងាយស្រួល។ ដោយហេតុថាបើយើងមើលសារទូរលេខ និងរបាយការណ៍គឺឯកសារទាំងនោះពិតជាបានជូនទៅ នួន ជា និងមជ្ឈិមបក្ស។ សូមអនុញ្ញាតជាមួយនឹងសារទូរលេខដែលបានបញ្ជូនមកពី សោ ភឹម ជាលេខាភូមិភាគបូព៌ា ដែលប្រើឈ្មោះហៅថា ឆុន ជូន ប៉ុល ពត ថ្ងៃទី២១ មីនា ឆ្នាំ១៩៧៦។ នៅខាងក្រោមដាក់ថាចម្លងជូនទៅ បងនួន និងបងស៊ី។ នៅក្នុងកថាខណ្ឌទី១ នៃសារទូរលេខនេះ មេដឹកនាំមជ្ឈិមបក្សត្រូវបានជូនដំណឹងថា កងកម្លាំងនៅភូមិភាគបូព៌ាបានចាប់ខ្លួនខ្មាំងវៀតណាមប្រាំ ហើយនៅក្នុងព្រៃពីរ ត្រូវបានបាញ់ចោល ហើយបីទៀតត្រូវបានឃុំខ្លួន។ កថាខណ្ឌទី២និយាយអំពីការសួរចម្លើយបុគ្គលមួយចំនួន ដែលគេចោទថាបានគប់គ្រាប់បែក ហើយចង់ជំទាស់ការកសាងប្រព័ន្ធភ្លឺស្រែ ហើយទូរលេខនោះបានបញ្ជាក់ថា៖ “យើងបានវាយគេនៅក្នុងសួរចម្លើយអំពីអង្គការចាត់តាំងរបស់គេ ហើយបញ្ជាក់ពីបញ្ហា២០ទៀតនៅក្នុងមូលដ្ឋាន នៅក្នុងស្រុកព្រះស្ដេច”។

[១៥:៣៥:២៦]

លោក លោកស្រីចៅក្រម! នេះជាសារទូរលេខមួយខ្លី ក៏ប៉ុន្ដែរបាយការណ៍អំពីការសម្លាប់ការឃុំខ្លួន ការប្រើទារុណកម្ម ការសួរចម្លើយអ្នកឃុំខ្លួន ដើម្បីស្វែងរកខ្សែរបស់គេ។ នេះគឺពិនិត្យឃើញថា នួន ជា អះអាងថា មេដឹកនាំភូមិភាគ លាក់កំបាំងពីអ្វី ពីមជ្ឈិមបក្សមិនឲ្យដឹង។ ហើយដូចដែលលោកស្រីចៅក្រមដឹងហើយថា នៅក្នុងសារទូរលេខនេះមិនមែនជាការលើកលែងដោយឡែកទេ ក៏ប៉ុន្ដែវាជាតំណាងឲ្យប្រភេទរបាយការណ៍ដែលបញ្ជូនទៅមេដឹកនាំនៅភ្នំពេញជារៀងរាល់ថ្ងៃ ពេញមួយរបបកម្ពុជាជាប្រជាធិបតេយ្យ។

ឥឡូវនេះ យើងពិនិត្យមើលតំបន់មួយទៀតនៅក្នុងខេត្តមណ្ឌលគិរី តំបន់១០៥ ជាតំបន់ស្វ័យតដែលរាយការណ៍ដោយផ្ទាល់ទៅមេដឹកនាំបក្សនៅភ្នំពេញ។ នេះជាសារទូរលេខផ្ញើពី ចាន់ មកមន្ទីរ -- ពីចាន់ មក៨៧០ នៅថ្ងៃទី២០ ឧសភា ១៩៧៧ ដោយលេខាតំបន់១០៥ ឡាំង ហៅថា “ចាន់”។ យើងបានស្ដាប់សក្ខីកម្មពីកូនរបស់លោក ឡាំង ឈ្មោះ ខាំ ផាន់ ដែលធ្វើការនៅមន្ទីររបស់ឪពុករបស់គាត់នៅក្នុងសម័យនោះ គាត់បានបញ្ជូននិងផ្ញើសារទូរលេខ។ ដូចដែលលោកចៅក្រមបានជ្រាប ខាំ ផាន់

បានបញ្ជាក់ថា "ឪពុករបស់គាត់បានរាយការណ៍ ហើយនិងទទួលការណែនាំពី នួន ជា លើបញ្ហាដែលទាក់ទងទៅនឹងសន្តិសុខ"។ នៅក្នុងសារទូរលេខនេះ លេខាតំបន់ ឡាំង រាយការណ៍នៅក្នុងកថាខណ្ឌទី២ អំពីការចាប់ខ្លួនយួនពីរនាក់។ នៅក្នុងកថាខណ្ឌ៣ គាត់រាយការណ៍អំពីខ្មាំងផ្ទៃក្នុងដែលកត់សម្គាល់ ហើយគាត់សង្ស័យគឺថា "សកម្មភាពបន្តម្តងហើយ ម្តងទៀត ហើយយើងបានចាប់មួយ ត្រូវតែចាប់មួយទៀតដែរ"។

[១៥:៣៧:២៤]

លោក លោកស្រីចៅក្រម អាចនឹងនឹកឃើញហើយ លេខាតំបន់១០៥ បានស្លាប់នៅឆ្នាំ១៩៧៧ ដែលគេចោទថា អនុរបស់គាត់ជាអ្នកបាញ់គាត់សម្លាប់នៅតាមផ្លូវទៅភ្នំពេញ ហើយក្រោយមក គឺ សៅ សារឿន បានជំនួសគាត់ជាលេខាតំបន់ ហើយគាត់បានមកទីនេះ គាត់មកធ្វើសក្ខីកម្មក្នុងសវនាការ ហើយបានកំណត់អត្តសញ្ញាណសារទូរលេខមួយចំនួនដែលគាត់បានបញ្ជូនទៅមន្ទីរ៨៧០។ នេះជាសារទូរលេខដែលបានបញ្ជូនដោយលេខាតំបន់ សារុន នៅថ្ងៃទី០៩ មេសា ឆ្នាំ១៩៧៨ រៀបរាប់អំពីខ្លឹមសារលម្អិតអំពីហេតុការណ៍ដែលថា គេបាត់ទូកពីរដោយសារមានហេតុការណ៍សាំង។ ក្រៅពីនេះ គឺថាសមាជិកពីរនៅក្នុងទូកនោះគឺត្រូវបានគេចាប់ ហើយមនុស្សម្នាក់ ទី៣នោះ គេហៅថា អាលីន គឺត្រូវបានគេឆ្លើយដាក់នៅក្នុងការសួរចម្លើយ នៅក្នុងសមាជិកនោះ។ ភស្តុតាងចំពោះអង្គជំនុំជម្រះរាប់បញ្ចូលទាំងចម្លើយរបស់ កង លាន ដែលជាកម្មាភិបាលតំបន់១០៥ ហើយបានរៀបរាប់អំពី លាន បានបាត់ខ្លួនបន្ទាប់ពីមានហេតុការណ៍ឆេះទូកនោះ ហើយគេបានដាក់គុកគាត់នៅមន្ទីរស-២១ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨។

សារទូរលេខមួយទៀត ដែលបញ្ជូនដោយតំបន់១០៥ ជាលេខា ដោយ សារុន គឺនៅថ្ងៃទី២៣ មេសា ១៩៧៨ បញ្ចើនៃចម្លងជូននៅខាងក្រោមនុ៎ង គឺថា "អ៊ំនួន ហើយនិងមន្ទីរ"។ សារទូរលេខនេះបានមានចំណារផ្ទាល់ដៃ ថា "អ៊ំនួន" នៅខាងឆ្វេងដៃខាងក្រោម។ នង សុផង់ បានបញ្ជាក់ថា ពីវិធីដែលគាត់ដឹកនាំក-១៨ ជាមន្ទីរសារទូរលេខដែលជាពិសេសការងារសំខាន់នោះ។ ហើយនៅក្នុងកថាខណ្ឌទី៣ គឺរបស់សារទូរលេខ សារុន ជាលេខាតំបន់បានស្វែងរកការណែនាំពីមជ្ឈិមបក្សទាក់ទងទៅនឹងកម្មាភិបាលតំបន់ដែលមានសាហាយស្មន់ ឬខុសសីលធម៌ជាមួយស្ត្រី ហើយទាំងពីរនាក់ត្រូវបានចាប់ខ្លួន។ សារុន ក៏បានរាយការណ៍ទៅកម្មាភិបាលនុ៎ង បានឆ្លើយដាក់ពីមុនដោយខ្លាំង គឺអាឈួន។ នៅពេលនោះតំបន់បានតាមដានសកម្មភាពរបស់លោក។ លោក លោកស្រីចៅក្រម! ឈួន គឺជាប្រធានមន្ទីរពាណិជ្ជ

កម្មតំបន់១០៥ គេបានចាប់ខ្លួន ហើយបញ្ជូនមកស-២១ ហើយដូចបញ្ជាក់នៅក្នុងសារទូរលេខ ហើយ សៅ សារុន ក៏បានទទួលស្គាល់ឈ្មោះកម្មាភិបាលតំបន់១០៥ ដែលឆ្លើយដាក់នៅក្នុងចម្លើយសារភាព ស-២១ គឺត្រូវបានបញ្ជូនទៅតំបន់ដើម្បីឲ្យគេតាមដានរក។ សារទូរលេខនេះគឺស្នើសុំយោបល់ពីអង្គការ ដើម្បីដាក់ទោសថា តើត្រូវបញ្ជូនកម្មាភិបាលចាប់ខ្លួនទៅណា។

[១៥:៤០:៣៦]

លោក លោកស្រីចៅក្រម! នេះជាឯកសារមួយចំនួនដែលយើងបានឃើញ។ សារទូរលេខនេះ បានបដិសេធលើការអះអាងរបស់ នួន ជា ថាលេខាតំបន់មិនបានជូនដំណឹងទៅបក្សអំពីហេតុការណ៍ នៅក្នុងតំបន់។ ទូរលេខចាស់ចុងក្រោយពីរ ដែលយើងបានមើល គឺនិយាយពីការជូនទៅមេដឹកនាំនៅ ភ្នំពេញជាពិស្តារអំពីការបាញ់ទៅលើទូក ហើយនិងកិច្ចការខុសសីលធម៌នោះផងដែរ។ នេះជាកម្រិតនៃ ការពិនិត្យដែលត្រូវបានអនុវត្តដោយមជ្ឈិមបក្សទៅលើប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យ។ អ្វីៗគេ តាមដានយ៉ាងជិតស្និទ្ធ ហើយនិងតាមដានដោយអង្គការ។ ការខុសបន្តិចបន្តួច ការដែលធ្វើឲ្យខូចចង្កៀង ឬក៏ភ្លើងនៅលើទូកក្ដី ឬក៏ពិនិត្យ ដែលត្រូវបានពិនិត្យថាអំពើក្បត់ជាតិ និងបញ្ជូនទៅភ្នំពេញ។ នេះគឺជា តថភាពដ៏តឹងរ៉ឹងរបស់សង្គមដែលត្រូវបានគេតាមដានដោយ នួន ជា, ខៀវ សំផន ហើយនិងមេដឹកនាំ របស់បក្សកុម្មុយនីស្តកម្ពុជា។ របាយការណ៍មកពីភូមិភាគនានាក៏មានសេចក្ដីលម្អិតដូចគ្នាដែរ។ ហើយ ការនិយាយអំពីការចាប់ខ្លួន ការសួរចម្លើយ ការសម្លាប់ ហើយនិងការតាមខ្លួន តាមរកបណ្ដាញខ្មាំង គិញ ហើយនិងជនក្បត់។ បើយើងមើលសារទូរលេខមកពីភូមិភាគឦសានចុះថ្ងៃទី១៥ មិថុនា ១៩៧៧ នៅក្នុងកន្លែងចម្លងជូននោះថា "អ៊ំនួន ហើយនិងមន្ទីរ"។ រៀបរាប់អំពីការចាប់ខ្លួន ការសួរចម្លើយដោយ កងពល៨០១ ហើយទាហានវៀតណាម ២០៩នាក់របស់ជនជាតិចារ៉ាយដែលជាក្រុមជនជាតិភាគតិច ដែលរស់នៅក្នុងតំបន់រវាងកម្ពុជា និងវៀតណាម។

[១៥:៤២:៣៨]

ផ្នែកទី២ នៃរបាយការណ៍ទូរលេខនេះគឺនិយាយពីចម្លើយសារភាពរបស់មនុស្សមួយចំនួន ដែល បង្កប់ខ្លួននៅក្នុងចម្ការកៅស៊ូ និងចម្ការកប្បាស ហើយត្រូវបានចោទប្រកាន់ថាជាខ្សែរបស់ខ្មាំង ហើយ គេដាក់បញ្ចូលនៅក្នុងទូរលេខនេះ គឺត្រូវសុំសេចក្ដីសម្រេចពីថ្នាក់លើ។ ឆោម សែ ប្រធានមន្ទីរសន្តិសុខ ៨០១ បានបញ្ជាក់ថា អ្នកឃុំខ្លួនចារ៉ាយភាគច្រើននេះ ក្រោយមកគេបណ្ដើរទៅគុករបស់គាត់ហើយគេ បានសម្លាប់អ្នកទាំងអស់នោះជាខ្សែ ដោយធ្វើតាមបញ្ជាដែលចេញដោយមន្ទីរភូមិភាគឦសាន។ លោក

លោកស្រីចៅក្រមបានឃើញសារទូរលេខជាច្រើនដែលរាយការណ៍មកពីភូមិភាគឧត្តរ កង ចាប ហៅ សែ ក្នុងអំឡុងពេលនៃសវនាការនេះ។

មានព័ត៌មានលម្អិតជាច្រើនដែលរាយការណ៍ទៅមជ្ឈិមបក្ស ដែលហេតុការណ៍កើតឡើងនៅភូមិភាគនោះ។ ខ្ញុំនឹងពិភាក្សាពីបញ្ហាខ្លះៗលម្អិតនៅពេលក្រោយ។ ប៉ុន្តែនៅពេលនេះ ខ្ញុំកត់សម្គាល់ឃើញថា នៅថ្ងៃទី១០ មេសា ឆ្នាំ១៩៧៨ សារទូរលេខនោះគឺ សែ ជាលេខាភូមិភាគ(បញ្ជាក់គណៈ៨៧០) ហើយចម្លងជូន អ៊ំនួន នៅមន្ទីរ ហើយបានរាយការណ៍បញ្ហាមួយចំនួនជាប្រចាំ ហើយបញ្ជាក់ថាមេដឹកនាំមជ្ឈិមបក្ស។ ការពិភាក្សានៃសារទូរលេខនេះជាលម្អិតនិយាយពីការសភាពការណ៍ខ្មាំងក្នុង និងខាងក្រៅខ្មាំងនៅក្នុងតំបន់ឧត្តរ។ ហើយផ្នែកទី៣នៃទូរលេខនេះ លេខាតំបន់បាននិយាយថា អំពីការបោសសម្អាតតំបន់១០៣ ព្រះវិហារ ដែលរាប់បញ្ចូលទាំងអ្នកជំទាស់នឹងបដិវត្តន៍ដោយចំហ និងដោយសម្ងាត់ក្ដី។ បន្ទាប់មកគាត់បានរៀបរាប់ពីការចាប់ខ្លួនកម្មាភិបាល ហើយសូមដកស្រង់ “សូមបញ្ជាក់នៅក្នុងរបាយ-ការណ៍ មិត្តនារី TCW-547 ដែលជាប្រពន្ធរបស់សមមិត្តនេះ។ សមមិត្តនេះត្រូវបានឆ្លើយដាក់ដោយខ្មាំងជាច្រើន។ ខ្ញុំដកសមមិត្តនេះ ហើយបញ្ជូនឲ្យទៅនៅមន្ទីរភូមិភាគ៨០១ ដើម្បីកុំឲ្យគាត់អាចចូលរួមក្នុងសកម្មភាពក្បត់បន្តទៅទៀត”។ សូមបញ្ចប់សេចក្ដីដកស្រង់។

[១៥:៤៥:១៣]

បន្ទាប់ពីមជ្ឈិមបក្សបានទទួលពីការចាប់ខ្លួនហើយ កម្មាភិបាលនារីនេះត្រូវបានរៀបរាប់នៅក្នុងសារទូរលេខគឺ TCW-547 ត្រូវបានបញ្ជូនទៅភ្នំពេញ ហើយត្រូវបានឃុំខ្លួននៅក្នុងមន្ទីរបណ្ដោះអាសន្នមាត់ទន្លេ។ ជាសំណាងល្អ គឺខ្មែរក្រហមនោះត្រូវបានបណ្ដេញដេញចេញនៅក្នុងបន្ទាប់ អាទិត្យបន្ទាប់នោះ ដូច្នេះហើយមុនពេលដែលគេបញ្ជូនគាត់ទៅ ស-២១។ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានពិនិត្យឃើញចម្លើយរបស់គាត់ ហើយនៅក្នុងរបាយការណ៍ខ្លីដែលបញ្ជូនដោយសារទូរលេខ យើងដឹងពីសក្ខីកម្មដែលធ្វើការនៅក្នុងសារទូរលេខនៅភ្នំពេញដែលបញ្ជូនទូរលេខមួយក្នុងមួយថ្ងៃយ៉ាងហោចណាស់ទៅមជ្ឈិមបក្ស។ ទំនាក់ទំនងសារទូរលេខនេះគឺថាអាចពិនិត្យឃើញ ហើយអាចបញ្ជាក់ ហើយពិនិត្យមើល និងសារទូរលេខដែលអាចផ្ញើអំពីតំបន់មួយចំនួន ដែលគេដាក់លេខរៀងជាបន្តបន្ទាប់នោះ។

ក្រៅពីទូរលេខប្រចាំថ្ងៃ ភូមិភាគក៏បានបញ្ជូនប្រចាំសប្ដាហ៍ ប្រចាំខែទៅមជ្ឈិមបក្សដែលរៀបរាប់ជាលម្អិតអំពីសភាពការណ៍នៅក្នុងតំបន់របស់ពួកគេ។ E3/1094 គឺជារបាយការណ៍ប្រចាំខែមកពីភូមិភាគបស្ចិម ខែកក្កដា ឆ្នាំ១៩៧៨។ ឯកសារខ្មែរដើមនោះគឺមាន១៤ទំព័រ នៅក្នុងភាសាអង់គ្លេសបក

ប្រែ១៦ទំព័រ។ នៅក្នុងចំណុចកណ្ដាលនោះ គឺនិយាយអំពីការរាយការណ៍អំពីសកម្មភាពខ្មាំង សភាព-ការណ៍ខ្មាំង ដូចជាសកម្មភាពខ្មាំងនៅភូមិភាគបស្ចិមដែលរៀបរាប់ជាលម្អិតដោយផ្នែកៗនីមួយៗ តាមតំបន់មួយៗ តាមស្រុក ហើយនិងសហករណ៍នីមួយៗ បុគ្គលនានាដែលត្រូវបានចាប់ខ្លួន សួរចម្លើយ ហើយនិងសម្លាប់ចោលនៅក្នុងតំបន់ទាំងនោះ ព្រមទាំងបុគ្គលដែលគេសង្ស័យថាជាខ្មាំង។

[១៥:៤៧:៣០]

ឯកសារ E3/179 គឺជារបាយការណ៍មកពីភូមិភាគពាយ័ព្យ គឺចាប់ពីថ្ងៃទី០៤ ដល់ ២៩ ឧសភា ឆ្នាំ១៩៧៧។ E3/1179 គឺជារបាយការណ៍ភូមិភាគពាយ័ព្យ ក្នុងសម័យកាលថ្ងៃទី២៤ ឧសភា ដល់ថ្ងៃទី ០៧ មិថុនា ឆ្នាំ១៩៧៨ ដូចជារបាយការណ៍មកពីភូមិភាគបស្ចិមដែរ មានព័ត៌មានពិស្ដារអំពីខ្មាំង ការបង្កបង្កើនផលស្រូវ ហើយនិងការផ្គត់ផ្គង់ស្បៀងអាហារ និងសុខភាពប្រជាជននៅក្នុងតំបន់នានានៅក្នុងភូមិភាគពាយ័ព្យ។ តាមពិតរបាយការណ៍នេះវែង ខ្ញុំមិនពិនិត្យដោយលម្អិតនោះទេ ប៉ុន្តែជាឯកសារសំខាន់ណាស់។ នៅពេលដែលយើងពិនិត្យមើលការអះអាងរបស់មេធាវីការពារក្ដីរបស់ នួន ជា នោះ ព័ត៌មាន គឺរាយការណ៍ថា របាយការណ៍នោះវាមានកម្រិតទេមកពីភូមិភាគ។

ខ្ញុំចង់ជម្រាបលោក លោកស្រីចៅក្រមឲ្យពិនិត្យមើលផ្នែកទី២ នៃរបាយការណ៍ថ្ងៃទី២៩ ឧសភា ឆ្នាំ១៩៧៧ មកពីភូមិភាគពាយ័ព្យ ដែលពិភាក្សាអំពីសភាពការណ៍ប្រជាជននៅក្នុងភូមិភាគ។ ផ្ទុយពីអ្វីដែលយើងបានឮពីជនជាប់ចោទនៅក្នុងការជំនុំជម្រះនេះ ភូមិភាគពាយ័ព្យបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងរបាយការណ៍ខ្លួន អំពីកង្វះម្ហូបអាហារ និងបញ្ហាសុខភាពរបស់ប្រជាជនដែលរស់នៅក្នុងភូមិភាគនោះ។ នៅក្នុងឯកសារនេះរបាយការណ៍របស់ភូមិភាគពាយ័ព្យបានរាយការណ៍ដូចតទៅ៖ ការរស់នៅរបស់ប្រជាជនគឺមានការខ្វះខាតនៅក្នុងតំបន់ជាច្រើន។ ឥឡូវនេះប្រជាជននៅក្នុងតំបន់១, ២, ៤, ៦ និង៧ គឺត្រូវការជំនួយយ៉ាងខ្លាំង។ មនុស្សភាគច្រើននៅខាងមូលដ្ឋាន គឺថាហូបតែបបរតែប៉ុណ្ណោះ។ នៅក្នុងកថាខណ្ឌបន្ទាប់ភូមិភាគបានរាយការណ៍ថា៖ “ជម្រកសម្រាប់ប្រជាជនត្រូវបានកសាងឡើងជាចុងក្រោយ។ ដូច្នេះហើយឥឡូវនេះគឺថាមិនមានមនុស្សដែលមិនមានកន្លែងស្នាក់នៅ ដេកនៅដីទៀតនោះឡើយ។ គឺមិនដូចនៅក្នុងឆ្នាំ៧៥, ៧៦នោះឡើយ។

[១៥:៤៩:៤៤]

លោក លោកស្រីចៅក្រមទាំងអស់នេះគឺជាទិដ្ឋភាពរបស់ភូមិភាគ ដែលមិនបានលាក់អំពីការខ្វះចំណីអាហារ ឬក៏បញ្ហានៃការរស់នៅពីមជ្ឈិមបក្សនោះឡើយ។ ប៉ុន្តែនៅពេលដែល នួន ជា និង ខៀវ

សំផន បានអះអាងថា ពួកគេមិនបានដឹងថាប្រជាជនរាប់សែននាក់ ដែលពួកគេបញ្ជូនទៅកាន់ភូមិភាគពាយ័ព្យនោះ គ្មានចំណីអាហារ ជម្រក និងថ្នាំសង្កូវនោះ គឺថាពួកគេនិយាយកុហកទាំងស្រុកតែងម្តង។

លោក លោកស្រីចៅក្រម គោលដៅសំខាន់នៃការរាយការណ៍ចំពោះមេដឹកនាំមជ្ឈិមបក្សគឺថាដើម្បីឲ្យមេដឹកនាំមជ្ឈិមបក្សផ្តល់យោបល់ ក៏ដូចជាការណែនាំទៅកាន់ភូមិភាគ យោធា និងអង្គការដទៃទៀត។ ដូចដែលបានបញ្ជាក់នៅក្នុងទស្សនាវដ្តីទង់បដិវត្ត ខែកញ្ញា ឆ្នាំ១៩៧២។ ខ្ញុំសូមដកស្រង់ "របាយការណ៍ជាទៀងទាត់ និងច្បាស់លាស់ ទៅថ្នាក់លើ ជួយឲ្យពួកយើងទទួលបានព័ត៌មាន ហើយនិងដឹងអំពីស្ថានការណ៍ជាក់ច្បាស់ ដែលធ្វើឲ្យយើងអាចផ្តល់យោបល់ដោយផ្ទាល់ និងដោយទាន់ពេលវេលា។ ការណែនាំជាមូលដ្ឋានចំពោះមូលដ្ឋានហ្នឹង ត្រូវបានបញ្ជាក់ឡើងម្តងទៀត នៅក្នុងកិច្ចប្រជុំ ថ្ងៃទី០៨ មីនា ១៩៧៦ របស់គណៈអចិន្ត្រៃយ៍ជាមួយនឹងមេដឹកនាំភូមិភាគពាយ័ព្យ និងតំបន់១០៣" -- ហើយ១០៣ និង ១០៦ ហើយខ្ញុំសូមដកស្រង់៖ "បញ្ជូនរបាយការណ៍ជាទូទៅ បញ្ជូនរបាយការណ៍តាមរយៈមុខព្រួញជាច្រើន។ រៀបចំរបាយការណ៍ដោយខ្លីដោយតែឡេក្រាម ដើម្បីឲ្យគណៈអចិន្ត្រៃយ៍អាចដឹងអំពីស្ថានភាពដើម្បីផ្តល់នូវការណែនាំឲ្យទាន់ពេលវេលា"។

[១៥:៥១:២៦]

លោក លោកស្រីចៅក្រម យើងបានឃើញថាសារទូរលេខត្រូវបានបញ្ជូនទៅមេដឹកនាំនៅទីក្រុងភ្នំពេញស្នើសុំការណែនាំ ឬក៏មតិយោបល់ ហើយសាក្សីដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះបានបញ្ជាក់ផងដែរ ថាមេដឹកនាំមជ្ឈិមបក្សឆ្លើយតបទៅនឹងសារទូរលេខទាំងអស់នោះ។ លេខាតំបន់១០៥ លោក សៅ សារុន បានផ្តល់សក្ខីកម្មថា សារទូរលេខរបស់គាត់ តែងតែការទទួលការឆ្លើយតបជាទូទៅដោយ ប៉ុល ពត ឬក៏ នួន ជា។ លោក នង សុផង់ បានរៀបរាប់អំពីសារទូរលេខដែលបញ្ជូនចេញដោយមន្ទីរ៨៧០ ជាការណែនាំពីអាជ្ញាធរជាន់លើទៅដល់ថ្នាក់ក្រោម ដែលគ្របដណ្តប់ទៅលើគ្រប់បញ្ហាទាំងអស់នៅក្នុងប្រទេស។

លោក លោកស្រីចៅក្រម រចនាសម្ព័ន្ធគ្រប់គ្រងជាមូលដ្ឋានរបស់បក្សកុម្មុយនីស្តកម្ពុជា រួមទាំងបញ្ចូលទាំងទំនាក់ទំនងរវាងមជ្ឈិមបក្ស និងភូមិភាគ គឺត្រូវបានកំណត់ដោយលក្ខន្តិកៈបក្ស ដែលត្រូវបានចាត់តាំងថា -- ដែលត្រូវបានរៀបចំឡើងនៅគណៈមជ្ឈិមថាជា អង្គភាពអនុវត្តយ៉ាងជិតស្និទ្ធ។

[១៥:៥២:៣៩]

ឥឡូវនេះ យើងមើលទៅលើមាត្រា២៣ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាដែលបានតាំងគណៈ

មជ្ឈិម គឺមានការទទួលខុសត្រូវដូចតទៅ៖ ទី១) គឺអនុវត្តមាគ៌ានយោបាយរបស់បក្ស និងលក្ខខណ្ឌរបស់បក្សនៅក្នុងបក្សទាំងមូល។ ទី២) ណែនាំអង្គការភូមិភាគ តំបន់ ក្រុងទាំងអស់ និងអង្គការបក្សទទួលខុសត្រូវផ្នែកផ្សេងៗ ទូទាំងប្រទេស ធ្វើសកម្មភាពតាមមាគ៌ានយោបាយ គោលជំហរសតិអារម្មណ៍។

ប្រសិនបើយើងមើលទៅលើមាត្រា២៧ គឺបាននិយាយអំពីកងទ័ពបដិវត្តកម្ពុជាដែលត្រូវស្ថិតនៅក្រោមការដឹកនាំផ្តាច់មុខ ដាច់ខាត និងគ្រប់ផ្នែករបស់បក្សកុម្មុយនីស្តកម្ពុជា។ ក្នុងនាមជាសមាជិករបស់គណៈមជ្ឈិម ដែលជាផ្នែកមួយដ៏ក្រុមនៅក្នុងថ្នាក់ដឹកនាំមជ្ឈិមបក្សដែលគ្រប់គ្រងទៅលើប្រទេសជារៀងរាល់នោះ ទាំង នួន ជា និង ខៀវ សំផន មានសិទ្ធិអំណាច ហើយនិងមានការទទួលខុសត្រូវទៅលើភូមិភាគ និងកម្មាភិបាលយោធាដែលអនុវត្ត ដែលប្រព្រឹត្តនូវបទល្មើសដែលជាប្រធានបទនៃការចោទប្រកាន់នៅក្នុងការជំនុំជម្រះនេះ។

[១៥:៥៣:៤៩]

វិធីសាស្រ្តការពារខ្លួនដែលថា ភូមិភាគគាត់អនុវត្តការងារដោយស្វ័យភាពហ្នឹង គឺត្រូវបានជំទាស់ឡើងដោយឯកសារដែលបានកត់ត្រានូវសេចក្តីសម្រេច និងគោលនយោបាយរបស់មជ្ឈិមបក្ស។ សារាចរដែលចេញដោយគណៈមជ្ឈិម ទស្សនាវដ្តីទង់បដិវត្ត និងកំណត់ហេតុការប្រជុំគណៈអចិន្ត្រៃយ៍បានបញ្ជោះទៅលើបញ្ហាទាំងអស់នេះ។ ឯកសារទាំងអស់នេះ បានបង្ហាញអំពីរចនាសម្ព័ន្ធដែលមជ្ឈិមបក្សធ្វើការសម្រេចចិត្ត ហើយនិងពិនិត្យមើលទៅលើការអនុវត្តមាគ៌ានយោបាយបក្ស ហើយនិងគោលនយោបាយរបស់បក្សដែលអនុវត្តដោយភូមិភាគ យោធា និងអង្គការកម្ពុជាប្រជាធិបតេយ្យដទៃទៀត។ ឧទាហរណ៍ច្បាស់លាស់នៃសិទ្ធិអំណាចរបស់គណៈមជ្ឈិម គឺសារាចរដែលខ្លួនចេញនៅថ្ងៃទី២០ ខែ៦ ឆ្នាំ១៩៧៨ ដែលធ្វើការកែសម្រួលទៅលើគោលនយោបាយបក្សទាក់ទងទៅនឹងខ្មាំង។ នៅក្នុងឯកសារទាំងអស់នេះ គណៈមជ្ឈិមបានកំណត់នូវចំនួនក្រុមមួយចំនួនដែលមិនត្រូវចាត់ទុកថាជាខ្មាំងនោះឡើយ។ ហើយវាក៏បានបញ្ជាក់ផងដែរថា បក្សនៅតែកម្ទេចបុគ្គលណាដែលបដិសេធមិនផ្លាស់ប្តូរគោលគំនិត ហើយបន្តធ្វើការជំទាស់ដាច់ខាតទៅនឹងបក្សកុម្មុយនីស្តកម្ពុជា។ ឯកសារនេះតែមួយគត់គឺអាចជំទាស់ដោយប្រសិទ្ធភាពទៅលើការអះអាងរបស់មេធាវីការពារក្តីដែលថាភូមិភាគអាចបំពេញការងារដោយស្វ័យភាពនៅពេលដែលធ្វើការចាប់ខ្លួន និងសម្លាប់ខ្មាំង។ ហើយឯកសារនេះបានបង្ហាញផងដែរថា វាគឺជាបញ្ហាដែលមជ្ឈិមបក្សធ្វើការអនុវត្តការគ្រប់គ្រង។ សិទ្ធិអំណាចក្នុងការគ្រប់គ្រងរបស់មជ្ឈិមបក្ស ក៏អាចមើលឃើញផងដែរនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ដែលចេញជារៀងរាល់ខែ ដែលផ្តើមដោយការណែនាំ និង

គោលការណ៍ណែនាំចំពោះសមាជិកបក្សទាក់ទងទៅនឹងការអនុវត្តមាគ៌ាបក្ស និងគោលនយោបាយបក្ស។

[១៥:៥៥:៤៣]

ទស្សនាវដ្ដីទង់បដិវត្តមួយចំនួនរួមមាននៅសុន្ទរកថា ដែលត្រូវបានផ្ដល់ដោយអ្នកតំណាងរបស់មជ្ឈិមបក្សនៅក្នុងការប្រជុំតាមភូមិភាគ ដែលនៅក្នុងនោះគឺវាបញ្ជាក់យ៉ាងច្បាស់ថាអ្នកណាជាមេដឹកនាំ ហើយអ្នកណាជាអ្នកនៅក្រោមបង្គាប់។ ឧទាហរណ៍ សំខាន់មួយនៃបញ្ហានេះ គឺទស្សនាវដ្ដីទង់បដិវត្តន៍ ខែ៨ ឆ្នាំ១៩៧៧ ដែលផ្សព្វផ្សាយអំពីសុន្ទរកថាដោយអ្នកតំណាងមជ្ឈិមបក្សនៅថ្ងៃ២៥ ខែកក្កដា ឆ្នាំ ១៩៧៧ នៅការប្រជុំកម្មាភិបាលភូមិភាគបស្ចិម។ ហើយទំនាក់ទំនងអាជ្ញាធរនេះគឺបញ្ជាក់យ៉ាងច្បាស់ ហើយខ្ញុំសូមដកស្រង់៖ "ខ្ញុំសូមឧទ្ទេសនាមអំពីសេចក្ដីណែនាំរបស់បក្សលើបញ្ហាមួយចំនួនសំខាន់ៗ សម្រាប់អនុវត្តក្នុងឆមាសទី២ ឆ្នាំ១៩៧៧ គឺជាបញ្ហាសំខាន់ៗដែលត្រូវអនុវត្តពីពេលនេះដល់ចុង ឆ្នាំ ១៩៧៧។ តាមខ្ញុំដឹងតាមសេចក្ដីរាយការណ៍របស់ភូមិភាគក្នុងប៉ុន្មានថ្ងៃកន្លងមកនេះ សមមិត្តគ្រប់តំបន់បានរៀនសូត្រនូវសេចក្ដីណែនាំរបស់បក្សនេះហើយ។ ក៏ប៉ុន្តែក្នុងឱកាសដែលការរៀនសូត្រពីស្រុកខណ្ឌពេលនេះ ស្រុកគំរូពេលនេះកំពង់ត្រឡាចលើ គឺគណៈភូមិភាគរួមជាមួយយល់ឃើញថាចាំបាច់ផ្សាយនូវសេចក្ដីណែនាំនេះ។ ដូច្នេះ អ្វីដែលយើងបានបញ្ជាក់នៅពេលនេះ គឺយើងអាចសម្រេចទៅបានក្នុងបីតោនទៅ ប្រាំមួយតោនក្នុងមួយហិកតា ហើយ និងបោសសម្អាតខ្មាំង ហើយនិងកសាងនៅថ្នាក់ដឹកនាំបក្ស។ សុន្ទរកថានេះរួមបញ្ចូលនូវការពិភាក្សាលម្អិតអំពីការបោសសម្អាតដែលកំពុងបន្តនៅភូមិភាគបស្ចិម ដែលរួមមានការបោសសម្អាតកម្មាភិបាល ដែលគេចាត់ទុកថាជាមេរោគ ហើយជាសាច់ស្អុយ។

[១៥:៥៧:៥០]

អ្នកតំណាងមជ្ឈិមបក្សបានបញ្ជាក់ បាននិយាយអំពីប្រជាជនដែលស្ថិតនៅក្នុងភូមិភាគបស្ចិមថាជាវត្តមាននៃសមាសធាតុមិនល្អ ឬក៏ជាជនក្បត់។ យើងលើកឧទាហរណ៍តែក្នុងភូមិភាគបស្ចិម ៨០ភាគរយទេដែលមិនល្អ។ យើងឃើញហាក់ដូចជាទាំងអស់ ការពិតមានតែ ៥០ភាគរយ ទេដែលមិនល្អ។ ក្នុង ៥០ភាគរយនេះទៀតក៏មិនមែនក្បត់ទាំងអស់ដែរ។ ក្បត់មានតែ២០ទៅ ៣០ភាគរយ -- មានតែ១០ ទៅ ២០ភាគរយតែប៉ុណ្ណោះ។ ដូច្នេះ ក្នុងពេលដែលគេរៀបរាប់អំពីខ្មាំងនៅភូមិភាគ គឺមជ្ឈិមបក្សបានកត់សម្គាល់ថា សហករណ៍ជាច្រើនត្រូវបានគ្រប់គ្រងដោយទាហានរបបចាស់ ហើយនិងអាជីវករមកពីកំពង់សោម។ គាត់ណែនាំដល់កម្មាភិបាលភូមិភាគឲ្យធ្វើការពិនិត្យមើលឡើងវិញ ទៅលើខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងដែលពិនិត្យទៅលើប្រវត្តិរូប និងចំណាត់ថ្នាក់របស់គណៈកម្មាធិការសហករណ៍ ហើយណែនាំ

ថាត្រូវធ្វើការកម្ទេចហើយនិងវាយប្រហារទៅលើខ្មាំង ហើយត្រូវគ្រប់គ្រងទៅលើសហករណ៍។ យើងត្រូវប្រើប្រាស់កម្លាំង វាមិនមែនជាបញ្ហារបស់ភូមិភាគណាមួយឡើយគឺជាបញ្ហារបស់ភូមិភាគទាំងអស់គ្នា។ ហេតុដូច្នេះហើយយើងមិនអាចមិនយកចិត្តទុកដាក់បាននោះទេ។ វាជាការពិបាកដើម្បីពិនិត្យមើលថាតើសហករណ៍ណាដែលគ្រប់គ្រងដោយខ្មាំងនៅក្រុមដទៃទៀត។ ហើយគាត់បានបញ្ជាក់យ៉ាងច្បាស់ថា ហោចណាស់ក៏មាន ៥០ភាគរយនៃសហករណ៍នៅក្នុងភូមិភាគត្រូវតែបោសសម្អាតដោយគោរពទៅតាមចំណាត់ថ្នាក់នៅចុងឆ្នាំ ហើយថា ១០០ភាគរយត្រូវបានបោសសម្អាតត្រឹមយ៉ាងយូរបំផុតពាក់កណ្ដាលឆ្នាំ១៩៧៨។ ទស្សនាវដ្ដីទង់បដិវត្តច្បាប់នេះបានបញ្ចប់ដូចតទៅនេះ យើងខ្ញុំសូមដកស្រង់៖ “ស្នើថ្នាក់ដឹកនាំបក្សគ្រប់ថ្នាក់យកចិត្តទុកដាក់ពិនិត្យពិភាក្សា សិក្សារៀនសូត្របទឧទ្ទេសនាមឲ្យបានហ្មត់ចត់ដើម្បីយកទៅអនុវត្តនៅតាមភូមិភាគរបស់ខ្លួនបានលទ្ធផលល្អ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញា។

បាទ ឥឡូវនេះសវនាការថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទទី២១ ខែតុលា ឆ្នាំ២០១៣ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី និងសាធារណជនបានជ្រាបផងដែរថា នៅថ្ងៃចន្ទ ដើមសប្ដាហ៍ក្រោយនេះអង្គជំនុំជម្រះនឹងផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាឡើងធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលផ្ទាល់មាត់របស់ខ្លួនបន្តបញ្ចប់។ ហេតុដូច្នេះ សូមភាគី បុគ្គលិក មន្ត្រីគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះ និងសាធារណជនជ្រាប និងសូមអញ្ជើញចូលរួមឲ្យបានមុនពេលកំណត់នេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ -- នាំខ្លួនពួកគាត់ត្រឡប់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃចន្ទទី២១ ខែតុលា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក ដោយលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះដោយផ្ទាល់។ ឯលោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកត្រឹមបន្ទប់ឃុំខ្លួន ដែលរៀបចំនៅឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរសវនាការពីចម្ងាយ។ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*